ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- និវាសនារីអន្តរជាតិ - ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ
- វេទិកាថ្នាក់រៀនស្តីអំពី «ប្រវត្តិសាស្រ្តកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

ចែកជូនដោយឥតគិតថ្លៃដល់មន្ទីរ ស្រុក និងឃុំ ទូទាំងព្រះរាជាណាចក្រកម្ពុជា

លេខ២៦៧ ខែមីនា ឆ្នាំ២០២២

# ស្វែងរកការពិត

## ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ ២៦៧ ខែមីនា ឆ្នាំ២០២២



ស្ត្រីកំពុងហាលស្រូវៗ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

## មាតិកា

### សំបុត្រ


- ទិវានារីអន្តរជាតិ ព្រះមហាក្សត្រី............១


### ផ្នែកឯកសារ


- សួស ណាន ហៅ ទេព ណាន.................... ៣
- សោម ពៅ៖ លេខាសង្កាត់បន្ទាយចក្រី .... ៥


### ផ្នែកប្រវត្តិសាស្ត្រ និងការស្រាវជ្រាវ


- អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា ទស្សនកិច្ច "បណ្ណាល័យសម្តេចម៉ែ"......... ៨
- ឯកអគ្គរដ្ឋទូតសិង្ហបូរីទស្សនកិច្ចតំបន់ ... ១២
- ដំណើរទស្សនកិច្ចរួមគ្នារបស់ឯកអគ្គរាជទូតអង់គ្លេស និងឯកអគ្គរដ្ឋទូតឥណ្ឌា ......... ១៦
- កិច្ចប្រជុំរវាងមជ្ឈមណ្ឌលឯកសារ និងអាជ្ញាធរមូលដ្ឋានក្នុងឃុំលាយបូរ.................... ២១
- ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មជួបប្រធានឃុំដាំ ............................... ២៤
- កិច្ចពិភាក្សារវាងមជ្ឈមណ្ឌលឯកសារកម្ពុជា និងអាជ្ញាធរស្រុកអង្គរធំ ....................២៦
- ក្រុមនិស្សិតស្ត្រីមកពីវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាមធ្វើទស្សនកិច្ចសិក្សា ..... ២៨
- ឈន ខិន្នែត ៖ ខ្មែរក្រហមយកឪពុកខ្ញុំ.... ៣១
- ថៃ ថាត ៖ ខ្មែរក្រហមសម្លាប់ក្រុមគ្រួសារ ... ៣៣
- ចៅ សុខហៀង៖ កងចល័តភូមិភាគ .....៣៥
- ធីក ង៉ែត៖ កងនារីស្រែអំបិល ........... ៣៧
- អ៊ាប ម៉ុង ៖ កងចល័តស្រុកព្រែកប្បាស ....៣៩
- ឪពុករបស់ខ្ញុំស្លាប់ដោយសារលួចដំឡូង ....៤១


### ផ្នែកវេទិកាសាធារណៈ


វេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅមជ្ឈមណ្ឌលឯកសារនៅ
- ខេត្តតាកែវ .................................៤៤
- ខេត្តព្រៃវែង ................................ ៤៧
- ខេត្តកំពង់ចាម ............................. ៥១


### ផ្នែកស្រាវជ្រាវរកគ្រួសារ

**«ទួលពិឃាដ»**


- ចោរលួចបាយក្តាំង .........................៥៥

វែកឆាចបដឹក មេចុងភៅបដិវត្តន៍ (ត)....៥៥



**រក្សាសិទ្ធិ**

មជ្ឈមណ្ឌលឯកសារកម្ពុជា

អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ

ក្រសួងព័ត៌មាននៃព្រះរាជាណាចក្រកម្ពុជា

ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន

លេខ៣៧៥ព.មប្រក

ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៨

រូបថតឯកសារ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា



**ស្នេរលេខនេះ ៖** ឆាំង យុ, ផាត ចាន់សុនិតា, ដា៉រ៉ារដ្ឋ មេត្តា, សុភ័ក្ត្រ ភាណា, មេក វិន, សៀង កញ្ញា, ឡុង ដានី, គីម សុវណ្ណដានី ទូច វណ្ណេត, សៀង កញ្ញា, ហៀក ស្រីពេជ្រ, មីន សាណាស់, ង៉ាន់ វីន, ផេង ពង្សរ៉ាស៊ី, មេន ឡឿន និង ឡុង វង្សសមិទ្ធ

**អ្នកនិពន្ធ និងស្រាវជ្រាវ៖** ផាត ចាន់សុនិតា **អ្នកបកប្រែ៖** លឹម អ៊ិភីង និង ជ័យ ចាន់ស៊ីណែត **និពន្ធនាយកទូទៅ៖** សោម ប៊ុនថន

**ជំនួយការនិពន្ធនាយក៖** ដា៉រ៉ារដ្ឋ មេត្តា **ក្រាហ្វិកកុំព្យូទ័រ៖** លី សេនសូនី ឡា **គ្រប់គ្រងការចែកផ្សាយ៖** ឆេង វ៉េង



Email: dccam@online.com.kh, Homepage: www.dccam.org, www.cambodiatribunal.org, www.cambodiasri.org

# ទិវានារីអន្តរជាតិ - ព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ

**ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា**




*សៀវភៅ «**សាក្សីប្រវត្តិសាស្ត្រ** ៖ សៀវភៅកំណត់ហេតុរបស់ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ»។ សៀវភៅកំណត់ហេតុរបស់សម្តេចព្រះវររាជមាតាជាតិខ្មែរ ត្រូវបានបកប្រែពីភាសាបារាំង ដោយលោកឯកអគ្គរាជទូតបណ្ឌិត ហូលីយ៉ូ អេ. ហែលជ្រេស ដែលបានបំពេញតួនាទីជាលេខាផ្ទាល់ជាន់ខ្ពស់របស់សម្តេចព្រះបរមរតនកោដ្ឋ ប្រមាណជាង១២ឆ្នាំ។ សៀវភៅកំណត់ហេតុនេះ បោះពុម្ពឡើងដោយគម្រោងស្រាវជ្រាវភាសាចិនរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

នៅថ្ងៃទី៨ ខែមីនាជារៀងរាល់ឆ្នាំ ទិវានារីអន្តរជាតិ គឺជាថ្ងៃដ៏វិសេសវិសាលបំផុតមួយ ដែលត្រូវបានប្រារព្ធឡើងដើម្បីអបអរដល់សមិទ្ធផលរបស់ស្ត្រី បង្កើនការយល់ដឹងអំពីសមភាពរបស់ស្ត្រី និងជំរុញសមភាពយេនឌ័រ ឲ្យកាន់តែប្រសើរឡើង។ ថ្ងៃនេះ ខ្ញុំសូមថ្វាយសម្តេចម៉ែនូវព្រះកិត្តិយស បំពោះ

ការបំពេញព្រះរាជកិច្ចដោយឥតនឿយណាយរបស់ព្រះអង្គ សម្រាប់ប្រជាជនកម្ពុជា ទាំងអស់។ ព្រះរាជដំណើរជីវិតមួយផ្នែកនៃព្រះអង្គ ត្រូវបានពិពណ៌នានៅក្នុងសៀវភៅ **សាក្សីប្រវត្តិសាស្ត្រ** ។ ក្នុងព្រះនាមជាព្រះរាជវរមាតាជាតិខ្មែរ ព្រះមហាក្សត្រី គឺជាព្រះរាជសាក្សីនៃជំពូកជាច្រើនរបស់ប្រវត្តិសាស្ត្រប្រទេសកម្ពុជា។ តាមរយៈប្រវត្តិសាស្ត្រនេះ ព្រះអង្គបានបំពេញព្រះរាជកិច្ចទាំងនៅលើឆាកជាតិនិងអន្តរជាតិ ព្រមទាំងព្រះរាជកិច្ចសំខាន់ៗជាច្រើនដែលមិនសូវដឹងឮ ដើម្បីទ្រទ្រង់ដល់ប្រជាជនកម្ពុជា ទាំងអស់។ ឆ្លៀតឱកាសនៅក្នុងថ្ងៃដែលទទួលស្គាល់ចំពោះតម្លៃ ក៏ដូចជាលើកកម្ពស់សិទ្ធិរបស់ស្ត្រីទាំងអស់ ខ្ញុំសូមថ្វាយព្រះកិត្តិយស សម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ដែលជាវីរស្ត្រីមួយព្រះអង្គ នៃស្ត្រីគ្រប់រូបនិងជនរួមជាតិកម្ពុជា ទាំងអស់។



ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ យាងទស្សនកិច្ចប្រាសាទបន្ទាយស្រី ក្នុងខេត្តសៀមរាប នៅឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ព្រះមហាក្សត្រី នរោត្តម មុនិនាថ សីហនុ ព្រះវររាជមាតាជាតិខ្មែរ គង់លើអង្រឹងសរសេរ កំណត់ហេតុក្នុងព្រះរាជដំណើរយាងមកកាន់តំបន់រំដោះក្នុងប្រទេសកម្ពុជានៅឆ្នាំ១៩៧៣។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



# សួស ណាន ហៅ ទេព ណាន គណៈស្រុកពាមជរ

**ផាត ចាន់សុនិតា**



កងចល័តនារី នៅភូមិភាគបូព៌ាកំពុងប្រមូលផលស្រូវ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៧៦ ក្រសួងសន្តិសុខតំបន់២១ រួមមានសមមិត្តភី (ប្រធានសួរចម្លើយ), សមមិត្តម៉ុន (អ្នកកត់ត្រា) និង សុភ័ន (កងការពារ) បានសួរចម្លើយទៅលើអ្នកទោសមកពីភូមិភាគបូព៌ាម្នាក់ឈ្មោះ សួស ណាន ដែលអង្គការចោទថាក្បត់។ នៅចំពោះមុខអ្នកសួរចម្លើយ សួស ណាន បានសារភាពដូចខាងក្រោម៖

ខ្ញុំឈ្មោះ សួស ណាន ឈ្មោះបដិវត្តន៍ ទេព ណាន ភេទប្រុស អាយុ៣៣ឆ្នាំ (នៅឆ្នាំ១៩៧៦)។ ខ្ញុំមានស្រុកកំណើតនៅភូមិ ត្រាច ឃុំដូនសរ ស្រុកមានជ័យថ្មី តំបន់២៤។ ឪពុករបស់ខ្ញុំឈ្មោះ សួស ហង់ និងម្ដាយឈ្មោះ ប៉ោក ទូច។ ខ្ញុំមានបងប្អូនបង្កើតចំនួន ៩នាក់ ស្រី៥នាក់ និងប្រុស៤នាក់។ ក្រុមគ្រួសាររបស់ខ្ញុំស្ថិតក្នុងវណ្ណៈកសិករថ្នាក់កណ្ដាលប្រកបមុខរបរធ្វើស្រែ។ ខ្ញុំមានកម្រិតវប្បធម៌កាលពីសង្គមចាស់រៀនដល់ថ្នាក់ទី២។ ខ្ញុំបានចូលរៀនជាមួយបដិវត្តន៍ ចំនួន៧វគ្គ ដូចជារៀននៅសាលាយោធាភូមិភាគ និងរៀននៅសាលានយោបាយ។ តាំងពីដើមមក ខ្ញុំពុំដែលធ្វើជាទាហានប៉ូលីសទេ ប៉ុន្តែខ្ញុំធ្លាប់បានចូលនិន្នាការនយោបាយជាមួយសង្គមរាស្ត្រនិយម។

ខ្ញុំបានចូលបដិវត្តន៍នៅសាលាកម្ពុជបុត្រដែលមានទីតាំងស្ថិតនៅទួលគោក, រាជធានីភ្នំពេញ ក្នុងឆ្នាំ១៩៦២ តាមរយៈសមមិត្ត វង់ ឈ្មោះបដិវត្តន៍ ឈូក បច្ចុប្បន្នជាលេខាតំបន់២៤។ បន្ទាប់ពីចូលបដិវត្តន៍ខ្ញុំទទួលបានតំណែងជាបន្តបន្ទាប់ៗ នៅឆ្នាំ១៩៦២ដដែល ខ្ញុំមានតួនាទីជាអ្នកដឹកនាំសិស្សនៅក្នុងសាលាកម្ពុជបុត្រ។ ក្រោយមក សមមិត្ត ឈូក បានខទ្ទេសនាមខ្ញុំចូលជាសមាជិកបក្សត្រៀមនៅថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៦៩ និងក្លាយជាសមាជិកពេញសិទ្ធិនៅថ្ងៃទី១០ ខែមីនា ឆ្នាំ១៩៧០។ បន្ទាប់ពីចូលបក្សជនពេញសិទ្ធិហើយ ខ្ញុំបានទៅនៅជាមួយសមមិត្ត គីម ឡាក់ ធ្វើជាលេខាស្រុកព្រៃវែង។ ក្រោយមក សមមិត្ត ណាំ សាន បានចាត់តាំងខ្ញុំឲ្យធ្វើជាលេខាយោធាតំបន់២៣។ នៅឆ្នាំ១៩៧១ ខ្ញុំធ្វើជាប្រធានសេនាធិការតំបន់២៤។ នៅឆ្នាំ១៩៧២ ខ្ញុំមានតួនាទីជាប្រធានយ២ តំបន់២៤។ រហូតដល់ឆ្នាំ១៩៧៣ អង្គការបានចាត់តាំងខ្ញុំឲ្យធ្វើជាអនុលេខាស្រុកពាមជរ។

ចំពោះសកម្មភាពគស៊ូរបស់ខ្ញុំក្នុងរយៈកាលកន្លងមកចាប់តាំងពីឆ្នាំ១៩៦២ ដល់ឆ្នាំ១៩៧០ ខ្ញុំចូលបម្រើខ្មាំងមានភារកិច្ចជាអ្នកយាមសាលា, យាមក្រុង, ចាំចាប់ខ្មែរក្រហមបាចខិតប័ណ្ណ។ លុះដល់ក្រោយឆ្នាំ១៩៧០ ខ្ញុំបានចូលបម្រើក្នុងចលានាមួយឈ្មោះ ចលានាសេរី ក្រោមការដឹកនាំរបស់ឈ្មោះ ឈូក គឺជាអ្នកទទួលខុសត្រូវរួមក្នុងប្រទេសដែលមានឋានៈពាក់ផ្កាយ៣, ចក្រី គឺជាប្រធានយោធារួមក្នុងប្រទេស ដែលមានឋានៈពាក់ផ្កាយ២ និង សុផាន ពាក់ផ្កាយ១។ ខ្ញុំដឹងច្បាស់ថា ចលនានេះមានការលម្អៀងស្តាំជ្រើសយកជនកុម្មុយនីស្តកណ្តាល និងកុម្មុយនីស្តសេរីក្នុងប្រទេសធ្វើជាកម្លាំងយុទ្ធសាស្ត្រ និងជ្រើសយកមូលដ្ឋានបង្អែកមានសូវៀត, ឆេកូស្លូវ៉ាគី, ប៉ូឡូញ, គុយបា និងជាពិសេសវៀតណាម។ ចលនាសេរីមានទិសដៅយុទ្ធសាស្ត្រគឺ ទី១) ត្រូវកសាងកម្លាំងយកចិត្តទុកដាក់ក្នុងអង្គភាពក្រសួងមូលដ្ឋានដែលមានការទុកចិត្ត មានជំហរកណ្តាល និងជំហរសេរី។ ទី២) ត្រូវប្រមូលស្បៀង និងយកចិត្តទុកដាក់បង្កបង្កើនផលឲ្យបានច្រើនជាងគេ និងកសាងមូលដ្ឋានបង្អែកត្រៀមធ្វើសង្គ្រាមយូរអង្វែង។ ទី៣) ត្រូវប្រមូលអាវុធទុកហើយបញ្ជូនអាវុធមានវៀតណាមផ្តល់ជំនួយជាមូលដ្ឋាន។

ដើម្បីឈានទៅរកការសម្រេចទិសដៅជាយុទ្ធសាស្ត្ររបស់ចលនាសេរីមានការរៀបចំសកម្មភាពដូចជា៖ ខាងផ្នែកចាត់តាំងរួមមានសមមិត្ត ឈូក ទទួលបន្ទុកខាងក្នុងប្រទេស និងទាក់ទងជាមួយវៀតណាម។ សមមិត្ត ចាន់ ចក្រី ទទួលបន្ទុកផ្នែកយោធាទូទាំងប្រទេស។ ចំណែកខាងផ្នែកនយោបាយមានខ្លឹមសារអប់រំចំនួនបីចំណុច គឺ៖ ១) កសាងកម្លាំងគ្រប់ផ្នែកឲ្យបានច្រើននៅក្នុងមូលដ្ឋាន និងអង្គភាពទាំងនយោបាយ និងសតិអារម្មណ៍។ ២) ត្រៀមលក្ខណៈសម្បត្តិដើម្បីតស៊ូយូរអង្វែង តាមរូបភាពសម្បូរបែប និងឈ្លប។ ៣) កសាងកម្លាំងបង្អែកសេដ្ឋកិច្ចឲ្យខ្លាំងក្លាបំផុត។ រីឯខាងផ្នែកសេដ្ឋកិច្ចគឺបំផុសមាគ៌ាសេដ្ឋកិច្ចរបស់បក្សឲ្យធ្វើឯកជន, បំផុសប្រជាជនឲ្យលួចគោក្របី, មាន់ទា, ជ្រូកលក់ឲ្យវៀតណាម។ ចំពោះផ្នែកវប្បធម៌អូសទាញប្រជាជនឲ្យរៀបការតាមប្រពៃណីចាស់, ហាមមិនឲ្យប្រជាជនវាយរូបចម្លាក់អ្នកតា, លើកទឹកចិត្តប្រជាជនឲ្យស្លៀកសម្លៀកបំពាក់ស៊ីវិល័យ និងច្រៀងបទចម្រៀងឯកជនតាមបទពីដើមដោយមិនឲ្យច្រៀងអំពីសមូហភាព។

ខាងលើនេះគឺជាចម្លើយសារភាពរបស់ សួស ណាន ហៅ ទេព ណន ប្រាប់ទៅកាន់អ្នកសួរចម្លើយស្តីអំពីការរៀបចំសកម្មភាពក្បត់នឹងអង្គការ និងខ្សែបណ្តាញចលនាសេរីរបស់ ឈូក, ចក្រី និង សុផាន ដើម្បីបះបោរធ្វើសង្គ្រាមប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីសេចក្តីកត់ហេតុសួរចម្លើយឯកសារJ00៩២៤។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ សួស ណាន ហៅ ទេព ពន ពិតប៉ុណ្ណាណានោះទេ?***

# សោម ពៅ៖ លេខាសង្កាត់បន្ទាយចក្រី ស្រុកកោះថ្ម័យ តំបន់២៤

ដារ៉ាវដ្ឋ មេត្តា



កងទ័ពខ្មែរក្រហមកំពុងវាយប្រយុទ្ធជាមួយកងទ័ពវៀតណាម នៅតាមបណ្ដោយព្រំដែន។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ សោម ពៅ និងមានឈ្មោះ បដិវត្តន៍ សោម វិន ជនជាតិខ្មែរ ភេទប្រុស អាយុ៣៨ឆ្នាំ។ ខ្ញុំមានទីលំនៅភូមិភ័គក្រលិស (បច្ចុប្បន្នអាចជាភូមិភគ្គនេស្ស) ឃុំត្រកោល (តាកោ) ស្រុកព្រៃវែង (ពោធិ៍រៀង) ខេត្តព្រៃវែង។ ប្រពន្ធរបស់ខ្ញុំឈ្មោះ សំ សឿន ចំណែកឈ្មោះបដិវត្តន៍ ប្អូន សារី រស់នៅភូមិរង្វះមួយរយ បច្ចុប្បន្នភូមិអង្វះមួយរយ ឃុំអន្សោង ស្រុកកំពង់ត្របែក ខេត្តព្រៃវែង។ ប្រពន្ធខ្ញុំធ្វើការនៅក្នុងមន្ទីរកាត់ដេរស្រុក។

ខ្ញុំបួសជាព្រះសង្ឃអស់រយៈពេល៨ឆ្នាំ នៅវត្តស្វាយសុខា ស្ថិតនៅភូមិស្វាយសុខា ឃុំព្រែកខ្លោង ស្រុកព្រៃវែង ខេត្តព្រៃវែង។ បងខ្ញុំឈ្មោះ ម៉ុក គឺជាអ្នកបំបួសខ្ញុំព្រោះគាត់គឺជាសង្រ្គាជវត្តស្វាយសុខា។ ចាប់ពីឆ្នាំ១៩៦១ដល់ឆ្នាំ១៩៦២ ខ្ញុំរៀននៅវត្តស្ទឹងស្លូត ស្ថិតនៅឃុំអ្នកលឿង ស្រុកពាមជរ ខេត្តព្រៃវែង។ ខ្ញុំរៀនភាសាបាលី ជាមួយគ្រូ សុខ សិន(បច្ចុប្បន្ននៅចម្ការកៅស៊ូរដ្ឋ) ចំណែកគ្រូ ព្រំ សម្បត្តិ បង្រៀនចំណោទ និងសរសេរតាមសូត្រ។ នៅពេលនោះ គ្រូ ហាយ អេល ក៏បង្រៀនភាសាបាលីដែរ និងជាសង្រ្គាជវត្ត។ ហាយ អេល មានស្រកកំណើតនៅភូមិពន្លៃ ឃុំបាបោង ស្រុកពាមរក៍ ខេត្តព្រៃវែង។ កាលខ្ញុំនៅរៀនទីនោះមានសិស្សចំនួន២០អង្គ។

មិត្តភក្តិដែលខ្ញុំជិតស្និទ្ធជាមួយមានឈ្មោះ សុខ សិន, កៅ មួន, ព្រំ សម្បត្តិ ហៅ មាន និងមានឈ្មោះក្រៅមួយទៀតគឺ ចក្រី, ស្លូត, រដ្ឋ, មុំ មាន, ម៉េង និង

ណាន នៅស្រុកពាមជរ, ក្រូច, មិ យន (ស្រុកកោះដ័យ), ហាក់ (យោធាភូមិភាគ), ឈួន ប្រធានរងយោធាតំបន់២៤, កង, ស៊ិត គឺជាបញ្ជាការរងតំបន់ ២៤, ប៉ុល, ផុស, សារ៉ន, វ៉ាន់, វ៉ុន គឺជាលេខាយោធាតំបន់២៤។ នៅចុងឆ្នាំ១៩៧៤ ខ្ញុំទទួលបានការអប់រំពីសមមិត្ត ឈូក និងសមមិត្ត ចក្រី ។ ខ្លឹមសារដែលសមមិត្ត ឈូក និយាយអប់រំខ្ញុំគឺ «ឥឡូវនេះយើងចប់សង្គ្រាម ប៉ុន្តែការងារពលកម្មកាន់តែខ្លាំងឡើង ប៉ុណ្ណឹងហើយនៅជីវភាពមិនគ្រប់គ្រាន់ទៀត សុខភាពប្រជាជនកាន់តែចោទ ហេវហត់ឈឺហើយលទ្ធភាពដោះស្រាយមិនចេញ។ បើប្រៀបធៀបជាមួយប្រទេសដទៃទៀត គឺយើងចាញ់គេ និងមិនជឿនលឿនទេ។ យើងត្រូវយកចិត្តទុកដាក់ប្រមូលកៀងគរកម្លាំងឲ្យប្រជាជនខបត្តម្ភយើង ដោយបំបែកកម្លាំងប្រជាជនពីបដិវត្តន៍» ។ ចំណែកខ្លឹមសារដែលសមមិត្ត ចក្រី អប់រំខ្ញុំគឺ «លើកអំពីបញ្ហាប្រៀបធៀបសម័យមុនសង្គ្រាមមានលក្ខណៈខុសគ្នា យើងខ្វះខាតសម្ភារ ស្បៀងអាហារមិនគ្រប់គ្រាន់ ពីសង្គមចាស់មានហូបគ្រប់គ្រាន់។ ចក្រី បានអប់រំខ្ញុំថា «ខំធ្វើសកម្មភាពទៅចាំចប់ចុងចប់ដើមចាំគិតគ្នា»។ ខ្លឹមសារទាំងអស់នេះខ្ញុំបានយកទៅធ្វើការឃោសនាបំផុសបំផុលប្រជាជន ហើយប្រជាជនមួយចំនួនយល់ស្របតាមការឃោសនានេះ។ ខ្ញុំចាត់តាំងកម្លាំងបន្តទៀតមានឈ្មោះ សុខ នី គឺជាសមាជិកទីពីរក្នុងគណៈស្រុកត្របែក, ទេព កេត គឺជាគណៈកសិកម្មស្រុកត្របែក, ចិន ចន គឺជាប្រធានឃុំក្រសោមអក (កន្សោមអក), ហួត សេង គឺជាប្រធានឃុំពាមទារ (ពាមមន្ទារ), ខឹម អ៊ី គឺជាយុជននៅភូមិប៉ុកទាក ឃុំប្រធាតុ, ម៉េត គឺជាយុវជននៅភូមិជ្រួល ឃុំក្រសោមអក (កន្សោមអក) និងឈ្មោះ កៅ មួន។

នៅក្នុងឆ្នាំ១៩៦៦ ខ្ញុំរៀននៅវត្តកំសាន ស្ថិតនៅខាងត្បូងប្សារអំពៅជាប់នឹងទន្លេបាសាក់ដែលមានចម្ងាយ ២០០ទៅ ៣០០ម៉ែត្រពីមាត់ទន្លេត្រើយខាងកើត និងមានគ្រូបង្រៀនឈ្មោះ បូ ។ បន្ទាប់មកខ្ញុំមកនៅភូមិស៊ីងស្លូត ក្នុងឃុំអ្នកលឿង ស្រុកពាមជរ


កងទ័ពខ្មែរក្រហមកំពុងវាយប្រយុទ្ធជាមួយកងទ័ពវៀតណាមនៅសមរភូមិក្នុងស្រុកប្រសូត្រ ខេត្តស្វាយរៀង។ ខែមករា ឆ្នាំ១៩៧៨។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ខេត្តព្រៃវែង វិញ ដោយសារអាចារ្យ ហាយ អេល ឲ្យខ្ញុំជួយបង្រៀនចំណោទ និងសរសេរតាមសូត្រដល់សិស្សថ្នាក់ទី១ ចំនួន២០នាក់។

ខ្ញុំបានចូលបដិវត្តន៍នៅឆ្នាំ១៩៦៧ នៅវត្តស៊ីងស្លូត ភូមិស៊ីងស្លូត ឃុំអ្នកលឿង ស្រុកពាមរក៍ ខេត្តព្រៃវែងដែលអ្នកនាំចូលឈ្មោះ កៅ មុន។ មូលហេតុកៅ មុន អាចអូសទាញខ្ញុំឲ្យចូលបដិវត្តន៍បាន គឺដោយសារគាត់ពន្យល់ខ្ញុំអំពីការដិះជាន់សក្តិភូមិ និងការរំដោះខ្លួន។

នៅក្នុងឆ្នាំ១៩៦៨ ខ្ញុំចេញពីវត្តស៊ីងស្លូតមកវត្តកំរៃង ស្ថិតនៅភូមិកំរៃង ឃុំធាយ ស្រុកបាភ្នំ ខេត្តព្រៃវែង បន្ទាប់មកខ្ញុំសឹកតែម្តង។ តាំងពីខ្ញុំចូលបដិវត្តន៍មកនៅខែឧសភា ឆ្នាំ១៩៦៩ ខ្ញុំទទួលតំណែងជា

លេខាសង្កាត់ នៅបន្ទាយចក្រី នៅស្រុកកោះដ័យ។ ចាប់តាំងពីខែឧសភា ដល់ខែតុលា ឆ្នាំ១៩៦៩ អង្គការឲ្យខ្ញុំទទួលការងារនៅសង្កាត់បឹងដោល។ នៅចន្លោះពីខែតុលា១៩៦៩ ដល់ខែកុម្ភៈ ឆ្នាំ១៩៧០ អង្គការចាត់តាំងខ្ញុំឲ្យទៅរៀននៅសាលាភូមិភាគ។ អភិបាលសាលាភូមិភាគឈ្មោះ សោ យ៉ាន់ និង តាម៉ាប់។ នៅពេលខ្ញុំត្រឡប់មកពីរៀនវិញអង្គការឲ្យខ្ញុំទៅទទួលការងារនៅស្រុកត្របែក ដោយមានតួនាទីជាប្រធានស្រុកត្របែក។ ខ្ញុំចូលបក្សនៅថ្ងៃទី១២ ខែកញ្ញា ឆ្នាំ១៩៧០ ដោយមានអ្នកខ្ទេសនាមគឺ បង ឈូក និង បងដ័យ គឺជាអ្នកទទួលស្គាល់។ ក្រោយមកខ្ញុំបានចាត់តាំង ឈ្មោះ ប៉ុក ស៊ាង នៅសហករណ៍ភូមិពោធិ៍ សង្កាត់ប្រធាតុ,យាវ យុន សង្កាត់អន្សោង, ទុំ ប៊ុច នៅអង្គភាពសន្តិសុខស្រុក, សោ សូវេត នៅមន្ទីរពេទ្យមធ្យម ឲ្យធ្វើសកម្មភាពបំបែកកម្លាំងប្រជាជននិងបដិវត្តន៍, ពង្រីកខាងសីលធម៌ទី៦ (កុំប្រព្រឹត្តអ្វីដែលល្មើសនឹងស្ត្រីភេទឲ្យសោះ) ហើយបង្កើតចោរកម្មឲ្យដើរលួចដើម្បីវាយបដិវត្តន៍។ នៅក្នុងឆ្នាំ១៩៧៥ ខ្ញុំទទួលឋានៈជាកម្មាភិបាលខេត្តព្រៃវែង។

អង្គការបានចាប់ខ្លួនខ្ញុំមកទីនេះ ព្រោះខ្ញុំបានទទួលការអប់រំ និងចាត់តាំងក្បត់ពីសមមិត្ត ឈូក និងសមមិត្តចក្រី។ ខ្ញុំត្រូវយកមកសួរចម្លើយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៧៦។

***កំណត់ចំណាំ៖ អត្ថបទនេះដកស្រង់ចេញពីសេចក្តីកត់ហេតុសួរចម្លើយឯកសារ D១២៧៥។ រាល់ចម្លើយសារភាពរបស់អ្នកទោសទាំងអស់នៅមន្ទីរសន្តិសុខស-២១ សុទ្ធតែឆ្លងកាត់ការបង្ខិតបង្ខំនិងធ្វើទារុណកម្មយ៉ាងធ្ងន់ធ្ងរពីកងសួរចម្លើយរបស់ខ្មែរក្រហម ដូច្នេះយើងមិនអាចសន្និដ្ឋានបានថាចម្លើយសារភាពរបស់ សោម ពៅ ហៅ សោម វិន ពិតប៉ុយ៉ាងណានោះទេ?***



យុទ្ធនារីកងទ័ពបដិវត្តន៍ខ្មែរក្រហមនៅភូមិភាគបូព៌ា រួមជាមួយកងចល័តកំពុងដឹកជញ្ជូនផលស្រូវពីសមរភូមិមុខ យកមកទុកនៅសមរភូមិក្រោយ ។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជាទស្សនកិច្ច "បណ្ណាល័យសម្តេចម៉ែ"

*សុភ័ក្ត្រ ភាណា*



ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល "ធនាគារជាតិនៃកម្ពុជា" ទស្សនកិច្ច "បណ្ណាល័យសម្តេចម៉ែ" នាព្រឹកថ្ងៃសុក្រ ទី ២៥ ខែមីនា ឆ្នាំ ២០២២។ (សុភ័ក្ត្រ ភាណា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល "ធនាគារជាតិនៃកម្ពុជា" អញ្ជើញជាភ្ញៀវកិត្តិយសមកកាន់ "បណ្ណាល័យសម្តេចម៉ែ" នាព្រឹកថ្ងៃសុក្រ ទី២៥ ខែមីនា ឆ្នាំ២០២២ ដើម្បីថ្វាយព្រះរាជកិត្តិយសចំពោះសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរ ព្រមទាំងគាំទ្រចំពោះការបង្កើត "បណ្ណាល័យសម្តេចម៉ែ" របស់មជ្ឈមណ្ឌលឯកសារកម្ពុជា និងអបអរសាទរទិវាប្រាក់រៀល ខួបលើកទី៤២ ។

ប្រាក់រៀលត្រូវបានបោះពុម្ពផ្សាយឡើងវិញដោយធនាគារជាតិនៃកម្ពុជា នាថ្ងៃទី២១ ខែមីនា ឆ្នាំ១៩៨០ ដែលមកទល់សព្វថ្ងៃគឺមានរយៈកាល ៤២ឆ្នាំមកហើយ។ ក្រោយពីការបោះពុម្ពរូបបិយប័ណ្ណឡើងវិញ បន្ទាប់ពីរូបបិយប័ណ្ណកម្ពុជាត្រូវបានលុបបំបាត់ទាំងស្រុងក្នុងរបបខ្មែរក្រហមធនាគារជាតិនៃកម្ពុជា បានស្រាវជ្រាវស្រទេញផ្សព្វផ្សាយ និងបង្កើតជាយុទ្ធនាការចាំបាច់ជាច្រើន ដើម្បីបង្កើនស្ថិរភាពនៃតម្លៃប្រាក់រៀល។

ជានិច្ចកាល ឯកឧត្តមអគ្គទេសាភិបាល ជា ចាន់តូ តែងគាំទ្រយ៉ាងស៊ិតស្វាញចំពោះកិច្ចការសិក្សាស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ចាប់តាំងពីឆ្នាំ១៩៩៥ រហូតមក។ ឯកឧត្តមអគ្គទេសាភិបាល បានគាំទ្រដល់ការបោះពុម្ពសៀវភៅប្រវត្តិសាស្ត្រស្តីពីប្រទេសកម្ពុជា សរសេរឡើងដោយប្រវត្តិវិទូល្បីល្បាញ ជាខេមរភាសា ដែលប្រែសម្រួលពីឯកសារដើមជាភាសាអង់គ្លេស ឬភាសាបារាំង។ សៀវភៅដែលប្រែសម្រួលនិងបោះពុម្ពជាភាសាខ្មែរទាំងនោះ រួមមាន "ប្រវត្តិសាស្ត្រប្រទេសកម្ពុជា" សរសេរឡើងជាភាសាបារាំងក្នុងឆ្នាំ១៩១៤ដោយប្រវត្តិវិទូជនជាតិបារាំង អាដេម៉ារ ឡឺក្លែរ ដែលត្រូវប្រើប្រាស់ជាឯកសារជំនួយដល់កម្មវិធីសិក្សារបស់ក្រសួងអប់រំ យុវជន និងកីឡា និងយ៉ាងទូលំទូលាយនៅក្នុងប្រទេសកម្ពុជា, "សត្រូវបងប្អូនឯង" និពន្ធដោយលោក ណាយ៉ាន់ ចាន់ដា, "របបប៉ុល ពត" ដែលជាស្នាដៃរបស់ប្រវត្តិវិទូជាន់ខ្ពស់និងសាស្ត្រាចារ្យប្រវត្តិសាស្ត្រគឺលោក ប៊ែន គៀរនិន, និង "ជំងឺកម្ពុជា" សរសេរឡើងដោយសង្គមវិទូជនជាតិបារាំង ម៉ារី អា ឡិចសាន់ឌ្រីន ម៉ាទីន និងសៀវភៅសិក្សាជាន់ខ្ពស់ដទៃទៀត។

ក្រោយប្រែសម្រួល សៀវភៅទាំងនេះ ត្រូវបានចុះផ្សាយជាភាគៗ នៅលើកាសែតរស្មីកម្ពុជា ដើម្បីផ្សព្វផ្សាយឲ្យបានទូលំទូលាយ និងជាជំនួយដល់មិត្តអ្នកអានទូទៅ។ សៀវភៅខាងលើបានចូលរួមចំណែកយ៉ាងសកម្មក្នុងការលើកស្ទួយការសិក្សាស្រាវជ្រាវរបស់សិស្សានុសិស្ស និងអ្នកស្រាវជ្រាវជនជាតិខ្មែរឲ្យបានយល់ដឹងថាតើអ្នកស្រាវជ្រាវបរទេសគិតយ៉ាងដូចម្តេចចំពោះប្រវត្តិសាស្ត្រខ្មែរ និងជាមូលដ្ឋានគ្រឹះដ៏ចាំបាច់សម្រាប់យុវជនជំនាន់ក្រោយសិក្សាស្រាវជ្រាវ និងសរសេរប្រវត្តិសាស្ត្រកម្ពុជាដោយខ្លួនឯង។ បច្ចុប្បន្ន ឯកឧត្តមអគ្គទេសាភិបាល បាននិងកំពុងរៀបចំ និងបោះពុម្ពសាឡើងវិញជាភាសាខ្មែរនូវសៀវភៅ "របបប៉ុល ពត" របស់លោក ប៊ែន គៀរនិន សាស្ត្រាចារ្យសាកលវិទ្យាល័យយ៉ែល។

ក្រៅពីគាំទ្រដល់ការបោះពុម្ពសៀវភៅប្រវត្តិសាស្ត្រជាភាសាខ្មែរ ឯកឧត្តមអគ្គទេសាភិបាល បានគាំទ្រដល់ការផលិតជាខ្សែភាពយន្តឯកសារ "កុំស្មានបងភ្លេច" ដែលស្តីពីប្រវត្តិតន្ត្រីខ្មែរនៅមុនសម័យសង្គ្រាម ក្នុងអំឡុងសម័យកលយុគ និងនាសម័យបច្ចុប្បន្ន។

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា បានទទួលស្វាគមន៍ និងបង្ហាញជូនដល់ប្រតិភូកិត្តិយសនូវសមិទ្ធផលនៃបណ្ណាល័យសម្តេចម៉ែ និងមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងរំលេចគោលបំណងសំខាន់ក្នុងការសាងសង់ទីតាំងអចិន្ត្រៃយ៍មួយគឺវិទ្យាស្ថានស្លឹករឹត។ គួររំឭកថាវិទ្យាស្ថានស្លឹករឹតបានទទួលការសព្វព្រះរាជហឫទ័យ និងការគាំទ្រក្រៃលែងពីសម្តេចព្រះវររាជមាតាជាតិខ្មែរ និងមន្ត្រីរាជរដ្ឋាភិបាលកម្ពុជាជាច្រើន ព្រមទាំងនៅក្នុងជួរកងទ័ព និងប្រជាជនកម្ពុជាទូទៅជាច្រើនទៀតផង ជាពិសេសនៅក្នុងវិស័យស្ថាបត្យកម្មទំនើបរបស់កម្ពុជា។ វិទ្យាស្ថានស្លឹករឹត គឺជាស្នាដៃល្អឯករបស់ស្ថាបត្យករស្ត្រី ល្បីល្បាញកម្រិតពិភពលោក គឺ លោកស្រី ហ្សាហា ហាឌីត ដែលប្លង់នៃស្នាដៃប្រណិតនេះ ត្រូវបានតាំងបង្ហាញជាផ្នែកមួយនៃពិព័រណ៍អចិន្ត្រៃយ៍របស់ "បណ្ណាល័យសម្តេចម៉ែ"។



ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល "ធនាគារជាតិនៃកម្ពុជា" និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅ "បណ្ណាល័យសម្តេចម៉ែ" នៅព្រឹកថ្ងៃសុក្រ ទី២៥ ខែមីនា ឆ្នាំ២០២២។
(សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)



ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល "ធនាគារជាតិនៃកម្ពុជា" និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅ "បណ្ណាល័យសម្ដេចម៉ែ" នៅព្រឹកថ្ងៃសុក្រ ទី២៥ ខែមីនា ឆ្នាំ២០២២។
(សុភ័ក្ត្រ ភាណា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល "ធនាគារជាតិនៃកម្ពុជា" នៅ "បណ្ណាល័យសម្ដេចម៉ែ" នៅព្រឹកថ្ងៃសុក្រ ទី២៥ ខែមីនា ឆ្នាំ២០២២។
(សុភ័ក្ត្រ ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

បណ្ណាល័យថ្វីត្បិតតែមានទំហំតូច ប៉ុន្តែយុគសម័យបច្ចេកវិទ្យាទំនើប យើងអាចប្រើប្រាស់ធនធានរបស់បណ្ណាល័យនេះ ដើម្បីផ្សព្វផ្សាយព័ត៌មានដែលមានរាប់លានឯកសារទៅដល់អ្នកសិក្សាស្រាវជ្រាវជាតិ និងអន្តរជាតិ។ ក្នុងអំឡុងទស្សនកិច្ច ប្រតិភូកិត្តិយស បានទទួលជ្រាបអំពីដំណើរការនៃការថែរក្សាឯកសារប្រវត្តិសាស្ត្រ និងទស្សនាសមុច្ច័យដ៏កម្រដែលមានតាំងបង្ហាញនៅក្នុងបណ្ណាល័យសម្ដេចម៉ែថែមទៀតផង។ លោកឯកអគ្គរាជទូតបណ្ឌិត ហ្វូលីយ៉ូ អេ. ហែលជ្រេស បានបង្ហាញអំពីសៀវភៅ «សាក្សីប្រវត្តិសាស្ត្រ» ដែលលោកបានប្រែសម្រួលជាភាសាអង់គ្លេស ពីសំណៅដើមនៃកំណត់ហេតុជាភាសាបារាំងរបស់សម្ដេចព្រះវររាជមាតាជាតិខ្មែរ កត់ត្រាព្រះរាជដំណើររបស់ព្រះអង្គ និងសម្ដេចព្រះបរមរតនកោដ្ឋមកកាន់តំបន់រំដោះក្នុងប្រទេសកម្ពុជានាឆ្នាំ១៩៧៣។ បច្ចុប្បន្នមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងរៀបចំប្រែសម្រួលសៀវភៅនេះជាភាសាខ្មែរ។

ជាចុងក្រោយ ឯកឧត្តមអគ្គទេសាភិបាល ជា ចាន់តូ បានសម្ដែងនូវអំណរគុណចំពោះការទទួលស្វាគមន៍ដ៏រាក់ទាក់ និងបានចារចំណារអនុស្សាវរីយ៍នៅលើសៀវភៅក្រាំងមាសនៃ"បណ្ណាល័យសម្ដេចម៉ែ" ដែលមានសេចក្ដីដូចតទៅ៖





ឯកឧត្តម ជា ចាន់តូ អគ្គទេសាភិបាល "ធនាគារជាតិនៃកម្ពុជា" និងឯកអគ្គរាជទូត បណ្ឌិត ហូលីយ៉ូ អេ.ហែលជ្រេស អតីតលេខាផ្ទាល់សម្តេចព្រះបរមរតនកោដ្ឋ សម្តេចព្រះនរោត្តម សីហនុ នៅ "បណ្ណាល័យសម្តេចម៉ែ" នៅព្រឹកថ្ងៃសុក្រ ទី២៥ ខែមីនា ឆ្នាំ២០២២។
(សុភ័ត្រ្ត ភាណា/បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**តាងនាមថ្នាក់ដឹកនាំ ធនាគារជាតិនៃកម្ពុជា ខ្ញុំសូមអរគុណចំពោះការទទួលបដិសណ្ឋារកិច្ច ប្រកបដោយមនោសញ្ចេតនា ភាតរៈ របស់លោកនាយក ទន្ទឹមនឹងនេះ ខ្ញុំសូមកោតសរសើរនូវស្នាដៃរៀបចំ ថែរក្សាឯកសារដ៏មានតម្លៃនេះ ដើម្បីទុកឱ្យយុវជនជំនាន់ក្រោយបានសិក្សារៀនសូត្រ។**

**សូមប្រសិទ្ធិពរឱ្យមានសុខភាពល្អ និងជ័យជម្នះ។**

*ភ្នំពេញថ្ងៃទី ២៥ មីនា ២០២២*

**ជា ចាន់តូ**



គណៈប្រតិភូបានថតរូបជុំគ្នានៅ "បណ្ណាល័យសម្តេចម៉ែ" នៅព្រឹកថ្ងៃសុក្រ ទី២៥ ខែមីនា ឆ្នាំ២០២២។
(សុភ័ត្រ្ត ភាណា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឯកអគ្គរដ្ឋទូតសិង្ហបុរីទស្សនកិច្ចតំបន់អន្លង់វែង

រមែក ទិន



លោកជំទាវ គ្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅសារមន្ទីរផ្ទះ តាម៉ុក។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២ លោកជំទាវ គ្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញមកធ្វើទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនៃស្រុកអន្លង់វែងជាទីដែលសង្គ្រាមត្រូវបានបញ្ចប់ និងសន្តិភាពចាប់ផ្តើមកើតមានឡើងវិញ។ លោកជំទាវឯកអគ្គរដ្ឋទូតបានក្លាយទៅជាអ្នកការទូតទីពីរនៃបណ្តាប្រទេសអាស៊ានដែលបានអញ្ជើញមកដល់តំបន់អន្លង់វែង ខណៈដែលប្រទេសកម្ពុជាកំពុងធ្វើជាប្រធានប្តូរវេនរបស់អាស៊ាន។

នៅវេលាម៉ោង៨:០០នាទីព្រឹក លោកជំទាវឯកអគ្គរដ្ឋទូតបានមកដល់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ដោយទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។ នៅក្នុងដំណើរទស្សនកិច្ចនេះ លោកជំទាវ



លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង នៅសារមន្ទីរផ្ទះ តាម៉ុក។
ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញមកធ្វើទស្សនកិច្ចមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង និងតំបន់ទេសចរណ៍ប្រវត្តិសាស្ត្រនៃស្រុកអន្លង់វែង ដោយទទួលបានការស្វាគមន៍យ៉ាងកក់ក្ដៅពី លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងបណ្ឌិត លី សុខឃាង នាយកមជ្ឈមណ្ឌលសន្តិភាពអន្លង់វែង។
ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

មានគោលបំណងស្វែងយល់ពីតំបន់ប្រវត្តិសាស្ត្រអន្លង់វែងដែលជាទីតាំងតស៊ូចុងក្រោយរបស់ចលនាខ្មែរក្រហម។ ស្រុកអន្លង់វែង មានទីតាំងប្រវត្តិសាស្ត្រចំនួន១៤កន្លែងដែលបម្រើឲ្យគោលដៅទេសចរណ៍ជាតិ និងអន្តរជាតិ។

នៅក្នុងឱកាសនៃដំណើរទស្សនកិច្ចរបស់លោកជំទាវអគ្គរដ្ឋទូតនេះ បណ្ឌិត លី សុខឃាង ក៏បានបង្ហាញអំពីកិច្ចការងារមួយចំនួនទាក់ទងនឹងការបង្កើតវេទិកាថ្នាក់រៀនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

បន្ទាប់មក លោកជំទាវឯកអគ្គរដ្ឋទូត បានធ្វើដំណើរឆ្ពោះទៅកាន់អតីតផ្ទះ ប៉ុល ពត និង ខៀវ សំផន, អតីតផ្ទះប្រជុំរបស់ តាម៉ុក នៅលើភ្នំដងរែក និងសារមន្ទីរផ្ទះ តាម៉ុក។ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសាកម្ពុជា បានរៀបរាប់យ៉ាងក្បោះក្បាយអំពីទីតាំងប្រវត្តិសាស្ត្រនីមួយៗ និងបានផ្ដោតការពិភាក្សាអំពីពាក្យ «សន្តិភាព» ដែលប្រទេសកម្ពុជាបានទទួលនាពេលបច្ចុប្បន្ន។

ឧត្តមសេនីយ៍ត្រី និត ណារ៉ុង ក៏បានចូលរួមធ្វើអត្ថាធិប្បាយអំពីរឿងរ៉ាវប្រវត្តិសាស្ត្រនៃការធ្វើសង្គ្រាមនៅ

តំបន់អន្លង់វែង និងការសម្រេចបាននូវសន្តិភាពក្រោមគោលនយោបាយ ឈ្នះ ឈ្នះរបស់រាជរដ្ឋាភិបាលកម្ពុជា។ បច្ចុប្បន្ននេះ អន្លង់វែងចាប់ផ្តើមបោះជំហានទៅរកការប្រែមុខមាត់ថ្មីតាមរយៈការសាងសង់«ស្តូប ឈ្នះ ឈ្នះ អន្លង់វែង»។ មុនពេលវិលត្រឡប់មកវិញ លោកជំទាវ ឯកអគ្គរដ្ឋទូត ត្យូ ឡេឆេង សម្តែងនូវការកោតសរសើរចំពោះដំណើរទស្សនកិច្ចសិក្សាស្វែងយល់អំពីសង្គ្រាម និងសន្តិភាពនៅប្រទេសកម្ពុជា ព្រមទាំងបេសកកម្មរបស់មជ្ឈមណ្ឌលសន្តិភាពអន្លង់វែង ក្នុងការអប់រំយុវជនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។



លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបូរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅពើយ តាម៉ុក។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបូរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា នៅកន្លែងលាក់ខ្លួនរបស់ ប៉ុល ពត នៅក្បាលទន្សោង។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបូរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅកន្លែងលាក់ខ្លួនរបស់ ប៉ុល ពត នៅក្បាលទន្សោង។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)





លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅរូងលាក់ខ្លួនរបស់ ប៉ុល ពត នៅក្បាលទន្សោង។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



លោកជំទាវ ត្យូ ឡេឆេង ឯកអគ្គរដ្ឋទូតសិង្ហបុរីប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ទស្សនកិច្ចទីតាំងបូជាសព ប៉ុល ពត នៅលើភ្នំដងរែក។ ថ្ងៃទី២៩ ខែមីនា ឆ្នាំ២០២២។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ដំណើរទស្សនកិច្ចរួមគ្នារបស់ឯកអគ្គរាជទូតអង់គ្លេស និងឯកអគ្គរដ្ឋទូតឥណ្ឌា

## មកកាន់បណ្ណាល័យសម្តេចម៉ែ

**ដារ៉ារដ្ឋ មេត្តា**



លោកជំទាវវេជ្ជបណ្ឌិត ដេវយ៉ានី ខុប្រាហ្គីដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា, យុវតី លេខ ការី មានតួនាទីជាអ្នកដើរតួនាទីជំនួសលោកជំទាវវេជ្ជបណ្ឌិត ដេវយ៉ានី ខុប្រាហ្គីដេ របស់ឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោកស្រី សូ ហារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា នៅបណ្ណាល័យ «សម្តេចម៉ែ»។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ដារ៉ារដ្ឋ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ លោកជំទាវ ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវវេជ្ជបណ្ឌិត ដេវយ៉ានី ខុប្រាហ្គីដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា រួមជាមួយ យុវតី ហៀង ហ្គិច លីម មានតួនាទីជាអ្នកដើរតួនាទីជំនួសលោកជំទាវ ធីណា រ៉េដស របស់អង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង យុវតី លេខ ការី មានតួនាទីជាអ្នកដើរតួនាទីជំនួសលោកជំទាវវេជ្ជបណ្ឌិត ដេវយ៉ានី ខុប្រាហ្គីដេ របស់ឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា អញ្ជើញមកធ្វើទស្សនកិច្ចរួមគ្នានៅបណ្ណាល័យសម្តេចម៉ែ។

ស្ថានទូតអង់គ្លេសបានចាប់ផ្តើមការប្រកួតប្រជែង «ឯកអគ្គរាជទូតមួយថ្ងៃ» ដើម្បីស្នើឲ្យបេក្ខជនជាស្ត្រីវ័យក្មេងចូលរួមផលិតវីដេអូផ្ទាល់ខ្លួនក្នុងគោលបំណងពិភាក្សា និងលើកកម្ពស់ការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចដល់ស្ត្រី និងកុមារ, ផ្តល់ឱកាស

ឲ្យសម្រេចបានការងារក្នុងក្តីស្រមៃរបស់ខ្លួននៅឆ្នាំ ២០៣០។ យុវតី ហឿន ហ្គិច លីម គឺជាអ្នកឈ្នះនៅក្នុងកម្មវិធីប្រកួតប្រជែងនេះ ដែលនឹងចំណាយពេលមួយថ្ងៃជាមួយឯកអគ្គរាជទូតអង់គ្លេស ធីណា រ៉េដស នៅក្នុងព្រឹត្តិការណ៍ណាមួយ នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ ២០២២ នេះ។ ស្ថានទូតឥណ្ឌា ក៏មានយុវតី លេខការី ដែលជាអ្នកឈ្នះក្នុងការប្រកួតប្រជែង «ឯកអគ្គរាជទូតមួយថ្ងៃ» នេះដែរ ទោះបីដំណើរការជ្រើសរើសអ្នកឈ្នះខុសពីគ្នាក៏ដោយ។

ឯកអគ្គរដ្ឋទូតទាំងពីរូបដែលជាប់ក្នុងការប្រកួតប្រជែង «ឯកអគ្គរាជទូតមួយថ្ងៃ» បានមកធ្វើទស្សនកិច្ចរួមគ្នានៅបណ្ណាល័យ «សម្តេចម៉ែ» នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ នេះ។ វាគឺជាព្រឹត្តិការណ៍រួមគ្នាលើកទីមួយអំពីប្រធានបទនេះ របស់ស្ថានទូតអង់គ្លេស និងស្ថានទូតឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា។

គណៈប្រតិភូ អញ្ជើញមកដល់បណ្ណាល័យសម្តេចម៉ែនៅវេលាម៉ោង៩:០០ព្រឹក ដោយមានការទទួលស្វាគមន៍យ៉ាងកក់ក្តៅពីអ្នកស្រី សូ ហ្សារីណា នាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកស្រី សូ ហ្សារីណា ធ្វើការណែនាំនិងបង្ហាញអំពីប្លង់អគារស្លឹករឹតដែលកំពុងដាក់តាំងបង្ហាញនៅច្រកចូលបណ្ណាល័យ «សម្តេចម៉ែ»។ ប្លង់រចនាអគារស្លឹករឹតនេះ គឺជាស្នាដៃរបស់ស្ថាបត្យករកម្រិតពិភពលោក គឺលោកស្រី ហ្សាហា ហាឌីដ ដែលមានភាពខុសប្លែកពីអគារបែបអភិរក្សនៃសំណង់ស្ថាបត្យកម្ម ដោយបម្រើនាទីជាបូជនីយដ្ឋានរំឭកអំពីអំពើប្រល័យពូជសាសន៍។ អគារស្លឹករឹត ក៏ជាទីតាំងអចិន្ត្រៃយ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជានៅក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា ដើម្បីរំឭក និងខ្ទីសដល់វិញ្ញាណក្ខន្ធជនរងគ្រោះដែលបានបាត់បង់ជីវិតប្រមាណ ២ លាននាក់ ក្នុងអំឡុងរបបប្រល័យពូជសាសន៍ខ្មែរក្រហមពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

នៅក្នុងឱកាសនៃដំណើរទស្សនកិច្ចនេះ អ្នកស្រី សូ ហ្សារីណា បង្ហាញសៀវភៅកំណត់ហេតុដ៏គួរឲ្យចាប់អារម្មណ៍របស់ព្រះមហាក្សត្រីនរោត្តមមុនិនាថសីហនុ ព្រះវររាជមាតាជាតិខ្មែរ ដែលមានចំណងជើងថា «ព្រះរាជដំណើររបស់សម្តេចព្រះមហាក្សត្រី នរោត្តមមុនិនាថ សីហនុយាងទៅកាន់តំបន់រំដោះ នៃរណសិរ្សរួមជាតិកម្ពុជា ក្នុងឆ្នាំ១៩៧៣ ដល់គណៈប្រតិភូ។

ជាកិច្ចបន្ត លោកស្រី សូ ហ្សារីណា ដឹកនាំគណៈប្រតិភូទៅទស្សនាបន្ទប់រក្សាទុកឯកសារនៅបណ្ណាល័យ «សម្តេចម៉ែ» ដែលរួមមាន សៀវភៅរាប់ពាន់ក្បាល, ឯកសាររាប់លានទំព័រ, ឯកសារសំណៅដើម, បណ្ណសារជារូបថត និងវីដេអូ, បណ្ណសារសោតទស្សន៍ និង



លោកជំទាវ ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និងលោកជំទាវវេជ្ជបណ្ឌិត ដេវ៉្យានី ខុប្រាហ្គី ដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា មកទស្សនកិច្ចនៅបណ្ណាល័យសម្តេចម៉ែ ដោយមានការទទួលស្វាគមន៍ពីលោកស្រី សូ ហ្សារីណា នាយករងមជ្ឈមណ្ឌលឯកសារកម្ពុជា។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ ( ដាត ចាន់សុនិតា/ មជ្ឈមណ្ឌលឯកសារកម្ពុជា )

*បរិក្ខារផ្ទុកឯកសារជាទម្រង់ឌីជីថល។ លោកស្រី សូ ហ្សារីណា ក៏បានលើកឡើងអំពីសាខារបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលមាននៅតាមបណ្ដាខេត្តមួយចំនួន ដូចជា ខេត្តឧត្តរមានជ័យ, ព្រៃវែង, កំពង់ចាម, ត្បូងឃ្មុំ, តាកែវ និងពោធិ៍សាត់ដើម្បីបម្រើដល់ការស្រាវជ្រាវរបស់សាធារណជន។*

*លោកជិទាវឯកអគ្គរាជទូតអង់គ្លេស និងឯកអគ្គរដ្ឋទូតឥណ្ឌា បានសរសើរអំពីតួនាទីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា ក៏ដូចជាបណ្ណាល័យសម្ដេចម៉ែ ក្នុងការថែរក្សាឯកសារទុកសម្រាប់សាធារណជន និងបានរួមចំណែកផ្ដល់ឯកសារដល់សាលាក្ដីខ្មែរក្រហម ដើម្បីស្វែងរកយុត្តិធម៌ជូនជនរងគ្រោះ ព្រមទាំងបានធ្វើការអប់រំអំពីរបបខ្មែរក្រហមដល់សិស្សានុសិស្ស និងយុវជនជំនាន់ក្រោយ។*

*ជាចុងក្រោយ គណៈប្រតិភូបានចំណាររនៅលើសៀវភៅក្រាំងមាសរបស់បណ្ណាល័យ «សម្ដេចម៉ែ» ដែលមានខ្លឹមសារ ដូចតទៅ ៖*

**«នេះគឺជាលើកទីមួយសម្រាប់ខ្ញុំដែលបានមកទស្សនកិច្ចនៅបណ្ណាល័យ «សម្ដេចម៉ែ»។ ខ្ញុំពិតជាមានសេចក្ដីរីករាយ សោមនស្សយ៉ាងក្រៃលែងនៅពេលដែលបានស្ដាប់នូវវីរភាពដ៏អង់អាចក្លាហានរបស់សម្ដេចម៉ែ។ ប៉ុន្តែ ខ្ញុំហាក់ដូចជាមានអារម្មណ៍កម្សត់នៅពេលបានស្ដាប់អំពីរបបប្រល័យពូជសាសន៍ខ្មែរក្រហម។ ខ្ញុំនឹងចងចាំនូវអនុស្សាវរីយ៍នៅថ្ងៃនេះហើយចែករំលែកឱ្យសហគមន៍ខ្ញុំបានដឹង»។**

— *យុវតី* **លេខ ការី** *មកពីខេត្តរតនគិរី*

**«ខ្ញុំពិតជាបានឃើញផ្ទាល់ភ្នែករបស់ខ្ញុំ។ វាគួរតែជាទីកន្លែងដែលអ្នកត្រូវតែមកទស្សនាម្ដងក្នុងមួយជីវិតរបស់អ្នក។ ខ្ញុំបានស្ដាប់នូវប្រវត្តិសាស្ត្ររបស់ជាតិខ្ញុំ»។**

— *យុវតី* **ហឿង ហ្គិច លីម** *មកពីទីក្រុងភ្នំពេញ*



*គណៈប្រតិភូកំពុងស្ដាប់លោកស្រី សូ ហ្សារីណា រៀបរាប់អំពីឯកសារដែលតម្កល់នៅបណ្ណាល័យ «សម្ដេចម៉ែ»។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*យុវតី លេខ ការី មានតួនាទីជាអ្នកដើរតួនាទីជំនួសលោកជំទាវវេជ្ជបណ្ឌិត ដេវ៉ារានី ឧប្រាហ្គីដេ របស់ឥណ្ឌា ប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ទស្សនកិច្ចបណ្ណាល័យសម្ដេចម៉ែ។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*





*លោកជំទាវ ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា និង លោកជំទាវវេជ្ជបណ្ឌិត ដេវ៉ី ខុប្រាហ្គីដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា កំពុងទស្សនាគំនូរ ដែលជាស្នាដៃរបស់វិចិត្រករ ញឹក ឌឹម នៅបណ្ណាល័យ «សម្តេចម៉ែ»។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*លោកជំទាវ ធីណា រ៉េដស ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា នៅបណ្ណាល័យ «សម្តេចម៉ែ» កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ដារ៉ារដ្ឋ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*



*យុវតី ហឿង ហ្គិច លីម មានតួនាទីជាអ្នកដើរតួនាទីជំនួសលោកជំទាវ ធីណា រ៉េដស របស់អង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា ទស្សនកិច្ចបណ្ណាល័យ «សម្តេចម៉ែ»។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

**«ជាចុងក្រោយយើងបានរៀបចំគម្រោងមកទស្សកិច្ចនៅកន្លែងដ៏វិសេសវិសាលមួយនេះ។ អរគុណដែលបាននាំយើងដើរទស្សនាបណ្ណាល័យ «សម្តេចម៉ែ»។ អគារដ៏ស្រស់ស្អាត និងការងារដ៏មានសារសំខាន់។ ទាំងនេះគឺជាកិច្ចការងារដ៏ល្អប្រសើរនៃគំនិតផ្តួចផ្តើមរបស់ «ឯកអគ្គរដ្ឋទូតមួយថ្ងៃ»។**

— *លោកជំទាវ* **ធីណា រ៉េដស**

*ឯកអគ្គរាជទូតអង់គ្លេសប្រចាំនៅព្រះរាជាណាចក្រកម្ពុជា*



*លោកជំទាវវេជ្ជបណ្ឌិត ដេវីយ៉ានី ខុប្រាហ្គីដេ ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំនៅព្រះរាជាណាចក្រកម្ពុជា មកទស្សនកិច្ចបណ្ណាល័យ «សម្ដេចម៉ែ» កំពុងចារលើសៀវភៅក្រាំងមាស។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ដារ៉ារដ្ឋ មេត្តា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

«អរគុណសម្រាប់ដំណើរទស្សនកិច្ចដ៏អស្ចារ្យ និងអាហារពេលព្រឹកដែលរៀបចំសម្រាប់ខ្ញុំ និងសម្រាប់ «ឯកអគ្គរដ្ឋទូតមួយថ្ងៃ» របស់ខ្ញុំក្នុងកិត្តិយសខែប្រវត្តិសាស្ត្រសម្រាប់ស្ត្រី នៅខែមីនា ឆ្នាំ២០២២។ ខ្ញុំសូមអរគុណដល់បណ្ណាល័យ «សម្ដេចម៉ែ», ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ និង មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលសម្រេចបានការងារដ៏សំខាន់បំផុតក្នុងការថែរក្សាប្រវត្តិសាស្ត្រសម្រាប់យុវជន និង សហគមន៍។ សូមចូលរួមអបអរសាទរ និងការសម្រេចបាននូវស្នាដៃ និងការបង្កើតកន្លែងដ៏ស្រស់ស្អាតជាមួយសិល្បៈ គឺបណ្ណាល័យ «សម្ដេចម៉ែ» ។

— *លោកជំទាវវេជ្ជបណ្ឌិត* **ដេវីយ៉ានី ខុប្រាហ្គីដេ**
*ឯកអគ្គរដ្ឋទូតឥណ្ឌាប្រចាំព្រះរាជាណាចក្រកម្ពុជា*



*គណៈប្រតិភូកំពុងស្ដាប់លោកស្រី សូ ហារីណា រៀបរាប់អំពីឯកសារដែលតម្កល់នៅបណ្ណាល័យ «សម្ដេចម៉ែ»។ ថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២។ (ផាត ចាន់សុនិតា/មជ្ឈមណ្ឌលឯកសារកម្ពុជា)*

# កិច្ចប្រជុំរវាងមជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងអាជ្ញាធរមូលដ្ឋានក្នុងឃុំលាយបូរស្ដីអំពីគម្រោងសុខភាព និងប្រវត្តិសាស្ត្រ

*សៀង កញ្ញា*




អាជ្ញាធរឃុំលាយបូរទទួលប្រអប់អនុស្សាវរីយ៍ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

លោក លី កុកឆាយ នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ធ្វើបទបង្ហាញទាក់ទងនឹងសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅកាន់អាជ្ញាធរឃុំលាយបូរ។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



នៅថ្ងៃសុក្រ ៩កើត ខែផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ពុទ្ធសករាជ ២៥៦៥ ត្រូវនឹងថ្ងៃទី១១ ខែមីនា ឆ្នាំ ២០២២ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ចំនួន៥នាក់បានចុះទៅសាលាឃុំលាយបូរ ក្នុងស្រុកត្រាំកក់ ខេត្តតាកែវ ដើម្បីជួបប្រជុំជាមួយអាជ្ញាធរមូលដ្ឋាន។ គោលបំណងនៃការចុះទៅជួបអាជ្ញាធរនេះ ដើម្បីជម្រាបជូននូវព័ត៌មាន និងស្នើសុំឲ្យអាជ្ញាធរមូលដ្ឋានចូលរួមសហការក្នុងការផ្សព្វផ្សាយគម្រោងស្ដីអំពី «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវក៏បានស្នើសុំអាជ្ញាធរមូលដ្ឋានឲ្យជួយប្រកាសស្វែងរកអ្នកស្ម័គ្រចិត្តកម្ពុជាជំនាន់ទី៨ចំនួន២០នាក់ ដើម្បីធ្វើការចុះជួប និងស្ដាប់សាច់រឿងរបស់អ្នករស់រានមានជីវិតកាលពីរបបខ្មែរក្រហមក្នុងភូមិឃុំដែលអ្នកស្ម័គ្រចិត្តកំពុងរស់នៅ និងធ្វើការផ្ដល់ព័ត៌មានស្ដីអំពីការទៅពិនិត្យសុខភាព និងជូនអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទៅពិនិត្យសុខភាព។

មូលហេតុដែលក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ សម្រេចចិត្តជ្រើសយកឃុំលាយបូរជា

ទីកន្លែងសម្រាប់អ្នកស្ម័គ្រចិត្តចុះទៅធ្វើការគឺដោយសារឃុំនេះមានទីតាំងនៅជិតទីរួមខេត្តតាកែវ ដែលផ្តល់ភាពងាយស្រួលដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមទៅពិនិត្យសុខភាពនៅមន្ទីរពេទ្យរក្សាសុខតាកែវ។

កម្មវិធីនៃអង្គប្រជុំ មានដូចខាងក្រោម៖



លោក លី កុកឆាយ នាយកមជ្ឈមណ្ឌលឯកសារខេត្តតាកែវ និងក្រុមការងារកំពុងបង្ហាញសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅកាន់អាជ្ញាធរឃុំលាយបូរ។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)

កិច្ចពិភាក្សារបស់ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ ជាមួយអាជ្ញាធរឃុំលាយបូរ។ (ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា)



**នៅវេលាម៉ោង ៨:០០ ដល់ ៨:៣០ នាទីព្រឹក**

មានការជួបជុំ និងការស្វាគមន៍ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវពីអាជ្ញាធរនៅក្នុងឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

**នៅវេលាម៉ោង ៨:៣០ ដល់ ៩:១០នាទីព្រឹក**

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវបានចែកឯកសារទាក់ទងនឹងគម្រោងទៅដល់អ្នកដែលបានចូលរួមប្រជុំ និងធ្វើបទបង្ហាញអំពីគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម»។

គម្រោងសុខភាពនេះបង្កើតឡើងក្នុងគោលបំណង គឺ ទី១) ធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទៅតាមគោលដៅដែលបានកំណត់ ទី២) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និង ទី៣) ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេសនៅតាមសហគមន៍ដាច់ស្រយាល សម្រាប់ផ្តល់ជាព័ត៌មាន ក្នុងការរៀបចំជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់ប្រជាជន និងសហគមន៍ទាំងនេះ។ តាមរយៈគោលបំណងនៃគម្រោងសុខភាពខាងលើ នឹងផ្តល់ឱកាសដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម នៅក្នុងខេត្តតាកែវ និងខេត្តផ្សេងទៀតទូទាំងប្រទេសកម្ពុជាបានទៅពិនិត្យសុខភាពដោយឥតគិតថ្លៃនៅមន្ទីរសម្រាកព្យាបាលឯកជន ដែលជាដៃគូចុះកិច្ចសន្យាជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា។

**នៅវេលាម៉ោង៩:១០ ដល់ ៩:៤០នាទី**

ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ លើកឡើងអំពីការជ្រើសរើសអ្នកស្ម័គ្រចិត្តជំនាន់ទី៤នៅក្នុងឃុំលាយបូរ ស្រុកត្រាំកក់ ខេត្តតាកែវ។

***នៅវេលាម៉ោង៩:៤០ ដល់ ១០:០០នាទី***

*មជ្ឈមណ្ឌលឯកសារខេត្តតាកែវបានចែកប្រអប់អនុ-ស្សាវរីយ៍ដល់អាជ្ញាធរមូលដ្ឋានទាំងអស់ដែលបានចូលរួមប្រជុំ និងបានថតរូបជុំគ្នា។*

*ក្រោយពីបញ្ចប់ការប្រជុំ មេឃុំ ជំទប់ទី១ ជំទប់ទី២ ក្រុមប្រឹក្សាឃុំ ស្មៀនឃុំ ជំនួយការរដ្ឋបាលឃុំ និងមេភូមិ ទាំង២៥រូបក្នុងឃុំលាយបូរ បានសម្តែងការពេញចិត្តគម្រោងសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ព្រោះបច្ចុប្បន្ននៅក្នុងឃុំលាយបូរ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមជាច្រើនកំពុងប្រឈមបញ្ហាសុខភាព និងគ្មានលទ្ធភាពទៅពិនិត្យជំងឺ។*




*ក្រុងការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវនិងអាជ្ញាធរឃុំលាយបូរ ថតរូបជុំគ្នា។*
*( ង៉ាន់ វីន/មជ្ឈមណ្ឌលឯកសារកម្ពុជា )*

# ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម

## ជួបប្រធានឃុំជាំដើម្បីពិភាក្សាលើគម្រោងការងារសុខភាព និងវេទិកាប្រវត្តិសាស្ត្រគ្រួសារ

*ឡុង ដានី*



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម រួមមាន ឡុង ដានី សុខ វណ្ណៈ គាត ស្រីឡែន និង ឈុំ រ៉ា ជួបជាមួយលោក មើក នូវ មេឃុំជាំ។ (ឈុំ រ៉ា/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅព្រឹកថ្ងៃទី២២ ខែមីនា ឆ្នាំ២០២២ ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្ម រួមមាន ឡុង ដានី, សុខ វណ្ណៈ, គាត ស្រីឡែន និង ឈុំ រ៉ា បានចុះទៅធ្វើការងារនៅឃុំជាំ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ។ នៅវេលាម៉ោង៩៖៣០ នាទីព្រឹកថ្ងៃដដែល ក្រុមការងារបានមកដល់សាលាឃុំជាំ និងជួបជាមួយលោកមេឃុំជាំឈ្មោះ មើក នូវ និងជំនួយការរដ្ឋបាលឃុំឈ្មោះ ខា សារឿន។ បន្ទាប់ពីបានណែនាំខ្លួន និងបង្ហាញលិខិតអំពីការបង្កើតមជ្ឈមណ្ឌលឯកសារកោះថ្មដល់លោកមេឃុំ មើក នូវ រួចមក ឡុង ដានី បានធ្វើបទបង្ហាញអំពីគម្រោងនៃការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើងនូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម (១៩៧៥-១៩៧៩)។ គម្រោងសុខភាពនេះមានគោលបំណងដូចខាងក្រោម៖

១) ដើម្បីធ្វើឲ្យប្រសើរឡើងស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទៅតាមគោលដៅដែលបានកំណត់អាយុចាប់ពី៥០ឆ្នាំឡើង គឺជាអ្នកដែលធ្លាប់បានឆ្លងកាត់របបខ្មែរក្រហម (១៩៧៥-១៩៧៩)។

២) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសម្រាប់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

៣) ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅតាមសហគមន៍ដាច់ស្រយាលសម្រាប់ជាព័ត៌មាន

មូលដ្ឋានក្នុងការរៀបចំជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់ប្រជាជនក្នុងសហគមន៍។

បន្ទាប់ពីធ្វើបទបង្ហាញចប់ ឡុង ដានី បានជម្រាបលោកមេឃុំ មើក នូវ ពីពេលវេលានៃការចាប់ផ្ដើមការងារគម្រោងពីខែមីនា ឆ្នាំ២០២២ នេះ និងខែបន្តបន្ទាប់ទៀត ក្រុមការងារនឹងចុះជួបដើម្បីស្ដាប់រឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងស្ថានភាពសុខភាពរបស់ពួកគាត់នៅតាមភូមិនីមួយៗក្នុងឃុំជាំ ស្រុកមេមត់។ បន្ទាប់មកអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមអាចទៅពិនិត្យសុខភាពនៅតាមមន្ទីរពិនិត្យនិងសម្រាកព្យាបាលជំងឺដែលជាដៃគូរបស់មជ្ឈមណ្ឌលឯកសារកោះថ្ម នៅឃុំទន្លូង (បន្ទប់ពិគ្រោះ និងព្យាបាលជំងឺ វេជ្ជបណ្ឌិត តាំង ស៊ីមាន) នៅ ទីរួមស្រុកមេមត់ (មន្ទីរសម្រាកព្យាបាល និងសម្ភពមេឌីកា២៤ម៉ោង) និងនៅស្រុកត្បូងឃ្មុំ (មន្ទីរពេទ្យ KV) បានដោយឥតគិតថ្លៃ។

លោកមេឃុំ មើក នូវ បានមានប្រសាសន៍ថា លោកមានការរីករាយដែលក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មបានចុះមកជួបសួរនាំប្រជាជនរបស់លោក ដែលធ្លាប់បានឆ្លងកាត់ការលំបាកវេទនាក្នុងរបបខ្មែរក្រហម និងអាចឲ្យពួកគាត់ទៅពិនិត្យសុខភាពដោយមិនអស់ថវិកាថែមទៀត។ ជាចុងក្រោយលោក មើក នូវ បានទូរសព្ទផ្ដល់ដំណឹងដល់មេភូមិ ទាំងអស់ក្នុងឃុំជាំឲ្យបានដឹងអំពីវត្តមានរបស់ក្រុមការងារមជ្ឈ-មណ្ឌលឯកសារកោះថ្មចុះទៅជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅក្នុងភូមិរបស់គាត់នៅក្នុងពេលឆាប់ៗ ខាងមុខនេះ។



លោក មើក នូវ មេឃុំជាំ
( ឡុង ដានី/មជ្ឈមណ្ឌលឯកសារកម្ពុជា )



ក្រុមការងារមជ្ឈមណ្ឌលឯកសារកោះថ្មរួមមាន ឡុង ដានី សុខវណ្ណ: គាត ស្រីឡែន និង ឈុំ រ៉ា ជួបជាមួយឃុំជាំ ឈ្មោះ មើក នូវ។
( ឈុំ រ៉ា/ មជ្ឈមណ្ឌលឯកសារកម្ពុជា )



សាលាឃុំជាំ ស្ថិតនៅក្នុងស្រុកមេមត់ ខេត្តត្បូងឃ្មុំ។
( គាត ស្រីឡែន/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# កិច្ចពិភាក្សារវាងមជ្ឈមណ្ឌលឯកសារកម្ពុជា
## និងអាជ្ញាធរស្រុកអង្គរធំ លើការងារគម្រោងសុខភាពសម្រាប់ អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

*គីម សុវណ្ណដានី*



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាប្រជុំជាមួយ អាជ្ញាធរស្រុកអង្គរធំ ខេត្តសៀមរាប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២២ លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា និងឧត្តមសេនីយ៍ត្រី និត ណារ៉ុង នាយសេនាធិការរង និងជាប្រធានក្រុមការងារប្រវត្តិសាស្ត្រយោធា យោធភូមិភាគទី៤ កងទ័ពជើងគោក កងយោធពលខេមរភូមិន្ទ រួមជាមួយក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា បានចុះទៅជួបជាមួយលោក ថាន់ អាន់ អភិបាលរងស្រុកអង្គរធំ និងមេឃុំក្នុងស្រុកអង្គរធំជាច្រើនរូបដើម្បីជួបសំណេះសំណាល និងជម្រាបជូនព័ត៌មានទាក់ទងគម្រោង «ការលើកកម្ពស់សិទ្ធិ និងការធ្វើឲ្យប្រសើរឡើង នូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម» ។

គោលបំណងនៃគម្រោងសុខភាពនេះ គឺ (១) ធ្វើឲ្យប្រសើរឡើង នូវស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ទៅតាមគោលដៅដែលបានកំណត់ (២) លើកកម្ពស់ការយល់ដឹងអំពីសុខភាពសាធារណៈ និងការទទួលបានសេវាកម្មសុខភាពសម្រាប់អ្នករស់រានមាន ជីវិតពីរបបខ្មែរក្រហម និង(៣) ធ្វើការសិក្សាស្រាវជ្រាវអំពីស្ថានភាពសុខភាពរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ជាពិសេសនៅតាមសហគមន៍ដាច់ស្រយាលសម្រាប់ផ្តល់ជាព័ត៌មាន ក្នុងការរៀបចំជំនួយអភិវឌ្ឍន៍នាពេលអនាគតដល់ប្រជាជននិងសហគមន៍ទាំងនេះ។

ចាប់តាំងពីដើមខែសីហា ឆ្នាំ២០២១ មជ្ឈមណ្ឌលឯកសារកម្ពុជាបានជ្រើសរើសអ្នកស្ម័គ្រចិត្តកម្ពុជាបីជំនាន់រួចមកហើយ ដែលមានចំនួន៧០០នាក់ បាន

ចុះធ្វើការនៅតាមមូលដ្ឋានទូទាំង២៥ រាជធានីខេត្តក្រុងនៅក្នុងប្រទេសកម្ពុជា។ ក្នុងនោះមានអ្នកស្ម័គ្រចិត្តចំនួន១៥ នាក់មកពីស្រុកផ្សេងៗគ្នាក្នុងខេត្តសៀមរាប ត្រូវបានជ្រើសរើសឲ្យធ្វើការងារនៅក្នុងគម្រោងសុខភាពនេះ។ ក្រុមអ្នកស្ម័គ្រចិត្តនៅក្នុងខេត្តសៀមរាប បានចុះសម្ភាសន៍អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមដែលជាឪពុកម្ដាយ អ៊ំពូ មីង ក៏ដូចជាអ្នកស្រុកភូមិរបស់ខ្លួន សរុបចំនួនប្រមាណ ៧០០ នាក់រួចមកហើយ។ នៅក្នុងខែមីនា ឆ្នាំ២០២២ នេះ ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបន្តជ្រើសរើស និងបណ្តុះបណ្តាលអ្នកស្ម័គ្រចិត្តជំនាន់ទីបួនមានចំនួនសរុបជាង ២០០នាក់ មកពីបណ្តាខេត្តនានា នៅទូទាំងប្រទេសកម្ពុជា។ ចំពោះខេត្តសៀមរាប ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាបានកំណត់យកស្រុកអង្គរធំជាគោលដៅអទិភាពដើម្បីបន្តការងារ ព្រោះប្រជាជននៅក្នុងស្រុកនេះភាគច្រើនមានជីវភាពក្រីក្រ និងខ្វះខាត និងត្រូវការចាំបាច់នូវការថែទាំសុខភាព។

នៅចុងបញ្ចប់នៃកិច្ចប្រជុំ លោកអភិបាលរងស្រុកអង្គរធំ លោក ថាន់ អាន់ និងក្រុមការងារបានថ្លែងអំណរគុណដល់មជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានជ្រើសរើសយកស្រុកអង្គរធំជាគោលដៅ ដើម្បីចុះជួយដល់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។



ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជាប្រជុំជាមួយអាជ្ញាធរស្រុកអង្គរធំ ខេត្តសៀមរាប។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




ក្រុមការងារមជ្ឈមណ្ឌលឯកសារកម្ពុជា និងអាជ្ញាធរស្រុកអង្គរធំ ខេត្តសៀមរាប ថតរូបជុំគ្នា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# ក្រុមនិស្សិតស្ត្រីមកពីវិទ្យាស្ថានពហុបច្ចេកទេស ខេត្តកំពង់ចាមធ្វើទស្សនកិច្ចសិក្សាមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

**ទូច វណ្ណេត**



ក្រុមនិស្សិតស្ត្រីដែលកំពុងសិក្សាឆ្នាំទី១ ជំនាញព័ត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ធ្វើទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (លី ដេវីដ និង វ៉ា ដារ៉ាពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា)

នាព្រឹកថ្ងៃអង្គារ៍ ទី២២ ខែមីនា ឆ្នាំ២០២២ ក្រុមនិស្សិតស្ត្រីដែលកំពុងសិក្សាឆ្នាំទី១ ជំនាញព័ត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ធ្វើទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ និស្សិតដែលចូលរួមទស្សនកិច្ចនេះមានចំនួនសរុប១៣នាក់ និងទទួលបានការស្វាគមន៍យ៉ាងកក់ក្តៅពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។

ជាកិច្ចចាប់ផ្តើម ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាមបាននាំនិស្សិតទាំងអស់ទៅទស្សនាពិព័រណ៍រូបថត ដើម្បីស្វែងយល់បន្ថែមទៅលើចំណេះដឹងប្រវត្តិសាស្ត្រ។ ក្នុងឱកាសទស្សនកិច្ចនេះ លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម បានបង្ហាញនិស្សិតទាំងអស់នូវកម្មវិធីអប់រំអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងឯកសារខ្មែរក្រហមនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម និងបានលើកទឹកចិត្តនិស្សិតធ្វើការស្រាវជ្រាវបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ បន្ទាប់ពីការធ្វើបទបង្ហាញ និស្សិតទាំងអស់បានទស្សនាវីដេអូឯកសារ មានចំណងជើងថា ក្តីសង្ឃឹមសម្រាប់អនាគត«Hope For The Future» ដែលបានលើកឡើងអំពីស្ត្រីពកូននៅក្នុងរូបថតដ៏ល្បីល្បាញមួយសន្ទឹកនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ឬអតីតមន្ទីរសន្តិសុខ ស-២១ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។

បន្ទាប់ពីបានទស្សនាវីដេអូឯកសារ និស្សិតទាំងអស់ក៏បានចូលរួមវេទិកាសន្ទនាអន្តរជំនាន់ជាមួយអៀង សារឿន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម

និងជាសមាជិកសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។ សារឿនបានចែករំលែកអំពីរឿងរ៉ាវជីវិតរបស់ខ្លួន និងការចូលធ្វើជាពេទ្យកងទ័ពខ្មែរក្រហមទៅកាន់ក្រុមនិស្សិត។ នៅពេលដែល សារឿនបានបញ្ចប់ការនិយាយរៀបរាប់ពីបទពិសោធន៍ជីវិតនៅក្នុងរបបខ្មែរក្រហម ការពិភាក្សា និងការសួរសំណួរបានចាប់ផ្តើម។ នៅក្នុងការជជែកពិភាក្សានេះ ក្រុមនិស្សិតបានសួរសំណួរទៅកាន់ សារឿន រួមមាន៖



អៀង សារឿន អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងជាសមាជិកសមាគមអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម ចែករំលែកអំពីរឿងរ៉ាវជីវិតរបស់ខ្លួននៅក្នុងរបបខ្មែរក្រហមទៅកាន់និស្សិត។ (លី ដេវីដ និងវ៉ា ដារ៉ាពេជ្រ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

**ទី១) តើអ៊ំប្រុសមានបាត់បង់សមាជិកគ្រួសារដែរឬទេ?**

**ទី២) តើអ៊ំប្រុសត្រូវបានបញ្ជូនទៅសមរភូមិមុខដែរឬទេ?**

**ទី៣) តើការហូបចុកគ្រប់គ្រាន់ដែរឬទេ**

**ទី៤) តើកុមារធ្វើការងារអ្វីខ្លះ និងទទួលបានរបបអាហារយ៉ាងដូចម្តេច?**

**ទី៥) តើមូលហេតុអ្វីបានជាអ៊ំប្រុសចូលធ្វើជាពេទ្យកងទ័ពខ្មែរក្រហម?**

ជាកិច្ចបញ្ចប់ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅ ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩) បោះពុម្ពលើកទី២ ដល់និស្សិតចូលរួមដើម្បីសិក្សាឈ្វេងយល់បន្ថែមទៀត។ ក្រុមនិស្សិតចូលរួមបានសរសេរចំណាប់អារម្មណ៍របស់ខ្លួនដូចខាងក្រោម៖



ក្រុមនិស្សិតស្ត្រីដែលកំពុងសិក្សាឆ្នាំទី១ ជំនាញព័ត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ធ្វើទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (លី ដេវីដ និងវ៉ា ដារ៉ាពេជ្រ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

***វុំ អាម៉ី*** និស្សិតឆ្នាំទី១ ជំនាញព័ត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម បង្ហាញចំណាប់អារម្មណ៍ថា «បន្ទាប់ពីបានចូលរួមកម្មវិធីថ្ងៃនេះ នាងខ្ញុំទទួលបានចំណេះដឹងបន្ថែម និងកាន់តែយល់អំពីផលលំបាកបន្សល់ទុកដោយរបបខ្មែរក្រហម»។

***សន ស្រីកា*** និស្សិតឆ្នាំទី១ ជំនាញព័ត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម បានចែករំលែកថា «នាងខ្ញុំយល់ថារបបខ្មែរក្រហមពិតជាផ្តល់ផលលំបាកខ្លាំងណាស់ដល់ប្រជាជនកម្ពុជា។ នាងខ្ញុំសង្ឃឹមថា ការរៀនពីប្រវត្តិសាស្ត្រនេះគឺអាចបង្រៀនឲ្យកូនខ្មែរចេះសាមគ្គីភាពគ្នា»។

***ហ៊ុន ស្រីនុត*** និស្សិតឆ្នាំទី១ ជំនាញព័ត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម បានលើកឡើងថា «នាងខ្ញុំមានអារម្មណ៍សោកស្តាយ និងអាណិតអាសូរយ៉ាងខ្លាំងចំពោះប្រជាជនខ្មែរដែលបានរស់នៅក្នុងរបបខ្មែរក្រហម និងបានរស់រានមានជីវិតពីរបបនេះ។ នាងខ្ញុំខិតខំរៀនសូត្រនិងចូលរួមសហការគ្នាដើម្បីកុំឲ្យរបបខ្មែរក្រហមនេះវិលត្រឡប់មកវិញម្តងទៀត»។



វុំ អាម៉ី និស្សិតឆ្នាំទី១ ជំនាញព័ត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម។ ( លី ដេវីដ និង វ៉ា ដា៉រ៉ាពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា )



សន ស្រីកា និស្សិតឆ្នាំទី១ ជំនាញព័ត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម។ ( លី ដេវីដ និង វ៉ា ដា៉រ៉ាពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា )



ក្រុមនិស្សិតស្ត្រីដែលកំពុងសិក្សាឆ្នាំទី១ ជំនាញពត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម ធ្វើទស្សនកិច្ចសិក្សាមកកាន់មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ ( លី ដេវីដ និងវ៉ា ដា៉រ៉ាពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា )



ហ៊ុន ស្រីនុត និស្សិតឆ្នាំទី១ ជំនាញព័ត៌មានវិទ្យា នៃវិទ្យាស្ថានពហុបច្ចេកទេសខេត្តកំពង់ចាម។ ( លី ដេវីដ និង វ៉ា ដា៉រ៉ាពេជ្រ/មជ្ឈមណ្ឌលឯកសារកម្ពុជា )

# ឈន ខិន្នែត ៖ ខ្មែរក្រហមយកឪពុកខ្ញុំទៅសម្លាប់ដោយសារតែបណ្តោយឱ្យគោស៊ីកណ្តាប់

*សៀង កញ្ញា និង ហៀក ស្រីពេជ្រ*



ឈន ខិន្នែត អាយុ៥៨ឆ្នាំមានទីកន្លែងកំណើតរស់នៅក្នុងភូមិត្រពាំងខ្វារ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ឈន ខិន្នែត អាយុ៥៨ឆ្នាំ កើតនៅក្នុងភូមិត្រពាំងខ្វារ ឃុំភ្នំកុង ស្រុកអង្គរជ័យ ខេត្តកំពត។ ខ្ញុំមានម្តាយឈ្មោះ ប៊ី សែ និងឪពុកឈ្មោះ ឈន សន (ស្លាប់)។ ខ្ញុំមានបងប្អូនបង្កើតសរុបទាំងអស់ចំនួន ៦នាក់ (ស្លាប់២នាក់)។ កាលពីកុមារភាព ខ្ញុំរៀនបានតិចតួចណាស់ ដោយសារខ្ញុំឧស្សាហ៍ឈឺ និងមានការវាយប្រយុទ្ធគ្នារវាងកងទ័ព លន់ នល់ និងយោធាខ្មែរក្រហមដែលបង្ករឲ្យមានចលាចលជាញឹកញាប់។

នៅក្នុងរបបខ្មែរក្រហមគ្រួសាររបស់ខ្ញុំកាន់តែលំបាកខ្លាំង។ ឪពុករបស់ខ្ញុំគឺជាគ្រូបង្រៀន ដូច្នេះខ្មែរក្រហមបានចាត់ទុកគ្រួសារខ្ញុំគឺជាពួកមូលធន។ អង្គការបានបែងចែកគ្រួសាររបស់ខ្ញុំឲ្យទៅរស់នៅក្នុងភូមិថ្មីមួយទៀត។ ប្រជាជនដែលរស់នៅទីនោះ អង្គការហៅថាជាពួកបញ្ញើ ឬប្រជាជនត្រៀម។ អង្គការបានចាត់តាំងឪពុករបស់ខ្ញុំឲ្យបររទេះដឹកកណ្តាប់ស្រូវ, ម្តាយរបស់ខ្ញុំប្រូតស្រូវ ហើយបងប្អូនរបស់ខ្ញុំ និងខ្ញុំជញ្ជូនកណ្តាប់ស្រូវ។ មានថ្ងៃមួយគោដែលឪពុករបស់ខ្ញុំយកទៅ ទឹមរទេះបានស៊ីកណ្តាប់ស្រូវ ខ្មែរក្រហមក៏យកឪពុកខ្ញុំទៅវាយសម្លាប់ចោល។

ដំបូង ខ្ញុំនិងម្តាយមិនដឹងថាខ្មែរក្រហមយកឪពុកខ្ញុំទៅសម្លាប់ទេ គឺមានអ៊ំប្រុសម្នាក់ដែលបររទេះដឹកកណ្តាប់ស្រូវជាមួយឪពុកខ្ញុំ បានឃើញខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំផ្ទាល់នឹងភ្នែក ហើយគាត់ក៏យកដំណឹងនេះមកប្រាប់គ្រួសារខ្ញុំ។ ក្រោយពេលដឹងថាឪពុករបស់ខ្ញុំស្លាប់ ម្តាយរបស់ខ្ញុំឈឺចិត្តយ៉ាងខ្លាំង ប៉ុន្តែគាត់មិនហ៊ានយំទេព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោលទៀត។ មានយប់មួយ ខ្ញុំនឹកឪពុកពេកក៏យំ ពេលនោះកងឈ្លបបានមកលបមើលបម្រុងយកខ្ញុំចេញទៅ ប៉ុន្តែខ្ញុំធ្វើពុតជាយល់សប្តិ។ ចំណែកបងស្រីរបស់ខ្ញុំ២នាក់ទៀតបានស្លាប់ដោយសារធ្វើការងារបាក់កម្លាំង និងហូបមិនគ្រប់គ្រាន់។ នៅពេលនោះ មានស្ត្រីពោះធំម្នាក់ចាញ់កូនក៏លួចបេះផ្លែឈើ

ហូប ប៉ុន្តែខ្មែរក្រហមបានតាមទាន់ក៏យកស្ត្រីនោះទៅវាយសម្លាប់ចោល។ ពេលខ្ញុំឃើញហេតុការណ៍នោះ ខ្ញុំភិតភ័យខ្លាំងណាស់។ ខ្ញុំមិនហ៊ាននិយាយពីហេតុការណ៍ដែលខ្ញុំបានឃើញទេ ព្រោះខ្ញុំភ័យខ្លាចខ្មែរក្រហមយកទៅសម្លាប់។ ខ្មែរក្រហមបានប្រើអ្នកទោសឲ្យជីករណ្តៅ នៅពេលជីករណ្តៅរួចហើយ ខ្មែរក្រហមវាយអ្នកទោសនោះទម្លាក់ចូលទៅក្នុងរណ្តៅ។ អ្នកទោសខ្លះមិនទាន់ស្លាប់ទេ ដូច្នេះខ្មែរក្រហមក៏កាយដីកប់ពីលើ។ ខ្ញុំមិនហ៊ានប្រកែក ឬក៏តវ៉ាជាមួយខ្មែរក្រហមទេ ទោះបីខ្មែរក្រហមសម្លាប់ឪពុករបស់ខ្ញុំ, ប្រើខ្ញុំឲ្យធ្វើការងារហួសកម្លាំង, មិនឲ្យហូបឆ្អែត និងមិនផ្តល់សម្លៀកបំពាក់ឲ្យខ្ញុំក៏ដោយ។ ក្រោយមកខ្មែរក្រហមបានប្រើខ្ញុំឲ្យបុកអង្ករដើម្បីត្រៀមធ្វើនំបញ្ចុកសម្រាប់ពិធីបុណ្យ ប៉ុន្តែពេលជិតដល់ថ្ងៃបុណ្យកងទ័ពវៀតណាមបានវាយចូលមកដល់។

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានចូលរៀននៅសាលារហូតបានប្រឡងជាប់ជាគ្រូបង្រៀន។ ក្រោយមក ខ្ញុំបានរៀបការជាមួយប្តីរបស់ខ្ញុំឈ្មោះ អ៊ុក សារ៉ាត់ និងមានកូនប្រុស២នាក់។ ខ្ញុំប្រកបមុខរបរជាគ្រូបង្រៀនរហូតមកដល់បច្ចុប្បន្ន។



ឈន ខិន្នែត រួមជាមួយអ្នកស្ម័គ្រចិត្តកម្ពុជានៃមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។
(ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



ទេសភាពនៅតាមវាលស្រែរដូវប្រាំងនៅខេត្តតាកែវ។
(ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ថៃ ថាត ៖ ខ្មែរក្រហមសម្លាប់ក្រុមគ្រួសារខ្ញុំ ដោយសារតែលួចអាហារហូប

*មីន សាណាស់*



ថៃ ថាត អាយុ ៦២ឆ្នាំ រស់នៅភូមិជើងទឹក, សង្កាត់ជើងទឹក, ក្រុងព្រៃវែង, ខេត្តព្រៃវែង។
(មីន សាណាស់/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ថៃ ថាត អាយុ៦២ឆ្នាំ មានស្រុកកំណើតនៅភូមិសា ឡុង ឃុំក្ដឿងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង។ ខ្ញុំមានបងប្អូនបង្កើត៤នាក់ ប្រុសម្នាក់ (ស្លាប់ក្នុងសម័យខ្មែរក្រហម) និង ស្រីបីនាក់។ ឪពុករបស់ខ្ញុំឈ្មោះ ពោ ថៃ គឺជាកសិករ និងជាជាងកាត់សក់ ចំណែកម្ដាយរបស់ខ្ញុំឈ្មោះ ស៊ុំ អៀត។ ឪពុកម្ដាយរបស់ខ្ញុំស្លាប់នៅក្នុងសម័យខ្មែរក្រហម។

កាលពីកុមារភាព ខ្ញុំរៀនបានត្រឹមថ្នាក់ទី៧ ចាស់ ក្នុងសម័យសង្គមរាស្ត្រនិយម នៅសាលាស្វាយរមៀត ដែលមានទីតាំងនៅស្រុកកំណើតរបស់ខ្ញុំ។ លុះចូលដល់ឆ្នាំ១៩៧០ សាលាត្រូវបានបិទទ្វារដោយសារតែសង្គ្រាម។ ចំណែកគ្រូៗដែលធ្លាប់ជួលផ្ទះម្ដាយរបស់ខ្ញុំស្នាក់នៅក៏សុំច្បាប់សាលាត្រឡប់ទៅរស់នៅស្រុកកំណើតរៀងៗខ្លួនដែរ។ នៅអំឡុងដើមឆ្នាំ១៩៧០ មានយុវជនបាននាំគ្នាចេញទៅធ្វើបាតុកម្ម ដោយយុវជននោះបានបែងចែកជាពីរក្រុមគឺ ក្រុមទី១) គាំទ្រ លន់ នល់ មកពីទីរួមខេត្តព្រៃវែង នាំគ្នាស្រែកថា «ជយោ សាធារណរដ្ឋ លន់ នល់» និង ក្រុមទី២) គាំទ្រសម្ដេចព្រះ នរោត្តម សីហនុ មកពីស្រុកអូររាំងឪ នាំគ្នាស្រែកថា «ជយោ សម្ដេចតា»។ ក្រុមបាតុកម្មទាំងពីរបានប៉ះទង្គិចគ្នាខ្លាំងនៅតំបន់ផ្សារពានា ឃុំក្ដឿងរាយ ស្រុកកញ្ជ្រៀច ខេត្តព្រៃវែង ដែលបណ្ដាលឲ្យបាត់បង់ជីវិតយុវជនអស់ជាច្រើននាក់។ ក្រោយពេលបាតុកម្មចប់ ភូមិរបស់ខ្ញុំក៏ធ្លាក់ចូលទៅក្នុងការកាន់កាប់របស់កងកម្លាំងរំដោះខ្មែរក្រហម និងមានការផ្លាស់ប្ដូរអ្នកដឹកនាំនៅក្នុងភូមិដែរ។

នៅឆ្នាំ១៩៧៥ បន្ទាប់ពីយោធាខ្មែរក្រហមទទួលជ័យជម្នះលើរបប លន់ នល់ អ្នកគ្រប់គ្រងខ្មែរក្រហមប្រមូលទ្រព្យសម្បត្តិឯកជនទាំងអស់របស់ប្រជាជនដាក់ចូលក្នុងសហករណ៍រួម ហើយសូម្បីតែដី ឡូងដុះនៅក្នុងបរិវេណផ្ទះរបស់ប្រជាជន ក៏ខ្មែរក្រហមហាមប្រជាជនមិនឲ្យដកយកមកហូបដែរ។ ចំពោះប្រជាជនណាដែលមានទិន្នាការប្រឆាំង ត្រូវបានអង្គការនាំយកទៅរៀនសូត្រ និងបាត់ខ្លួន។ ប្រជាជនក្នុងភូមិសា ឡុង

ត្រូវបានខ្មែរក្រហមជម្លៀសទៅនៅម្តុំមន្ទីរពេទ្យព-២ ជិតចម្ការកៅស៊ូពាមជាំង។ គ្រួសាររបស់ខ្ញុំត្រូវស្ថិតក្រោមការតាមដានរបស់ខ្មែរក្រហម ព្រោះខ្មែរក្រហមចោទគ្រួសារខ្ញុំថា ជាប់សែស្រឡាយវៀតណាម។ គ្រួសាររបស់ខ្ញុំបានធ្វើការផ្លូវធូរជាងគ្រួសារផ្សេងទៀត ហើយអង្គការបម្រុងយកគ្រួសាររបស់ខ្ញុំទៅសម្លាប់ជាច្រើនលើកច្រើនសារ ប៉ុន្តែត្រូវបានឈ្លបភូមិជួយ។

ក្រោយមក ខ្មែរក្រហមបានកត់ឈ្មោះ និងបញ្ជូនក្រុមគ្រួសាររបស់ខ្ញុំឲ្យទៅរស់នៅតំបន់ដីខ្លាញ់ ដែលជាទីកន្លែងលត់ដំ។ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់ខ្ញុំឲ្យទៅនៅឃុំតាំងក្រសាំង ស្រុកសន្ទុក ខេត្តកំពង់ធំ។ នៅទីនោះ អង្គការបញ្ជាឲ្យខ្ញុំលីបាវស្រូវក្នុងមួយថ្ងៃឲ្យបាន១តោន យកទៅលាក់ទុកនៅឃ្លាំងធំមួយក្នុងព្រៃ។ ដោយឃើញខ្ញុំហត់នឿយ បងប្រុសរបស់ខ្ញុំបានលួចមកជួយជញ្ជូនស្រូវ ប៉ុន្តែខ្មែរក្រហមដឹងក៏ចាប់បងប្រុសរបស់ខ្ញុំទៅសម្លាប់ចោល។ នៅអំឡុងពេលនោះឪពុករបស់ខ្ញុំពុំមានអាហារហូបគ្រប់គ្រាន់ឡើយ ដូច្នេះគាត់ក៏លួចកាប់ដំឡូងឈើនៅតាមផ្លូវដែលគាត់ដើរទៅធ្វើការយកមកហូប ក៏ត្រូវខ្មែរក្រហមឃើញ ហើយនាំគាត់យកទៅសម្លាប់ទៀត។ ក្រោយមក ដោយសារស្រេកឃ្លានខ្លាំងពេក ម្តាយរបស់ខ្ញុំបានលួចរើសគួរស្រូវយកមកបុក និងដាំបាយឲ្យកូនហូប ក៏ត្រូវឈ្លបខ្មែរក្រហមឃើញ ហើយរាយការណ៍ប្រាប់ប្រធានកងធំ។ យោធាខ្មែរក្រហមបានមកចាប់ម្តាយរបស់ខ្ញុំយកទៅសម្លាប់ចោលថែមទៀត។

នៅដើមខែមករា ឆ្នាំ១៩៧៩ កងទ័ពរណសិរ្សសាមគ្គីសង្គ្រោះជាតិកម្ពុជា និងកងទ័ពវៀតណាមបានចូលមកផ្តួលរំលំរបបខ្មែរក្រហម។ ខ្ញុំនិងបងស្រីបានវិលត្រឡប់មកស្រុកកំណើតវិញ ប៉ុន្តែពេលមកដល់ភូមិ ផ្ទះនិងដីធ្លីរបស់ខ្ញុំត្រូវបានប្រជាជនបានចូលមករស់នៅមុនអស់ទៅហើយ។ ខ្ញុំនិងបងស្រីក៏បានសម្រេចចិត្តមករស់នៅចាប់ផ្តើមកសាងជីវិតសារជាថ្មីក្នុងភូមិជើងទឹក សង្កាត់ជើងទឹក ក្រុងព្រៃវែង ខេត្តព្រៃវែង រហូតមកដល់ពេលបច្ចុប្បន្ន។


រោងបាយរបស់អ្នកភូមិ ក្នុងស្រុកមេសាង ខេត្តព្រៃវែង។ (ដេង ពង្សរ៉ាស៊ី/មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ថៅ សុខហៀង៖ កងចល័តភូមិភាគក្នុងរបបខ្មែរក្រហម

**ប៉ាន់ ទីន**



ថៅ សុខហៀង អាយុ៦១ឆ្នាំ ទទួលប្រអប់អនុស្សាវរីយ៍ពីក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ឆេង វ៉េង/មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ថៅ សុខហៀង អាយុ៦១ឆ្នាំ កើតនៅភូមិវាល ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិអង្គ ឃុំក្តាញ់ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំប្រកបរបរត្បាញហូល។ ឪពុករបស់ខ្ញុំឈ្មោះ ថៅ ផា និងម្តាយឈ្មោះ ឈិន ចិន។ ខ្ញុំមានបងប្អូនចំនួន១២នាក់ ប្រុស៥នាក់ និងស្រី៧នាក់ ប៉ុន្តែស្លាប់អស់៣នាក់។ កាលពីខ្ញុំអាយុ១០ឆ្នាំ ខ្ញុំបានចូលរៀនត្រឹមថ្នាក់ទី១០ នៅសាលាវត្តស្លាបាត ស្រុកព្រៃកប្បាស ខេត្តតាកែវ។

នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនចេញពីភូមិឲ្យទៅនៅភូមិផ្សេងៗ ខ្ញុំឃើញប្រជាជនមួយចំនួនជម្លៀសមកពីទីក្រុងភ្នំពេញ។ ប្រជាជនទាំងនោះត្រូវបានអង្គការចាត់ទុកថា ប្រជាជន ១៧ មេសា និងត្រូវជម្លៀសបន្តទៅកាន់ខេត្តបាត់ដំបង។ ពីដំបូងខ្មែរក្រហមបានឲ្យខ្ញុំរស់នៅតាមផ្ទះរៀងខ្លួន និងបុកអង្ករហូប។ ក្រោយមកខ្មែរក្រហមបានប្រមូលប្រជាជនឲ្យហូបនៅក្នុងសហករណ៍។ ខ្មែរក្រហមបានយកតុរៀនរបស់សិស្សនៅសាលា មកតម្រៀបធ្វើជាតុហូបបាយរួម។ ចំពោះរបបអាហាររបស់ប្រជាជនក្នុងរបបខ្មែរក្រហម គឺមានតែបបរលាយជាមួយពោត ហើយចុងភៅដួសបែងចែកទៅតាមក្រុម។ ខ្មែរក្រហមបានចាត់តាំងឲ្យឪពុកម្តាយរបស់ខ្ញុំកិនអង្ករនៅរោងម៉ាស៊ីន។ ជីតារបស់ខ្ញុំស្រោចបន្លែ និងដឹកដំឡូងពីភ្នំចំបាប់ទៅចែកនៅតាមសហករណ៍ ដោយក្នុងមួយថ្ងៃដឹកឲ្យបានពីរទៅបីរទេះ។ យាយរបស់ខ្ញុំរែងអង្ករ និងដាំបាយសម្រាប់ប្រជាជននៅក្នុងសហករណ៍។ រីឯខ្ញុំនៅកងចល័ត រែកដី ភ្ជួរស្រែ ដីកព្រែក និងបោកស្រូវ នៅភ្នំអង្គរបុរី។ កងចល័តរបស់ខ្ញុំគឺជាកងចល័តភូមិភាគ ប៉ុន្តែការហូបចុកគឺទទួលបានតិចជាងកងចល័តផ្សេងទៀត។ ថ្ងៃខ្លះខ្ញុំគ្មានអង្ករហូបទេ ដូច្នេះពេលចេញទៅស្ទូងដកម្តងៗ ខ្ញុំបានលួចចាប់ត្រីបុក្គាមខ្យងហូបទាំង

នៅ។ ខ្ញុំធ្លាប់បានឃើញខ្មែរក្រហមធ្វើទារុណកម្មអ្នកទោស ដោយយកដែកក្រៀវរទេះវាយទៅលើអ្នកទោសនោះ។ ខ្ញុំក៏ធ្លាប់ឃើញឈ្លបខ្មែរក្រហមចាប់ប្រជាជនដែលជាប់សាច់ញាតិជាមួយខ្ញុំដាក់រទេះសេះយកទៅវាយសម្លាប់នៅពេលយប់នៅក្នុងរណ្តៅរួម ដោយខ្មែរក្រហមចោទអ្នកទាំងនោះថាលួចហូបអាហារ។

នៅដើមឆ្នាំ១៩៧៩ ខ្ញុំបានឮប្រជាជនស្រែកថា កងទ័ពវៀតណាមវាយចូលមកហើយ។ បន្ទាប់ពីឮដំណឹងនេះ ខ្ញុំបបួលគ្នារត់ចេញពីសហករណ៍។ ខ្ញុំឃើញយោធាខ្មែរក្រហមជិះសេះ ប៉ុន្តែខ្ញុំមិនឃើញយោធាទាំងនោះបាញ់គ្នាឡើយ។ ខ្ញុំរត់ភៀសខ្លួនរហូតទៅដល់សំរោងយ៉ោង។ ខ្ញុំមិនហ៊ានចូលផ្ទះទេ ព្រោះខ្ញុំជឿតាមការឃោសនារបស់ខ្មែរក្រហមថា កងទ័ពវៀតណាមធ្វើបាប។ បន្ទាប់ពីកងទ័ពវៀតណាមបានវាយផ្តួលរំលំរបបខ្មែរក្រហមរួចហើយ ទើបខ្ញុំវិលត្រឡប់មកស្រុកកំណើតវិញ។

ក្រោយឆ្នាំ១៩៧៩ គ្រួសាររបស់ខ្ញុំបានរស់នៅជុំគ្នាប្រកបដោយសេចក្តីរីករាយ លើកលែងតែបងប្រុសរបស់ខ្ញុំម្នាក់ឈ្មោះ ចៅ ផន បានបាត់ខ្លួនរហូតមកដល់សព្វថ្ងៃ។ នៅអំឡុងពេលនោះ រដ្ឋអំណាចបានចែកដីឲ្យម្នាក់១៥អា ដើម្បីធ្វើស្រែ។ យើងបានធ្វើស្រែដោយចងក្រងជាក្រុមប្រវាស់ដៃ គឺជួយភ្ជួររាស់ និងប្រូតកាត់គ្នា។ ក្រោយមក ខ្ញុំបានរៀបការនៅអាយុ១៩ឆ្នាំ ជាមួយបុរសម្នាក់ឈ្មោះ មាស យ៉ុង និងមានកូនចំនួន៥នាក់ គឺស្រី២នាក់ និងប្រុស៣នាក់។ យើងប្រកបមុខរបរធ្វើស្រែចម្ការ និងត្បាញហូល រហូតមកដល់សព្វថ្ងៃ។



ឧបករណ៍ត្បាញ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

អ្នករស់រានមានជីវិតពីរបបខ្មែរក្រហមកំពុងត្បាញ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)



# ធឹក ង៉ែត៖ កងនារីស្រែអំបិល

រៀបរៀង ស្រីពេជ្រ



ធឹក ង៉ែត អាយុ៦៥ឆ្នាំ រស់នៅភូមិស្រែពោធិ៍ ឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ កំពុងរៀបរាប់បទពិសោធន៍ជីវិតឆ្លងកាត់របបខ្មែរក្រហមទៅកាន់អ្នកស្ម័គ្រចិត្តមជ្ឈមណ្ឌលឯកសារខេត្តតាកែវ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ ធឹក ង៉ែត អាយុ៦៥ឆ្នាំ បច្ចុប្បន្នរស់នៅភូមិស្រែពោធិ៍ឃុំចារ ស្រុកព្រៃកប្បាស ខេត្តតាកែវ។ នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីយោធាខ្មែរក្រហមឡើងកាន់អំណាច ខ្មែរក្រហមបានធ្វើបាបមកលើខ្ញុំ និងក្រុមគ្រួសាររបស់ខ្ញុំ ព្រោះដឹងថាបងប្រុសរបស់ខ្ញុំគឺជាអតីតជាទាហាន លន់ នល់ ចំណែកឪពុកម្តាយរបស់ខ្ញុំមានជីវភាពធូរធារកាលពីជំនាន់មុនៗ ខ្មែរក្រហមបានជម្លៀសប្រពន្ធកូនបងប្រុស

របស់ខ្ញុំ ដែលធ្លាប់ធ្វើទាហាន លន់ នល់ ទៅកាន់ខេត្តបាត់ដំបង។ ចំណែកខ្ញុំខ្មែរក្រហមបានបញ្ជូនឲ្យទៅធ្វើការងាររែកអំបិល។ ខ្ញុំតែងតែប្រុងប្រយ័ត្ននូវរាល់សកម្មភាពសព្វគ្រប់បែបយ៉ាង តាមដែលអាចធ្វើទៅបាន។ ខ្ញុំខិតខំធ្វើការងារជូនអង្គការមិនហ៊ានសម្រាកទេ សូម្បីតែពេលខ្ញុំឈឺ។ ខ្ញុំធ្វើការរហូតទាល់តែដួលសន្លប់នៅហ្នឹងកន្លែង ទើបប្រធានកងបញ្ជូនខ្ញុំទៅមន្ទីរពេទ្យ។ ខ្ញុំសម្រាកនៅពេទ្យបានពីរយប់ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យមកធ្វើការងារធម្មតាវិញ។ ខ្ញុំរែកអំបិលបីគោនក្នុងមួយថ្ងៃដោយសារ មានអ្នកខ្សឹបប្រាប់ខ្ញុំថា ប្រសិនបើមិនខំប្រឹងធ្វើការងារទេប្រយ័ត្នអង្គការយកទៅសម្លាប់ចោល។ ក្រៅពីធ្វើការនៅស្រែអំបិល អង្គការបានចាត់តាំងខ្ញុំឲ្យឃ្វាលក្របី, វេញខ្សែគោ, ធ្វើបង្គីក្នុងមួយថ្ងៃឲ្យបាន១២គូរ និងបន្សាំគោ ស្ទូងចំនួន២៥នឹមដើម្បីភ្ជួរស្រែ។ គ្រប់ការងារដែលខ្មែរក្រហមបានដាក់ឲ្យ ខ្ញុំធ្វើបានទាំងអស់ដោយមិនហ៊ានប្រកែក ប្តូរ៉ាឡើយ ព្រោះខ្លាចខ្មែរក្រហមយកទៅសម្លាប់ចោល។ នៅចុងឆ្នាំ១៩៧៨ ខ្ញុំផ្លាស់មកធ្វើការងារដាកងដឹកជញ្ជូន ចំណែកការហូបចុក ខ្ញុំទទួលបានតែបបររាវដែលមានតែអង្ករមួយគ្រាប់ប៉ុណ្ណោះ។ ថ្ងៃខ្លះ ពេលដែលខ្ញុំចេញទៅឃ្វាលក្របី ខ្ញុំបានដើររើសត្នោតទុំយកមកហូបបន្ថែម។

រឿងរ៉ាវដែលខ្ញុំឈឺចាប់និងចងចាំមិនភ្លេចពីរបបខ្មែរក្រហមគឺ ខ្មែរក្រហមបានធ្វើទារុណកម្មនិងចាក់ថ្នាំសម្លាប់ឪពុករបស់ខ្ញុំ ដោយខ្មែរក្រហមចោទគាត់ថា គឺជាក្រុមមូលធនកាលពីជំនាន់មុន។ ចំណែក បងប្រុសរបស់ខ្ញុំនិងប្រពន្ធត្រូវបានខ្មែរក្រហមយកទៅសម្លាប់ ដោយសារតែមានថ្ងៃមួយកូនរបស់ពួកគាត់ចង់ហូបត្រី ហើយពួកគាត់លួចចេញទៅរកត្រីឲ្យកូនហូបរហូតហួសម៉ោងធ្វើការ។ ខ្ញុំបានស្វែងរកក្មួយដែលកងនារីយកទៅចិញ្ចឹម ប៉ុន្តែខ្ញុំរកមិនឃើញ។ បន្ទាប់ពីរបបខ្មែរក្រហមបានដួលរលំ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ខ្ញុំបានទៅនៅដំរី ហើយឆ្លៀតចូលទៅសួររកក្មួយដែលបាត់ខ្លួននៅអង្គការកាកបាទក្រហមនៅដំរី ប៉ុន្តែត្រូវបានអ្នកធ្វើការនៅទីនោះបដិសេធព្រោះខ្ញុំមកពីតំបន់ផ្សេង។

ក្រោយមកខ្ញុំបានរៀបការ និងខិតខំរកប្រាក់។ ខ្ញុំបានត្រឡប់មកស្រុកកំណើតប្រកបរបរធ្វើស្រែរហូតមកដល់សព្វថ្ងៃ ប៉ុន្តែមិនសូវជាធូរធារប៉ុន្មានទេ។ ទោះបីយ៉ាងណាខ្ញុំរស់នៅប្រកបដោយភាពរីករាយ និងមានសិទ្ធិសេរីភាពគ្រប់គ្រាន់ក្នុងការប្រកបការងារផ្សេងៗ។



ធឹក ង៉ែត ទទួលប្រអប់អនុស្សាវរីយ៍ពីអ្នកស្ម័គ្រចិត្តកម្ពុជា ខេត្តតាកែវ។ (ង៉ាន់ វីន/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# អ៊ាប ម៉ុង ៖ កងចល័តស្រុកព្រៃកប្បាស

**ថ៉ាន់ ទីន**



អ្នកស្ម័គ្រចិត្តកម្ពុជាប្រគល់ប្រអប់អនុស្សាវរីយ៍ជូន អ៊ាប ម៉ុង។ (តាំង វិមន្ត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ាប ម៉ុង អាយុ៧៨ឆ្នាំ កើតនៅភូមិសំបត ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ សឹង ស៊ឹម និងម្តាយឈ្មោះ ភឿក វ៉ា។

នៅឆ្នាំ១៩៦៨ ខ្ញុំចូលរៀននៅសាលាព្រៃកប្បាស រយៈពេល៣ឆ្នាំ ក៏កើតមានរដ្ឋប្រហារនៅថ្ងៃទី១៨ ខែមីនា ឆ្នាំ១៩៧០។ បន្ទាប់មក ខ្ញុំទៅរៀននៅវត្តអង្គរាញ់មួយរយៈខ្លី ក៏បួសជាព្រះសង្ឃ។ ខ្ញុំបួសបានរយៈពេលជិតមួយវស្សា ខ្មែរក្រហមឲ្យខ្ញុំសឹកវិញ។ នៅពេលខ្ញុំអាយុ១៥ឆ្នាំ ខ្ញុំបានចូលធ្វើការនៅកងចល័តឃុំព្រៃកប្បាស។ នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមបានចាត់តាំងខ្ញុំឲ្យទៅជីកព្រែកនៅស្ទឹងព្រែកត្នោត ក្នុងខេត្តកំពង់ស្ពឺ រយៈពេល៣ខែ ទើបត្រឡប់មកភូមិ

វិញ។ ក្រោយមក ខ្មែរក្រហមបានបញ្ជូលខ្ញុំទៅនៅក្នុងកងចល័តស្រុកព្រៃកប្បាស និងចាត់តាំងឲ្យជីកព្រែកលើកប្រព័ន្ធភ្លឺស្រែ និងធ្វើស្រែ។ ខ្ញុំត្រូវធ្វើការទាំងយប់ទាំងថ្ងៃ និងបានសម្រាករយៈពេលមួយម៉ោងពេលហូបបាយនៅម៉ោង៥ល្ងាចប៉ុណ្ណោះ។ បន្ទាប់មក នៅវេលាម៉ោង៦ល្ងាច ខ្មែរក្រហមប្រើខ្ញុំធ្វើការងារបន្តទៀត។ ខ្មែរក្រហមបានជម្លៀស ប្រជាជន១៧ មេសា មកធ្វើការជាមួយខ្ញុំ និងប្រើអ្នកទាំងនោះឲ្យធ្វើការងារគ្មានទំនេរឡើយ ចំណែកអាហារគឺមានតែបបររាវប៉ុណ្ណោះ។ ក្រុមគ្រួសារប្រជាជនជម្លៀសមកពីទីក្រុងភ្នំពេញ ខ្មែរក្រហមបែងចែកឲ្យទៅនៅផ្ទះជាមួយអ្នកមូលដ្ឋាន ដែលក្នុងមួយផ្ទះមានអ្នកជម្លៀសចាប់ពី២ទៅ៣គ្រួសារ។ ប្រជាជនជម្លៀសមកថ្មីដែលប្រព្រឹត្តខុស គឺកម្មាភិបាលខ្មែរប្រហមបានយកអ្នកទាំងនោះទៅលត់ដំនៅជ្រៃអូរញ្ញោ ស្ថិតក្នុងខេត្តកំពង់ស្ពឺ។

ខ្ញុំធ្វើការទាំងឈឺ។ នៅរដូវប្រាំង ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យជីកព្រែក ហើយរដូវវស្សាខ្មែរក្រហមឲ្យខ្ញុំរែកកណ្ដាប់ ដកសំណាប ស្ទូង និងលើកប្រព័ន្ធភ្លឺស្រែ។ ប្រធានកងបានកំណត់ក្នុងម្នាក់ត្រូវលើកភ្លឺស្រែឲ្យបានប្រវែង៥ម៉ែត្រក្នុងមួយថ្ងៃ និងកំណត់ក្នុងមួយក្រុមដែលមានសមាជិកចំនួន១០នាក់ ត្រូវជីកព្រែកទទឹងប្រវែង៤ម៉ែត្របណ្ដោយ៥ម៉ែត្រ និងជម្រៅ១.៥ម៉ែត្រ។

ខ្ញុំធ្លាប់ឃើញខ្មែរក្រហមហៅក្រុមយុវជនឲ្យឡើងរទេះសេះ ដោយនិយាយប្រាប់យុវជនទាំងនោះថា «ឥឡូវអង្គការឲ្យប្អូនៗទៅស្រុកវិញហើយ គឺស្រុកនៅឯណាអង្គការឲ្យទៅទីនោះ»។ ពេលខ្លះ ខ្ញុំឃ្លានខ្លាំងពេកចង់លួចបេះផ្លែចេក និងល្ហុង យកមកហូប ប៉ុន្តែខ្ញុំខ្លាចឈ្លបខ្មែរក្រហមតាមទាន់។ សមាជិកកងខ្លះមិនបានហូបអាហារគ្រប់គ្រាន់ បណ្ដាលឲ្យខ្សោយហេវហត់និងដួលសន្លប់។ យើងបាននាំគ្នាសែងអ្នកជំងឺនោះទៅព្យាបាលនៅមន្ទីរពេទ្យស្រុកព្រៃកប្បាស។ យើងសែងអ្នកជំងឺនោះទៅដល់ពេទ្យ ម៉ោង១២ ឬម៉ោង១រសៀល ហើយពេលខ្លះពេទ្យក៏ជួយសង្គ្រោះបាន ពេលខ្លះក៏ជួយសង្គ្រោះអ្នកជំងឺនោះមិនបានដែរ។ បន្ទាប់ពីរបបខ្មែរក្រហមដួលរលំបានរយៈពេល៤ខែ គឺនៅខែមេសា ឆ្នាំ១៩៧៩ ខ្ញុំបានរៀបការប្រពន្ធឈ្មោះ ស៊ឹម សៀងលី និងមានកូនចំនួន ៤នាក់ គឺស្រី ៣នាក់ និងប្រុស១នាក់។



អ៊ាប ម៉ុង អាយុ៧៨ឆ្នាំ មានទីលំនៅបច្ចុប្បន្នរស់នៅក្នុងភូមិអំពិលរៀង ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ កំពុងចែករំលែកបទពិសោធន៍ជីវិតរបស់គាត់នៅក្នុងសម័យខ្មែរក្រហម។
(តាំង វិមន្ត/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ឪពុករបស់ខ្ញុំស្លាប់ដោយសារលួចដំឡូង

**ង៉ាន់ វីន**




អ្នកស្ម័គ្រចិត្តកម្ពុជាប្រគល់ប្រអប់អនុស្សាវរីយ៍ជូន អ៊ុម អ៊ិន។ (ង៉ាន់ វីន / មជ្ឈមណ្ឌលឯកសារកម្ពុជា)

ខ្ញុំឈ្មោះ អ៊ុម អ៊ិន មានស្រុកកំណើតនៅភូមិអំពិលរៀង ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ។ ខ្ញុំមានឪពុកឈ្មោះ អ៊ុម អឿន និងម្តាយឈ្មោះ ពេង ឡេង។ កាលនៅពីក្មេងខ្ញុំបានទៅរស់នៅជាមួយឪពុកម្តាយនៅឯស្រុកអង្គរបូរី ខេត្តតាកែវ។ នៅពេលម្តាយឪពុករបស់ខ្ញុំទៅធ្វើស្រែក ទុកឲ្យខ្ញុំនៅជាមួយបងៗ។ ខ្ញុំបានចូលរៀនត្រឹមថ្នាក់ទី៧ នៅសង្គមចាស់។ ដោយសារជីវភាពគ្រួសារលំបាក ទើបឪពុកខ្ញុំសម្រេចចិត្តយកខ្ញុំដែលពេលនោះមានអាយុ១៣ឆ្នាំ ឲ្យទៅរស់នៅជាមួយនឹងអ៊ំប្រុស ព្រោះតែខ្ញុំមិនអាចជួយការងារក្នុងបន្ទុកគ្រួសារដូចបងៗឯទៀត។ នៅអំឡុងពេលខ្ញុំរស់នៅជាមួយអ៊ំប្រុស ខ្ញុំនឹករឭកឪពុកម្តាយ ខ្លាំងណាស់។ នៅក្នុងឆ្នាំ១៩៧៤ ខ្ញុំបានរៀបការជាមួយប្រពន្ធឈ្មោះ ឈាន យ៉េង។

នៅក្នុងឆ្នាំ១៩៧៥ ខ្មែរក្រហមចាត់តាំងខ្ញុំឲ្យទៅជីកប្រឡាយ និងរែកដី នៅភ្នំអន្លុងរបូរី។ ប្រពន្ធរបស់ខ្ញុំ ខ្មែរក្រហមចាត់តាំងឲ្យស្ទូងស្រូវ និងធ្វើស្រែ។ ម្ដាយរបស់ខ្ញុំ ខ្មែរក្រហមចាត់តាំងឲ្យដាំបាយ ហើយឪពុករបស់ខ្ញុំ អង្គការចាត់តាំងឲ្យឃ្វាលគោ និងក្របី។ អង្គការឲ្យយើងហូបតែបបរលាយជាមួយសម្លត្រកួនប៉ុណ្ណោះ។ ខ្ញុំមិនបានរស់នៅជួបជុំគ្រួសារទេ។ អង្គការបានបែងចែកមនុស្សឲ្យរស់នៅតាមកងផ្សេងៗគ្នា ដូចជា កងកុមារ កងយុវជន ចំណែកកងចាស់ៗ អង្គការចាត់តាំងឲ្យមើលក្មេងៗ។ ថ្ងៃមួយដោយសារឃ្លានខ្លាំងពេក ឪពុករបស់ខ្ញុំបានទៅលួចដំឡូងមកហូប ប៉ុន្តែកងឈ្លបតាមទាន់ក៏ចាប់ឪពុកខ្ញុំយកទៅវាយចោលនៅវាលស្រែ។ ដំបូងម្ដាយរបស់ខ្ញុំបានដើររកឪពុករបស់ខ្ញុំ ប៉ុន្តែដើររកមិនឃើញទាល់តែសោះ។ ម្ដាយរបស់ខ្ញុំទៅសួរអ្នកភូមិ ប៉ុន្តែគ្មាននរណាប្រាប់គាត់ឡើយ។ ម្ដាយរបស់ខ្ញុំដើររកប្ដីបណ្ដើរ និងយំបណ្ដើរ។ ក្រោយមកមានអ្នកភូមិម្នាក់បានលួចខ្សឹបប្រាប់ម្ដាយរបស់ខ្ញុំថា ឪពុករបស់ខ្ញុំត្រូវបានអង្គការយកទៅវាយចោលនៅឯវាលស្រែហើយ។ ដោយសារអាណិតប្ដីខ្លាំងពេក ម្ដាយរបស់ខ្ញុំបានធ្លាក់ខ្លួនឈឺ ហើយក្រោយមកក៏បានស្លាប់។

បន្ទាប់ពីខ្មែរក្រហមដួលរលំ នៅឆ្នាំ១៩៧៩ ខ្ញុំបានរស់នៅជុំជាមួយប្រពន្ធ និងកូនចំនួន៤នាក់ គឺស្រី១នាក់ ប្រុស៣នាក់។ បច្ចុប្បន្ន ខ្ញុំប្រកបមុខរបរធ្វើស្រែ និងរស់នៅក្នុងឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ ដដែល។



អ៊ុម អ៊ិន រស់នៅក្នុងភូមិអំពិលរៀង ឃុំព្រៃកប្បាស ស្រុកព្រៃកប្បាស ខេត្តតាកែវ កំពុងចែករំលែកបទពិសោធន៍ជីវិតរបស់គាត់នៅក្នុងសម័យខ្មែរក្រហម ប្រាប់ដល់អ្នកស័គ្រចិត្តកម្ពុជា ខេត្តតាកែវ។ (ង៉ាន់ វីន / មជ្ឈមណ្ឌលឯកសារកម្ពុជា)

# ការិយាល័យ
# ព័ត៌មានសាធារណៈ







«ការិយាល័យព័ត៌មានសាធារណៈ» របស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានបើកបម្រើជូននិស្សិតអ្នកស្រាវជ្រាវបុគ្គលិករាជការ និងអង្គការក្រៅរដ្ឋាភិបាល និងបុគ្គលទាំងឡាយដែលមានចំណាប់អារម្មណ៍ពីការវិវឌ្ឍន៍របស់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ឬសាលាក្តីខ្មែរក្រហម។







មជ្ឈមណ្ឌលឯកសារកម្ពុជាជាកន្លែងប្រមូលផ្តុំ និងចងក្រងឯកសារអំពីរបបកម្ពុជាប្រជាធិបតេយ្យបានច្រើនបំផុត។ ឯកសារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាមានប្រាំប្រភេទ។ ប្រភេទឯកសារទីមួយគឺឯកសារជាក្រដាសសន្លឹកដែលមានចំនួនជិតមួយលានទំព័រ។ ប្រភេទឯកសារទីពីរ គឺជាបទសម្ភាសន៍ដែលបុគ្គលិកមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅធ្វើសម្ភាសន៍ជាមួយជនរងគ្រោះ និងអតីតកម្មាភិបាលខ្មែរក្រហម។ ប្រភេទឯកសារទីបីគឺជារូបថតទាក់ទងទៅនឹងសម័យខ្មែរក្រហម។ ប្រភេទឯកសារទីបួនគឺជាឯកសារទាក់ទងទៅនឹងការធ្វើផែនទីរណ្តៅសាកសព និងទីតាំងសម្លាប់របស់ខ្មែរក្រហម និងឯកសារទីប្រាំគឺជាខ្សែភាពយន្តឯកសារដែលបានផលិតឡើងក្នុងរបបខ្មែរក្រហម និងសម័យក្រោយមកទៀត។







តាមរយៈការិយាល័យព័ត៌មានសាធារណៈ សាធារណជនអាចនឹងស្រាវជ្រាវឯកសារទាំងនេះបាន។ ឯកសារខ្លះទៀតរួមមាន៖ ប្រវត្តិរូបកម្មាភិបាលខ្មែរក្រហម ចម្លើយសារភាពកំណត់ហេតុរបស់បក្សទូរលេខឆ្លើយឆ្លងព័ត៌មានដែលបានមកពីការសម្ភាសន៍ជាមួយអតីតកម្មាភិបាលខ្មែរក្រហម និងទិន្នន័យគន្លនិទ្ទេសបង្ហាញពីរណ្តៅសាកសព ទីតាំងគុក និងបូជនីយដ្ឋានប្រល័យពូជសាសន៍។










ការិយាល័យព័ត៌មានសាធារណៈមានទីតាំងនៅអគារលេខ៦៦ មហាវិថីព្រះសីហនុ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។ ការិយាល័យរបស់យើងបើកជូនសាធារណជនចាប់ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ពេលព្រឹកពីម៉ោង ៨÷០០ ដល់ម៉ោង ១២÷០០ និងពេលរសៀលពីម៉ោង ២÷០០ ដល់ម៉ោង ៥÷០០។ ប្រសិនបើអស់លោកអ្នកមានចម្ងល់ ឬចង់រៀបចំព្រឹត្តិការណ៍ជាក្រុមណាមួយ សូមទាក់ទងបុគ្គលិករបស់យើង ស៊ាង ចិន្តា អ្នកសម្របសម្រួល តាមរយៈទូរសព្ទលេខ៖ ០១២ ៦៦៣ ៦១១ ឬ អ៊ីម៉ែល ៖

truthchenda.s@dccam.org

សូមអរគុណ!

# វេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅមជ្ឈមណ្ឌលឯកសារនៅខេត្តតាកែវ

សៀង កញ្ញា



សិស្សានុសិស្សកំពុងសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យក្នុងថ្នាក់រៀនសិស្សានុសិស្សកំពុងសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ
(ហៀក ស្រីពេជ្រ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

នៅថ្ងៃទី២៦ ខែមីនា ឆ្នាំ២០២២ មជ្ឈមណ្ឌលឯកសារកម្ពុជាខេត្តតាកែវ បានរៀបចំវេទិកាថ្នាក់រៀនស្តីអំពីការសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ជាមួយសិស្សានុសិស្សចំនួន៣០នាក់ (សិស្សប្រុស៧ នាក់ និងសិស្សស្រី២២នាក់) មកពីវិទ្យាល័យព្រៃទប់ ស្រុកទ្រាំង ខេត្តតាកែវ នៅក្នុងការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម ស្ថិតនៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ។

មុនពេលធ្វើវេទិកាថ្នាក់រៀន ក្រុមការងារបានចែកតារាងស្ទាបស្ទង់មតិចំនួន៣០ច្បាប់ ទៅដល់សិស្សានុសិស្ស ដើម្បីវាស់ស្ទង់ចំណេះដឹង មុននឹងធ្វើការបង្រៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ តារាងវាស់ស្ទង់ចំណេះដឹងនេះមានសំណួរចំនួន ១២ ដែលត្រូវបានបែងចែកជាបួនផ្នែកធំៗ គឺ ផ្នែកទីមួយ) ចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ផ្នែកទីពីរ) ចំណេះដឹងអំពីនិយមន័យឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧទាហរណ៍នៃការកើតមានឧក្រិដ្ឋកម្មឃោរឃៅ។ ផ្នែកទីបី) ចំណេះដឹងអំពីធាតុផ្សំដែលនាំឲ្យមានអំពើប្រល័យពូជសាសន៍នៅក្នុងសហគមន៍និងប្រទេសជាតិ និង ផ្នែកទីបួន) ចំណេះដឹងអំពីវិធីសាស្ត្រ

ដ៏មានសារសំខាន់ក្នុងការទប់ស្កាត់អំពើប្រល័យពូជសាសន៍។

បន្ទាប់មក គ្រូខេ្មសបានផ្ដល់ឱកាសដល់សិស្សានុសិស្ស សួរសំណួរទាក់ទងនឹងប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មុនពេលធ្វើបទបង្ហាញ។ មូលហេតុដែលឲ្យសិស្សសួរសំណួរមុនពេលបង្រៀនគឺ ទី១) ចង់ដឹងអំពីការយល់ដឹងរបស់សិស្សទាក់ទងរបបខ្មែរក្រហមមានកម្រិតណា។ ទី២) ផ្ដល់ឱកាសដល់សិស្សសួររាល់សំណួរដែលចង់ដឹងទាក់ទងនឹងរបបខ្មែរក្រហម ទី៣) ឲ្យសិស្សចូលរួមសកម្មភាពក្នុងការគិតដើម្បីត្រៀមខ្លួនក្នុងការស្ដាប់គ្រូពន្យល់មេរៀន។

តាមរយៈសំណួរដែលសិស្សានុសិស្សសួរទៅកាន់លោកគ្រូ មានដូចជា ១) ហេតុអ្វីបានជាខ្មែរក្រហមជម្លៀសប្រជាជនចេញពីទីក្រុងភ្នំពេញ? តើប្រជាជនទាំងអស់នោះរស់នៅដោយរបៀបណា? ២) តើក្នុងរបបកម្ពុជាប្រជាធិបតេយ្យថ្នាក់ដឹកនាំប្រទេសមានយុទ្ធសាស្ត្រអ្វីខ្លះ? ៣) ហេតុអ្វីបានជាខ្មែរក្រហមសម្លាប់ជាតិសាសន៍ខ្លួនឯង? ៤) តើនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យមានវិស័យសុខាភិបាលដែរឬទេ? បើមានការព្យាបាលប្រព្រឹត្តឡើងយ៉ាងដូចម្ដេច? ៥) តើការរៀបការសម័យខ្មែរក្រហមប្រព្រឹត្តទៅដោយរបៀបណា? ៦) តើហេតុអ្វីបានជាខ្មែរក្រហមឲ្យប្រជាជនរស់នៅរួមគ្នា ហូបរួមគ្នា និងធ្វើការរួមគ្នា? ៧) តើរបបខ្មែរក្រហមមានអ្នកហ៊ានប្រឆាំង ប្ដូរ៉ាដែរឬទេ? ប្រសិនបើមានតើមានអ្វីកើតឡើង។

បន្ទាប់ពីទទួលបានសំណួរពីសិស្ស គ្រូខេ្មសមិនទាន់ឆ្លើយតបភ្លាមៗនោះទេ គឺបានធ្វើបទបង្ហាញទាក់ទងនឹងប្រវត្តិសាស្ត្រខ្មែរក្រហម និងចាក់បញ្ចាំងខ្សែវីដេអូឯកសារខ្លីមួយ មានរយៈពេលប្រាំមួយនាទីដែលនិយាយពី«កុមារកម្ពុជា»។ ខ្សែវីដេអូមួយនេះបង្ហាញពីដំណើរគ្មានគោលដៅរបស់ក្មេងកំព្រាដែលនៅសល់ពីរបបខ្មែរក្រហម។ ក្នុងវីដេអូបង្ហាញពីរូបភាពស្គមស្គាំងគ្មានអនាម័យក្នុងការហូបចុក និងការរស់នៅរបស់កុមារដែលមានជីវិតតែលតោលគ្មានគោលដៅ ដែលដំណើររឿងទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពដែលមិនអាចទទួលយកបានពីសំណាក់ក្មេងៗជំនាន់ក្រោយ។ តាមរយៈវីដីអូនេះផងដែរក៏បានដាស់តឿនឲ្យក្មេងជំនាន់ក្រោយស្អប់ខ្ពើមសង្គ្រាម និងមានស្មារតីជួយទប់ស្កាត់កុំឲ្យមានការកើតឡើងនៃរបបខ្មែរក្រហមម្ដងទៀត។

បន្ទាប់ពីការផ្ដល់ពេលវេលាបន្តិចបន្តួចសម្រាប់សិស្សានុសិស្សសម្រាករយៈពេលខ្លី គ្រូបានចាប់ផ្ដើមធ្វើបទបង្ហាញរបស់ខ្លួនបន្តទៀត ដោយផ្ដោតលើផ្នែកសំខាន់គឺ និយមន័យនៃអំពើឧក្រិដ្ឋកម្ម និងកត្តាគ្រោះថ្នាក់ជាក់លាក់ដែលបង្កើតជាឧក្រិដ្ឋកម្មឃោរឃៅ។

នៅពេលធ្វើបទបង្ហាញគ្រូខេ្មសឆ្លើយនូវរាល់សំណួរដែលសិស្សានុសិស្សបានសួរ ដោយធ្វើការបកស្រាយយ៉ាងក្បោះក្បាយ។ បន្ទាប់មក គ្រូខេ្មសបានលើកទឹកចិត្តឲ្យសិស្សបំពេញតារាងស្ទាបស្ទង់មតិ ដើម្បីស្វែងយល់ពីចំណេះដឹងរបស់សិស្សានុសិស្សកើនឡើងកម្រិតណា បន្ទាប់ពីបានចូលរួមវេទិកាថ្នាក់រៀនរួច។

ក្រោយពីធ្វើការវាស់ស្ទង់ចំណេះដឹងសិស្សរួច ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តតាកែវ បានសាកសួរអំពីចំណាប់អារម្មណ៍របស់សិស្សដែលបានចូលរួមវេទិការថ្នាក់រៀននេះ ដោយក្នុងនោះ ស្រេង ស្រីល័ក្ខ ភេទស្រី អាយុ១៨ឆ្នាំ ជាសិស្សនៃវិទ្យាល័យព្រៃទប់ បានបញ្ចេញចំណាប់អារម្មណ៍ថា "ក្រោយពីបានរៀនប្រវត្តិសាស្ត្ររួចមក ខ្ញុំបានយល់ដឹងកាន់តែស៊ីជម្រៅជាងមុន និងកាន់តែចង់ដឹងថែមទៀតពីរបបខ្មែរក្រហម។



សិស្សានុសិស្សកំពុងសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យក្នុងសិស្សានុសិស្សកំពុងសិក្សាប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យនៅក្នុងការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហមនៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ (ហៀក ស្រីពេជ្រ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

ជាចុងបញ្ចប់ នាងខ្ញុំ ស្នើសុំឲ្យលោកគ្រូ អ្នកគ្រូ ណែនាំនាងខ្ញុំ ឲ្យយល់ដឹងពីរឿងរ៉ាវប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យកាន់តែច្បាស់ថែមទៀត”។

ក្រុមការងារក៏បានសម្ភាសន៍ និងចោទសួរសំណួរចំនួន៣ទៅកាន់សិស្សថែមទៀតដោយ សំណួរទី១) តើប្អូនយល់ឃើញបែបណាចំពោះវេទិកាថ្នាក់រៀននេះ? សំណួរទី២) តើមានវិធីសាស្ត្រណាខ្លះ ទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមកើតឡើងម្តងទៀត? សំណួរទី៣) តើមជ្ឈមណ្ឌលឯកសារកម្ពុជាអាចជួយអ្វីបានខ្លះដល់វិទ្យាល័យប្អូន?

ខាត់ស្រីពេជ្រអាយុ១៨ឆ្នាំជាសិស្សនៃវិទ្យាល័យព្រៃទប់ បានឆ្លើយនូវសំណួរទី១ថា វេទិកាថ្នាក់រៀននេះពិតជាមានសារសំខាន់ណាស់សម្រាប់សិស្សានុសិស្សជាពិសេសសិស្សថ្នាក់ទី១២។ និងសំណួរទី២ ខាត់ស្រីពេជ្រ បានឆ្លើយថា ដើម្បីកុំឲ្យរបបនេះកើតឡើងម្តងទេ គឺយុវជនទាំងអស់ត្រូវរៀនឲ្យមានចំណេះដឹងឲ្យទូលំទូលាយអំពីប្រវត្តិសាស្ត្ររបស់ខ្លួន។

ចេង សុឃីម ភេទប្រុស អាយុ២០ឆ្នាំ ជាសិស្សនៃវិទ្យាល័យ ព្រៃទប់ បានឆ្លើយថា វេទិកាថ្នាក់រៀននេះបានបង្ហាញពីប្រវត្តិសាស្ត្រ និងការរស់នៅរបស់ប្រជាជនខ្មែរក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ចំពោះវិធីសាស្ត្រដើម្បីកុំឲ្យរបបនេះកើតឡើងម្តងទៀត ប្រជាជនត្រូវហ៊ានប្រឆាំងចំពោះរបបផ្តាច់ការ និងមួយទៀតត្រូវដោះស្រាយបញ្ហាដោយសន្តិវិធី។ ខ្ញុំចង់ឲ្យមជ្ឈមណ្ឌលឯកសារកម្ពុជា ជួយផ្សព្វផ្សាយឲ្យបានទូលាយដល់សិស្សនៅតាមវិទ្យាល័យ ដើម្បីឲ្យសិស្សទាំងអស់បានយល់ដឹងប្រវត្តិសាស្ត្ររបស់ខ្មែរឲ្យកាន់តែស៊ីជម្រៅ។

គា ស្រីឡា ភេទស្រី អាយុ១៨ឆ្នាំ ជាសិស្សនៃវិទ្យាល័យ ព្រៃទប់ បានឆ្លើយថា “វេទិកាថ្នាក់រៀន នេះបានធ្វើឲ្យនាងខ្ញុំបានដឹងអំពីការធ្វើទារុណកម្មរបស់ខ្មែរក្រហមទៅលើប្រជាជន, ការប្រើឲ្យធ្វើការហួសកម្លាំង និងការហូបបាយមិនគ្រប់គ្រាន់ជាដើម។ ក្នុងការទប់ស្កាត់របបប្រល័យពូជសាសន៍ យុវជនគួរតែស្វែងយល់អំពីប្រវត្តិសាស្ត្រឲ្យបានច្រើន គោរពសិទ្ធិមនុស្សមិនរើសអើងពូជសាសន៍និងមិនត្រូវជឿលើការឃោសនារបស់អ្នកនយោបាយងាយៗពេកនោះទេ។

មុននឹងត្រឡប់ទៅកាន់គេហដ្ឋានរៀងៗខ្លួនវិញ សិស្សានុសិស្សទាំងអស់ បានឈរថតរូបជុំគ្នាជាមួយនឹងគ្រូដែលបានបង្រៀនអំពីប្រវត្តិសាស្ត្រមួយព្រឹកនេះ ជាមួយគ្រូនាយកនៃវិទ្យាល័យ ព្រៃទប់ដឹកនាំ និងក្រុមការងាររបស់មជ្ឈមណ្ឌលឯកសារខេត្តតាកែវ នៅពីមុនផ្ទាំងពិព័រណ៍ធំមួយ ស្ថិតនៅ ខាងក្នុងបណ្ណាល័យឯកសារខ្មែរក្រហម។



សិស្សានុសិស្សវិទ្យាល័យព្រៃទប់និងក្រុមការងារមជ្ឈ-មណ្ឌលឯកសារកម្ពុជាដែលបានចូលរួមវេទិកាថ្នាក់រៀន នៅក្នុងការិយាល័យស្រាវជ្រាវ និងបណ្ណាល័យឯកសារខ្មែរក្រហម នៃមជ្ឈមណ្ឌលគរុកោសល្យភូមិភាគតាកែវ។ (ហៀក ស្រីពេជ្រ/ មជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យលើកទី៧០

## នៅមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង

ផេង ពន្ធរ៉ាស៊ី



*គ្រូខ ទ្មុសធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យទៅកាន់សិស្សានុសិស្ស។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)*

មជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង ដែលមានទីតាំងស្ថិតនៅក្នុងបរិវេណមជ្ឈមណ្ឌលគរុកោសល្យភូមិភាគ ខេត្តព្រៃវែង នៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២២ បានរៀបចំវេទិកាថ្នាក់រៀនលើកទី៧០ របស់ខ្លួនជាមួយសិស្សានុសិស្សចំនួន៣៦នាក់ (ស្រី៣៨នាក់) មកពីវិទ្យាល័យ មេសាង ស្រុកមេសាង ខេត្តព្រៃវែង។ វិទ្យាល័យ មេសាង គឺជាវិទ្យាល័យមួយដែលទទួលបានការតម្លើងផ្ទាំងពាក្យស្លោកអប់រំ ស្តីពីការបងចាំប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ពីមជ្ឈមណ្ឌលឯកសារកម្ពុជា កាលពីឆ្នាំ២០១៨កន្លងមក។ ការតម្លើងផ្ទាំងពាក្យស្លោកនេះ ត្រូវបានធ្វើឡើងជាមួយគ្នានឹងការរុករកអដ្ឋិធាតុជនរងគ្រោះដែលត្រូវបានសម្លាប់ក្នុងរបបខ្មែរក្រហម ពីក្រុមអ្នកជំនាញរុករកអដ្ឋិធាតុក្រោមដីតាមរយៈម៉ាស៊ីនស្កេននៃក្រុមហ៊ុនស្ប៊្រារ៉ូហក។ កាលពីមុនខែមករា ឆ្នាំ១៩៧៩ បរិវេណវិទ្យាល័យ មេសាង គឺជាទីតាំងសម្លាប់មនុស្សរបស់ខ្មែរក្រហម។ អ្នកទោសខ្មែរក្រហម ត្រូវបានបណ្តើរ

ចេញពីមន្ទីរឃុំឃាំងក្នុងបរិវេណវត្តដីដុះ ដែលមានចម្ងាយប្រមាណ២០០ម៉ែត្រប៉ុណ្ណោះ យកមកសម្លាប់នៅក្នុងរណ្តៅចំនួន៦ ដែលត្រូវបានរកឃើញដោយម៉ាស៊ីនស្តូនរបស់ក្រុមហ៊ុន ស៊ីប្រារ៉ូហក។ នៅក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ ទីតាំងសម្លាប់នេះ ត្រូវបានបោសសម្អាត និងប្រែក្លាយទៅជាទីតាំងសម្រាប់អប់រំវិញ។ វិទ្យាល័យ មេសាង នាពេលបច្ចុប្បន្នគឺចាប់ផ្តើមកសាងតាំងពីពេលនោះមក។ ពីមួយឆ្នាំទៅមួយឆ្នាំ សិស្សានុសិស្សរាប់ពាន់នាក់បានចុះឈ្មោះចូលរៀននៅក្នុងវិទ្យាល័យនេះ ហើយសិស្សថ្នាក់ទី១២ ភាគច្រើន ត្រូវបានណែនាំឲ្យដឹងពីទីតាំងសម្លាប់នៅក្នុងបរិវេណវិទ្យាល័យដែលខ្លួនកំពុងសិក្សា តាមរយៈការពន្យល់ និងបង្ហាញពីគ្រូបង្រៀនប្រវត្តិវិទ្យាដែលធ្លាប់ចូលរួមក្នុងវគ្គបណ្តុះបណ្តាលគ្រូបង្រៀន រៀបចំដោយមជ្ឈមណ្ឌលឯកសារកម្ពុជា និងក្រសួងអប់រំ យុវជន និងកីឡា។



សិស្សានុសិស្សសរសេរសំណួរលើក្តារខៀនមុនពេលគ្រូខុទ្ទេសចាប់ផ្តើមបង្រៀន។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

**នៅក្នុងវេទិកាថ្នាក់រៀននេះត្រូវបានបែងចែកសកម្មភាពដូចតទៅ ៖**

១) សិស្សានុសិស្ស ត្រូវបានណែនាំឲ្យដឹងពីការបង្កើតមជ្ឈមណ្ឌលឯកសារខ្មែរក្រហម ដើម្បីការចងក្រង និងផ្សព្វផ្សាយពីឯកសារប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ សម្រាប់ជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការស្វែងយល់ និងចងចាំពីប្រវត្តិសាស្ត្រនេះ។



គ្រូខុទ្ទេស, គ្រូដឹកនាំ, ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តព្រៃវែង និងសិស្សានុសិស្សថតរូបជុំគ្នា។
(បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

២) តារាងស្ទាបស្ទង់មតិ (មុនពេលធ្វើវេទិកាថ្នាក់រៀន) ចំនួន ៣៦ ច្បាប់ ត្រូវបានចែកទៅកាន់សិស្សានុសិស្សទាំងអស់ដើម្បីបំពេញ ក្នុងគោលបំណងវាស់ស្ទង់ចំណេះដឹងពីមុនអំពីប្រវត្តិសាស្ត្រខ្មែរក្រហម។ តារាងស្ទាបស្ទង់មតិនេះ មានសំណួរចំនួន ១២ ដែលត្រូវបានបែងចែកជាបីផ្នែកធំៗ គឺ ក) ចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ។ ខ) ចំណេះដឹងអំពីនិយមន័យ និងកត្តាគ្រោះថ្នាក់ជាក់លាក់ដែលនាំឲ្យកើតមានអំពើឃោរឃៅក្នុងពិភពលោក និង គ) ចំណេះដឹងអំពីវិធីសាស្ត្រក្នុងការចូលរួមទប់ស្កាត់អំពើហិង្សា ឬអំពើប្រល័យពូជសាសន៍។

៣) គ្រូខុទ្ទេសបានផ្តល់ពេលវេលាចំនួន២០នាទីដល់ក្រុមសិស្សទាំងអស់ ក្នុងការសួរសំណួរអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ មុនការធ្វើបទបង្ហាញខ្លីអំពីប្រវត្តិសាស្ត្រនេះ។ ទម្រង់នៃការសួរសំណួររបស់សិស្ស គឺជាទម្រង់នៃការឡើងមកសរសេរសំណួរនៅលើក្រដាសផ្ទាំងធំមួយ ដែលស្ថិតនៅចំពីមុខតុសិស្សទាំងអស់។ មិនមានសិស្សានុសិស្សច្រើននាក់ទេ ដែលបានឡើងមកសរសេរ



សិស្សានុសិស្សលើកដៃសួរសំណួរបន្ទាប់ពីគ្រូខ្ទេសធ្វើបទបង្ហាញចប់។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)



សំណួរដែលខ្លួនឆ្ងល់យូរណាស់មកហើយ នៅលើផ្ទាំងក្រដាសធំនេះ។

មូលហេតុនៃការផ្តើមឲ្យមានការសួរសំណួរមុនការបង្រៀននេះគឺ ទី១) ទាញអារម្មណ៍ និងការគិតរបស់សិស្សមកផ្តោតលើអំឡុងពេលនៃរបបខ្មែរក្រហម។ ទី២) ផ្តល់ឱកាសដល់សិស្សដែលមានចម្ងល់ជាយូរមកហើយអំពីប្រវត្តិសាស្ត្រខ្មែរក្រហមដែលខ្លួនមិនដឹងសួរទៅកាន់នរណាដើម្បីទទួលបានចម្លើយ។ ទី៣) អាចជាឱកាសនៃការសួរសំណួរពិបាកៗដែលគ្រូរបស់ខ្លួនមិនទាន់រកចម្លើយឲ្យខ្លួនបាន។ តាមរយៈសំណួរដែលសិស្សានុសិស្សបានសួរ មានសំណួរខ្លះត្រូវការចម្លើយរហូតដល់ទៅពីរម៉ោងឬច្រើនជាងនេះ។ ឧទាហរណ៍៖ សិស្សស្រីម្នាក់បានស្នើឲ្យគ្រូខ្ទេសពន្យល់រៀបរាប់ពីព្រឹត្តិការណ៍ទាំងអស់ដែលបានកើតឡើងក្នុងរបបខ្មែរក្រហម។ លើសពីនេះទៀត សិស្សស្រីម្នាក់ទៀតបានសួរពីវិធីសាស្ត្របែបណាដែលអាចទប់ស្កាត់អំពើប្រល័យពូជសាសន៍បាន។ សំណួរទាំងពីរនេះ គឺជាប្រធានបទដែលគ្រូខ្ទេសនឹងត្រូវលើកយកមកធ្វើបទបង្ហាញក្នុងអំឡុងពេលនៃវេទិកាថ្នាក់រៀននាពេលនេះ។

៤) គ្រូខ្ទេសបានចំណាយពេលវេលាប្រហែលមួយម៉ោងកន្លះ សម្រាប់ការធ្វើបទបង្ហាញពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)។ ការធ្វើបទបង្ហាញ បានចាប់ផ្តើមពីការពន្យល់ពាក្យ «ខ្មែរក្រហម» ដែលជាពាក្យហៅដំបូងដោយសម្តេចព្រះនរោត្តម សីហនុ ហើយត្រូវទស្សនាវដ្តីអ្នកជាតិនិយមយកមកចុះផ្សាយនៅក្នុងឆ្នាំ១៩៦៧ និងបញ្ចប់ដោយការបង្ហាញពីផលប៉ះពាល់នៃរបបខ្មែរក្រហម មកលើប្រជាជនទូទៅ និងប្រទេសជាតិ ជាពិសេសជំងឺបាក់ស្បាតដែលនៅតែបន្តកើតមានចំពោះអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនាពេលបច្ចុប្បន្ននេះ។

៥) ខ្សែវីដេអូឯកសារខ្លី ដែលមានរយៈពេលតែប្រាំមួយនាទី មានចំណងជើងថា «កុមារកម្ពុជា» ត្រូវបានដាក់បញ្ចាំងបន្ទាប់ពីការធ្វើបទបង្ហាញរបស់គ្រូខ្ទេស។ ខ្សែវីដេអូនេះ បង្ហាញអំពីដំណើរគ្មានគោលដៅរបស់ក្មេងកំព្រាទាំងឡាយដែលឪពុកម្តាយ និងបងប្អូនបានស្លាប់ចោលអស់។ ក្នុងដំណើរផ្សងព្រេងនេះ សិស្សានុសិស្សបានសង្កេតឃើញពីភាពគ្មានអនាម័យក្នុងការហូបចុក និងរស់នៅរបស់ក្មេង ព្រមទាំងបានឃើញពីជីវិតតែលតោលគ្មានគោលដៅ ដែលដំណើរទាំងនេះបានឆ្លុះបញ្ចាំងឲ្យឃើញពីភាពដែលមិនអាចទទួលយកបាននាពេលបច្ចុប្បន្ននេះ ពីសំណាក់ក្មេងៗជំនាន់ក្រោយ។ ខ្សែ

វីដេអូនេះ ក៏ជាភស្តុតាងបញ្ជាក់ និងជាមេរៀនជីវិតរបស់ក្មេងៗជំនាន់មុន ដែលក្មេងៗជំនាន់នេះបានបង្ហាញពីភាពអាណិតអាសូរចំពោះសោកនាដកម្មនានាដែលបានកើតមានចំពោះក្មេងៗក្នុងសម័យខ្មែរក្រហម។ វីដេអូនេះ ក៏ជាផ្នែកមួយដែលបំផុសឲ្យក្មេងៗជំនាន់ក្រោយ ឲ្យរិះរកវិធីទប់ស្កាត់កុំឲ្យរបបខ្មែរក្រហមវិលត្រឡប់មកជាលើកទីពីរទៀត។

៦) បន្ទាប់ពីផ្តល់ពេលវេលាខ្លីសម្រាប់សិស្សានុសិស្សសម្រាក គ្រូខុទ្ទេសបានចាប់ផ្តើមការធ្វើបទបង្ហាញរបស់ខ្លួនបន្តទៀត ដោយផ្តោតលើផ្នែកសំខាន់ពីរគឺ ១) និយមន័យនៃអំពើឧក្រិដ្ឋឃោរឃៅ (រួមមានឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម) និងឧទាហរណ៍ជាក់លាក់មួយចំនួនដែលនាំឲ្យកើតមានឧក្រិដ្ឋកម្មឃោរឃៅទាំងឡាយ។ ២) ការបង្ហាញពីវិធីសាស្ត្រជាក់លាក់ចំនួនពីរ ក្នុងការចូលរួមទប់ស្កាត់អំពើឃោរឃៅ ឬអំពើប្រល័យពូជសាសន៍ក្នុងកម្រិតបុគ្គល គ្រួសារ ឬសហគមន៍ និងកម្រិតប្រទេសជាតិ។

៧) សិស្សានុសិស្សទាំងអស់ ត្រូវបានលើកទឹកចិត្តឲ្យបំពេញតារាងស្ទាបស្ទង់មតិ (ក្រោយពេលធ្វើវេទិកាថ្នាក់រៀន) ម្តងទៀត ដើម្បីស្វែងយល់ពីចំណេះដឹងកើនឡើងក្រោយពេលដែលខ្លួនបានចូលរួមក្នុងសកម្មភាពវេទិកាថ្នាក់រៀនរយៈពេលបីម៉ោងរួចមក។ លើកនេះ សិស្សានុសិស្សបានចំណាយពេលវេលាច្រើនជាងកន្លះម៉ោង ក្នុងការបំពេញតារាងស្ទាបស្ទង់មតិនេះ ព្រោះថា មានសំណួរមួយចំនួនទាមទារឲ្យសិស្សានុសិស្សសរសេររៀបរាប់ពីចំណេះដឹងដែលខ្លួនបានសិក្សាថ្មីៗពីក្នុងកម្មវិធីវេទិកាថ្នាក់រៀន ពីគំនិតយល់ឃើញនានារបស់ខ្លួនអំពីវិធីសាស្ត្រផ្ទាល់ខ្លួនក្នុងការចូលរួមទប់ស្កាត់អំពើហិង្សា និងពីគំនិតឆ្លុះបញ្ចាំងពីដំណោះស្រាយចំពោះការកើតឡើងនូវអំពើហិង្សានៅក្នុងសហគមន៍ ដែលខ្លួនគួរមាន និងដោះស្រាយ ក្នុងករណីដែលមានអំពើហិង្សាកើតឡើងមែន។

៨) ចុងបញ្ចប់នៃកម្មវិធីវេទិកាថ្នាក់រៀន សិស្សានុសិស្សទាំងអស់ទទួលបានសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពលើកទី២ ម្នាក់មួយច្បាប់ ដើម្បីទុកជាឯកសារស្រាវជ្រាវ និងរៀនសូត្របន្ថែមមុនពេលដែលខ្លួននឹងត្រូវចូលរួមប្រឡងប្រជែងបញ្ចប់ថ្នាក់មធ្យមសិក្សាទុតិយភូមិនាពេលប៉ុន្មានខែខាងមុខនេះ។

៩) មុននឹងត្រឡប់ទៅកាន់គេហដ្ឋានរៀងៗខ្លួនវិញ សិស្សានុសិស្សទាំងអស់បានឈរថតរូបជុំគ្នាជាមួយនឹងគ្រូខុទ្ទេស គ្រូដឹកនាំ និងក្រុមការងាររបស់មជ្ឈ-មណ្ឌលឯកសារខេត្តព្រៃវែង នៅពីមុនផ្ទាំងពិព័រណ៍ធំមួយ ស្ថិតនៅខាងក្នុងបរិវេណការិយាល័យមជ្ឈ-មណ្ឌលមណ្ឌលឯកសារខេត្តព្រៃវែង។ ចំពោះបញ្ហាប្រឈម សិស្សានុសិស្សមួយចំនួនតូច បានបង្ហាញឲ្យឃើញពីភាពអស់កម្លាំង និងងងុយដេកក្នុងពេលស្តាប់ការធ្វើបទបង្ហាញ។ ទោះបីជាយ៉ាងណាក៏ដោយ ក៏សិស្សានុសិស្សភាគច្រើនលើសលុប បានបង្ហាញឲ្យឃើញពីការយកចិត្តទុកដាក់ខ្ពស់ក្នុងការត្រងត្រាប់ស្តាប់ការពន្យល់របស់គ្រូខុទ្ទេស។ ការធ្វើវេទិកាថ្នាក់រៀនរបស់យើង គឺចាប់ផ្តើមនៅម៉ោងមួយកន្លះរសៀល និងបញ្ចប់នៅម៉ោង៥រសៀលថ្ងៃដដែល។



សិស្សានុសិស្សបំពេញតារាងវាស់ស្ទង់ចំណេះដឹងមុនពេលសិក្សា។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

# វេទិកាថ្នាក់រៀនស្ដីអំពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ(១៩៧៥-១៩៧៩)»

## នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម

ទូច វណ្ណេត និង មេន នឿន




លោក ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា ធ្វើបទបង្ហាញស្ដីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) ដល់សិស្សានុសិស្សៗ (អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម)

នៅរសៀលថ្ងៃអាទិត្យ ទី៦ ខែមីនា ឆ្នាំ២០២២ មជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំវេទិកាថ្នាក់រៀនស្ដីពី៖ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» ដោយមានការចូលរួមពីសិស្សានុសិស្សសរុបចំនួន២០នាក់ (ស្រី១១នាក់ និងប្រុស៩នាក់) មកពីវិទ្យាល័យតាមាង វិទ្យាល័យពាមជីកង និងវិទ្យាល័យព្រះសីហនុ។ វេទិកាថ្នាក់រៀននេះ ប្រារព្ធធ្វើឡើងនៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម វេលាម៉ោង១:៣០រសៀលរដល់ម៉ោង៤:៣០រសៀល ដោយអនុវត្តតាមវិធានការការពារ រួមមាន ការវាស់កម្ដៅ ការពាក់ម៉ាស់ ការសម្អាតដៃឲ្យបានស្អាតជាមួយអាកុល ការរក្សាគម្លាតសុវត្ថិភាព និងការបើកទ្វារបង្អួចឲ្យមានខ្យល់ចេញចូលគ្រប់គ្រាន់។

វេទិកាថ្នាក់រៀននេះ ធ្វើឡើងក្នុងគោលបំណងដើម្បីឲ្យសិស្សានុសិស្សទទួលបានចំណេះដឹងអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងផ្ដល់ឱកាសក្នុងការពិភាក្សា និងការជជែកវែកញែកពិចារណានូវអ្វីដែលខ្លួនបានដឹង និងធ្លាប់បានរៀនអំពីប្រវត្តិសាស្ត្រខ្មែរក្រហមកន្លងមក។ ដើម្បីសម្រេចគោលបំណងនេះ ក្រុមការងារ និងអ្នកស្ម័គ្រចិត្តនៃមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម រៀបចំកម្មវិធីមួយចំនួនបន្ថែមទៀត រួមមាន ការបង្ហាញពិព័រណ៍អចិន្ត្រៃយ៍អំពីមេ

ដឹកនាំខ្មែរក្រហម និងការជម្លៀសប្រជាជនពីទីក្រុងភ្នំពេញ និងពិព័រណ៍រូបថតអំពីរឿងរ៉ាវអ្នករស់រានមានជីវិតពីរបបខ្មែរក្រហម និងសកម្មភាពការងាររបស់ស្ម័គ្រចិត្តកម្ពុជាចុះជួបអ្នករស់រានមានជីវិតពីរបបខ្មែរក្រហមនៅមូលដ្ឋានការធ្វើបទបង្ហាញទៅលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ការចាក់បញ្ចាំងវីដេអូឯកសារអំពីរបបខ្មែរក្រហម និងការចែកសៀវភៅស្តីអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បោះពុម្ពលើកទី២។

ជាកិច្ចចាប់ផ្តើម លោក ស៊ាង ចិន្តា នាយកមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ស្វាគមន៍ដល់វាគ្មិន និងសិស្សានុសិស្ស ដែលចូលរួមវេទិកាថ្នាក់រៀននេះ និងអំពីសារសំខាន់នៃការសិក្សាអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ ព្រមទាំងការបង្កើតឡើងនូវមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ដែលមានតម្កល់ឯកសារយ៉ាងសម្បូរបែបទាក់ទងរបបខ្មែរក្រហម និងផ្តល់កម្មវិធីអប់រំប្រវត្តិសាស្ត្រខ្មែរក្រហម។

បន្ទាប់មកលោកគ្រូ ផេង ពង្សរ៉ាស៊ី នាយកកម្មវិធីអប់រំពីអំពើប្រល័យពូជសាសន៍នៅកម្ពុជា បានចាប់ផ្តើមធ្វើបទបង្ហាញទៅលើប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) និងលើកសំណួរចំនួន៣ដើម្បីបញ្ជាក់កម្រិតនៃការយល់ដឹងរបស់សិស្សអំពីរបបខ្មែរក្រហម។ បន្ទាប់ពីទទួលបានចម្លើយផ្សេងៗពីសិស្ស លោកគ្រូ រ៉ាស៊ី ពន្យល់អំពីរចនាសម្ព័ន្ធរបស់ខ្មែរក្រហម និងគោលនយោបាយដែលមានស្រាប់នៅក្នុងបទបង្ហាញ និងឯកសាររូបថតនៅលើផ្ទាំងស្លាយ។ សិស្សានុសិស្សទាំងអស់ស្តាប់និងកត់ត្រាយ៉ាងយកចិត្តទុកដាក់លើបទបង្ហាញរបស់វាគ្មិន។ តមក លោកគ្រូ រ៉ាស៊ី ចាក់បញ្ចាំងវីដេអូឯកសារដែលមានចំណងជើងថា «កុមារកម្ពុជា»។ វីដេអូឯកសារនេះត្រូវបានថតភ្លាមៗបន្ទាប់ពីឆ្នាំ១៩៧៩ ដែលឆ្លុះបញ្ចាំងពីទិដ្ឋភាពកុមារក្នុងប្រទេសកម្ពុជាបន្ទាប់ពីរបបខ្មែរក្រហមដួលរលំ។

បន្ទាប់ពីបទបង្ហាញបានបញ្ចប់ ក្រុមការងារមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម ចែកសៀវភៅប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតយ្យ (ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) បោះពុម្ពលើកទី២ ដល់សិស្សានុសិស្សដើម្បីអាន និងសិក្សាឈ្វេងយល់បន្ថែមទៀត។



សិស្សានុសិស្សមកពីវិទ្យាល័យតាមាង វិទ្យាល័យពាមជីកង និងវិទ្យាល័យព្រះសីហនុ ចូលរួមវេទិកាថ្នាក់រៀនស្តីពី «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម)

**ហុក លក្ខិណា** ភេទស្រី គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យតាមាង បានរៀបរាប់ថា ខ្លួនបានដឹងខ្លះៗអំពីរបបខ្មែរក្រហមតាមរយៈការសិក្សានៅសាលា។ បន្ទាប់ពីការចូលរួមវេទិកាថ្នាក់រៀននេះ លក្ខិណាទទួលបានចំណេះដឹងជាច្រើនអំពីប្រវត្តិសាស្ត្រកម្ពុជាប្រធិបតេយ្យ និងការបញ្ឈប់ការរើសអើងពូជសាសន៍។ ជាចុងក្រោយ លក្ខិណា បានបញ្ជាក់ទៀតថា «ការការពារកុំឲ្យកើតឡើងអំពើហិង្សា និងអំពើប្រល័យពូជសាសន៍គឺមានសារសំខាន់ណាស់ដើម្បីរក្សាសន្តិភាពសង្គម និងប្រទេស»។



ហុក លក្ខិណា ភេទស្រី សិស្សថ្នាក់ទី១២នៃវិទ្យាល័យតាមាង។ (អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម)

**អាន ស្រីដូ** ភេទស្រី គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យតាមាង បានបង្ហាញចំណាប់អារម្មណ៍ថា «ខ្ញុំយល់ដឹងបន្ថែមអំពីរបបកម្ពុជាប្រជាធិបតេយ្យ និងកាន់តែយល់ច្បាស់ពីនិយមន័យរបស់អំពើប្រល័យពូជសាសន៍។ របបប្រល័យពូជសាសន៍បំផ្លិចបំផ្លាញសង្គមជាតិខ្មែរឲ្យធ្លាក់ដុនដាប។ បន្ទាប់ពីស្តាប់បទបង្ហាញរបស់លោកគ្រូ វ៉ា សុី ខ្ញុំយល់ថាការការពារអំពើប្រល័យពូជសាសន៍កុំឲ្យកើតឡើងគឺពិតជាមានសារសំខាន់ខ្លាំងណាស់។ យើងត្រូវបញ្ឈប់ការរើសអើងពូជសាសន៍ និងការបញ្ឈប់អំពើហិង្សាគ្រប់រូបភាព។»



អាន ស្រីដូ ភេទស្រី សិស្សថ្នាក់ទី១២នៃវិទ្យាល័យតាមាង។(អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម)

**ហែល លាងហុង** ភេទប្រុស គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យព្រះសីហនុ បានចែករំលែកចំណេះដឹងដែលខ្លួនទទួលបាននៅក្នុងវេទិកាថ្នាក់រៀននេះថា៖

ទី១) ខ្ញុំបានយល់ដឹងបន្ថែមអំពីរបបខ្មែរក្រហម និងមិនចង់ឲ្យប្រទេសកម្ពុជាមានស្ថានភាពដូចពេលនោះទៀតឡើយ។

ទី២) ខ្ញុំបានឃើញរាល់សកម្មភាពនៃការលុបបំបាត់វណ្ណៈ ភាពគ្មានសិទ្ធិសេរីភាព ការហូបបាយរួម ការកាប់សម្លាប់ នៅក្នុងរបបខ្មែរក្រហម ចេញពីការធ្វើបទបង្ហាញអំពីប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ និងការដាក់តាំងពិព័រណ៍រូបថតអំពីរឿងរ៉ាវរបស់អ្នករស់រានមានជីវិតពីរបបខ្មែរក្រហម។

ទី៣) ប្រទេសកម្ពុជាបានធ្លាក់ចូលក្នុងភ្លើងសង្គ្រាម និងអំពើប្រល័យពូជសាសន៍។ ខ្ញុំពេញចិត្តចំពោះសន្តិភាពនាពេលបច្ចុប្បន្ន និងមិនចង់ឃើញសង្គ្រាម។ ខ្ញុំនឹងខិតខំរៀនសូត្រដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ប្រទេសជាតិ។

**ម៉ន សុចិត្រា** ភេទប្រុស គឺជាសិស្សថ្នាក់ទី១២នៃវិទ្យាល័យ ហ៊ុនសែនពាមជីកងបានបង្ហាញអំពីចំណាប់អារម្មណ៍របស់ខ្លួនបន្ទាប់ពីចូលរួមវេទិកាថ្នាក់រៀននេះថា៖

- ខ្ញុំទទួលបានចំណេះបន្ថែមអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងយល់ច្បាស់ពីផលប៉ះពាល់ដល់គ្រួសារ និងសង្គមជាតិ ដែលត្រូវបានបំផ្លិចបំផ្លាញដោយរបបនេះ។

- ខ្ញុំយល់ដឹងអំពីវិធីសាស្ត្រក្នុងការការពារកុំឲ្យអំពើប្រល័យពូជសាសន៍កើតឡើងតាមរយៈការបញ្ឈប់ការរើសអើង និងការទប់ស្កាត់អំពើហិង្សា។
- ខ្ញុំនឹងចែករំលែកចំណេះដឹងអំពីប្រវត្តិសាស្ត្រខ្មែរក្រហម និងចូលរួមផ្សព្វផ្សាយបន្ថែមទៀតនៅក្នុងថ្នាក់រៀន និងភូមិរបស់ខ្ញុំ។



សិស្សានុសិស្សមកពីវិទ្យាល័យតាមាង វិទ្យាល័យពាមជីកង និងវិទ្យាល័យព្រះសីហនុ ចូលរួមវេទិកាថ្នាក់រៀនស្ដីពី៖ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម)



សិស្សានុសិស្សមកពីវិទ្យាល័យតាមាង វិទ្យាល័យពាមជីកង និងវិទ្យាល័យព្រះសីហនុ ចូលរួមវេទិកាថ្នាក់រៀនស្ដីពី៖ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម)

សិស្សានុសិស្សមកពីវិទ្យាល័យតាមាង វិទ្យាល័យពាមជីកង និងវិទ្យាល័យព្រះសីហនុ ចូលរួមវេទិកាថ្នាក់រៀនស្ដីពី៖ «ប្រវត្តិសាស្ត្រកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)» នៅមជ្ឈមណ្ឌលឯកសារខេត្តកំពង់ចាម។ (អ្នកស្ម័គ្រចិត្តកម្ពុជាខេត្តកំពង់ចាម)



# ចោរលួចបាយក្តាំង
# វ៉ៃកឆាចបដឹក មេចុងភៅបដិវត្តន៍ (ត)

ដោយអត់ទ្រាំការស្រេកឃ្លានមិនបាន ខ្ញុំក៏ងើបទៅបើកហិបបន្ទុំផ្លែខេមា រាវរកផ្លែដែលទុំ តែត្រូវខកចិត្តដោយមិនមានផ្លែណាមួយទុំឡើយ។ ពេលនោះយាយពោលមកកាន់ខ្ញុំថា “ចៅឃ្លានមែនទេ?” ខ្ញុំតបវិញថា“មិនអីទេយាយ។” យាយដឹងចិត្តចៅ យកផ្លែមួយដែលទុំពីក្បាលដំណេករបស់គាត់មកឲ្យខ្ញុំ ហើយនិយាយថា “នែចៅ ហូបអានេះទៅ” ខ្ញុំយកមកទំពាហូបយ៉ាងឆ្ងាញ់ តែវាចាញ់ការឈឺចាប់ផ្លូវចិត្ត និងរបួសក្បាល។ ខ្ញុំខំបិទភ្នែកសំងំដេកបំភ្លេចនូវទុក្ខកង្វល់ទាំងឡាយដែលកើតមានឡើងទាំងអម្បាលម៉ាននៃខ្សែជីវិតក្មេងកំព្រាក្នុងវាលវដ្តសង្សារមហាធំធេងវង្វេងកោះត្រើយនេះ។

សំណល់ទឹកភ្នែកជាសម្រែកដួងចិត្តជិតក្នុងអារម្មណ៍ឲ្យខ្លោចផ្សា។ តើមាននរណាខ្លះអភ័ព្វដូចគ្រួសារខ្ញុំ? ក្នុងចិត្តខំរើបម្រះដោះស្រាយចំណងកម្មឲ្យរួចផុត បានធូរស្បើយ។ យប់ថ្ងៃគេងឱបតែទុក្ខកង្វល់។

ខ្ញុំយកដៃគងថ្ងាស ខំប្រឹងសំងំដេកឲ្យវាលក់ តែភ្នក់ភ្លើងនៅតែឆេះក្នុងចិត្ត ដោយសារការធ្វើទារុណកម្ម ទាំងផ្លូវកាយ ផ្លូវចិត្ត ធ្វើឲ្យនឿយហត់ ខ្ញុំក៏លង់លក់ក្នុងស្បៃរាត្រីទាំងរបួសដួងចិត្ត និងរបួសក្បាលឈឺពើតផ្សា ដែលមិនអាចហាប្រាប់អ្នកណាបាន ព្រោះកាយ និងចិត្តត្រូវរងគ្រោះក្រោមស្នាដៃកម្មាភិបាល មេកងនារីកុមារ និងចុងភៅរបស់អង្គការបដិវត្តន៍៕

---

# ៥. ការសម្រេចចិត្តពុះគ្រួសារជាពីរ

## របបខ្មៅរុញច្រានបង្កងវាសនាគ្រួសារ

### ជីវិតក្រោមនឹមទឹកភ្នែកនៃបដិវត្តន៍

យប់ថ្ងៃ ថ្ងៃយប់ចេះតែកន្លងទៅ ជីវិតរស់នៅក្នុងរបបអាវខ្មៅ គឺជាជីវិតផុយស្រួយ និងភិតភ័យគ្រប់ពេលវេលា ព្រោះមិនដឹងថាត្រូវអង្គការយកទៅសម្លាប់នៅពេលណាឡើយ។

គ្រប់គ្នារស់នៅទាំងគ្មានអារម្មណ៍ ហាក់ដូចជាស្លាប់ពាក់កណ្តាលខ្លួន។ ការងារមានជាប្រចាំគ្មានពេលទំនេរ បើសម្រាកពេលហូបបាយ គឺមានបន្ថែមការងារផ្សេងៗ ឬចូលរួមប្រជុំជីវភាព ស្តាប់កម្មាភិបាលខ្មែរក្រហមនិយាយឃោសនាអប់រំគោលនយោបាយ និងមនោគមវិជ្ជារបស់គេ សួរដេញដោលពីទោសកំហុសនយោបាយ ថ្កោលទោសប្រជាជនដទៃទៀតដែលធ្វើខុសពិន័យ ដោយធ្វើស៊ុយទិតៀនចំពោះខ្លួនឯងនូវកំហុសទាំងឡាយ។ បន្ទាប់មកមានការកោតសរសើរទះដៃអបអរសាទរពីកម្មាភិបាលខ្មែរក្រហមមេអង្គប្រជុំថាយើងជាប្រជាជនគំរូខំកសាងខ្លួនដោយខ្លួនឯង ប៉ុន្តែក្រោយមកអ្នកទាំងនោះត្រូវគេយកទៅសម្លាប់ចោលដដែល។

សម្រាប់កុមារ គឺគ្មានអ្វីក្រៅពីការងារចាំគោ ចាំចាប ដែលអង្គការតម្រូវឲ្យធ្វើនោះទេ។ ត្រូវងើបពីព្រលឹមកើបអាចម៍គោ ហើយដឹកគោទៅចងជាមួយការភ័យខ្លាចតក់ស្លុតក្រោមក្រសែភ្នែកអង្គការភ្នែកម្នាស់ រង់ចាំ

ចាប់កំហុស និងចោទប្រកាន់ រាល់សកម្មភាព ថាយើងមិនស្មោះត្រង់នឹងបដិវត្តន៍ និងរង់ចាំតែថ្ងៃអង្គការយកទៅកសាងដោយចាត់ទុកយើងជាអ្នកទោសបដិវត្តន៍ប៉ុណ្ណោះ។

ម្យ៉ាងទៀតដោយសារតែគ្រួសារខ្ញុំជាអ្នក១៧ មេសា ដែលជាមុខសញ្ញាអង្គការបដិវត្តន៍ត្រូវកម្ទេចមុនគេ។

ខ្ញុំនៅចាំបានថា មុនពេលអង្គការចាត់តាំងឲ្យគ្រួសារខ្ញុំទៅនៅ ទួលស្វាំង ពេលយប់បានជួបជុំគ្រួសារក្រោយបំពេញការងារជាទម្ងន់លើសកម្លាំងជូនអង្គការបដិវត្តន៍ ហើយ ហូបតែបបរ ជួនកាលបានបាយមួយដងម្ដាល និងសម្លម្ជូរត្រកួនព្រលិតសុទ្ធតែទឹកស្ទើររាល់ថ្ងៃបបូរមាត់ និងធ្មេញពណ៌ខ្មៅស្វាយគ្រប់ៗគ្នា។

# កងឈ្លបយមរាជ អង្គការបដិវត្តន៍

## កងឈ្លបម្នាក់ យមរាជម្នាក់

នៅពេលយប់ស្ងាត់មុនចូលនិទ្រា ខ្ញុំសង្កេតឃើញឪពុកគាត់តែងតែអើតមើលទៅក្រោមតាមប្រហោងរនាបផ្ទះ ក្រែងលោមានកងឈ្លបលួចស្ដាប់យកការណ៍។ ប្រសិនបើយើងនិយាយអ្វីដែលប៉ះពាល់ដល់អង្គការបដិវត្តន៍ គេនឹងរាយការណ៍ជូនថ្នាក់លើភ្លាម។

ដោយមិនឃើញមាននរណាមួយ ឪពុកបានខ្សឹបប្រាប់ម្ដាយខ្ញុំជាសំឡេងខ្យល់ថា គ្រួសារអ្នកថ្មីនេះអ្នកថ្មីនោះត្រូវអង្គការឲ្យទៅរស់នៅទួលស្វាំង។ គាត់ខ្សឹបបណ្ដើរ អើតមើលទៅក្រោមបណ្ដើរ រួចគាត់បញ្ឈប់សំឡេង ដោយមានមនុស្សដើរចុះឡើងរង់ចាំស្ដាប់។

មួយស្របក់ក្រោយមកមនុស្សខោអាវខ្មៅចេញពីក្រោមផ្ទះ គាត់បន្តខ្សឹបប្រាប់ម្ដាយខ្ញុំ "គេចេញទៅវិញហើយ" ដោយដកដង្ហើមវែងមួយៗក្នុងចិត្តស្រណោះអស់សង្ឃឹម។ លោកឪពុកស្រងូតស្រងាត់មើលទៅមុខគាត់ គិតរួចនិយាយខ្សឹបៗ ហ៊ឺៗ គង់តែថ្ងៃណាមួយដល់វេនគ្រួសារយើងជាមិនខាន។ ម្ដាយខ្ញុំរលីងរលោងទឹកភ្នែកតបវិញថា "ពិតហើយមានគេលួចប្រាប់ខ្ញុំថា សូមឲ្យយើងប្រុងប្រយ័ត្ន អង្គការបដិវត្តន៍នឹងមិនលើកលែងទោសឲ្យទេ។ គេនឹងយកអ្នកថ្មីទៅសម្លាប់ ទាំងអស់ម្ដងមួយគ្រួសារៗ"។ ខ្ញុំស្ដាប់បានខ្លះមិនបានខ្លះ។ ឪពុកខ្ញុំតបទៅម្ដាយវិញ គិតថា គ្រួសារយើងមិនអ៊ីចុះ។

យប់ណាក៏ដូចយប់ណាដែរ លោកឪពុកអ្នកម្ដាយខ្ញុំតែងតែពិភាក្សាគ្នារកដំណោះស្រាយឲ្យគ្រួសារជៀសផុតពីគេយកទៅសម្លាប់ដោយសំឡេងខ្សាវៗ និងភ័យខ្លាចពីកងឈ្លបមកលួចស្ដាប់ ហើយរាយការណ៍ទៅអង្គការបដិវត្តន៍ថ្នាក់លើ។ ចង់មិនចង់ស្រេចតែកងឈ្លបជាអ្នកបកស្រាយ **កងឈ្លបម្នាក់ គឺជាយមរាជម្នាក់**។



ទិដ្ឋភាពៈ កងឈ្លបលបស៊ើបការណ៍នៅក្រោមផ្ទះខ្ញុំនៅពេលយប់ (ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិឃាដ)

# ចុតហ្មាយមច្ចុរាជ មេកងកម្មាភិបាលអង្គការបដិវត្តន៍

ជាការពិត កន្លងមិនបានប៉ុន្មានថ្ងៃផងពេលព្រលប់ងងឹតព្រាលៗ ក៏មាននីរសារម្នាក់ ស្លៀកពាក់ខោអាវខ្មៅបង់កក្រមា បណ្តើរកង់កញ្ចាស់អមជាមួយមេភូមិគណៈមុខព្រួយរោងបាយកណ្តាលចូលមកក្នុងផ្ទះ។

ពេលនោះខ្ញុំកំពុងបំពក់ភ្នក់ភ្លើងដើម្បីដេញមូសឲ្យមេគ្នោត។ មេភូមិនិងនីរសារសួររកឈ្មោះដោយបន្លឺថា "សមមិត្ត ឡុង និងសមមិត្តនារី ឆេង នៅទេ?" ឪពុកម្តាយអង្គុយលើកាំជណ្តើរស្ទុះទៅនិយាយកាន់គេថា"មានការអីឈ្មោះខ្ញុំនឹងហើយសមមិត្ត"។

និរសារនោះលូកយកក្រដាសសៀវភៅកញ្ចាស់ពណ៌ស៊ីម៉ងត៍មួយសន្លឹកបត់ជាបីបួនផ្នត់ចេញពីហោប៉ៅអាវហើយបើកលានៅចំពោះមុខឪពុកម្តាយខ្ញុំ។ បន្ទាប់មកគេបោះពាក្យសម្តីថា "ប្រធានមេកងសយ ដែលជាកម្មា-ភិបាលថ្នាក់លើចាត់តាំងឲ្យគ្រួសារសមមិត្តថ្មី ឡុង ទៅរស់នៅលើទួលស្វាំង នៅថ្ងៃស្អែកនេះ ដូច្នេះសមមិត្តឡុងឯងត្រូវរៀបចំខ្លួននិងធ្វើតាមបញ្ជាកម្មាភិបាលថ្នាក់លើនេះ។"

បន្ទាប់មកគេក៏ចេញទៅវិញ។ ឪពុកម្តាយខ្ញុំងាកមើលមុខគ្នាដោយទឹកមុខស្រពោនសង្រេក រួចគាត់នាំគ្នាឡើងទៅលើផ្ទះ។ មួយស្របក់ក្រោយមកខ្ញុំឡើងទៅតាមក្រោយឃើញគាត់កំពុងនិយាយ "រាយ"រាប់រឿង"រាវនោះប្រាប់ជីដូនជីតា និងបងស្រីខ្ញុំ។

គាត់គ្មានពាក្យអ្វីនឹងថ្លាថ្លែងដល់កូនទាំងពីរនោះឡើយ ក្រៅពីទឹកមុខស្រងូតស្រងាត់បង្កប់ដោយអារម្មណ៍ក្តុកក្តួលដាស់អន្ទ្រួនដួងចិត្តគ្រប់ៗគ្នាក្នុងជីវិតពោរពេញដោយទុក្ខសោកគ្មានពេលស្រាកស្រាន្ត។

**ឪពុកម្តាយកូន និងចៅ គឺជាគុកកម្មផ្លូវចិត្តនិងជីវិតទឹកភ្នែកលើទីលានថ្មុកឈាមបដិវត្តន៍ដ៏ខ្មៅងងឹតនេះ។**

គាត់ទាំងពីរនាក់មិនទាន់សម្រាន្តទេ គាត់នៅជជែកគ្នាជាសំឡេងខ្សឹបខ្សៀវ អើតមើលក្រោមបណ្តើរក្រែងលោមានកងឈ្លបមកលួចស្តាប់ទៀត ព្រោះជួបគ្នាក្នុងគ្រួសារមានតែពេលរាត្រីពេលថ្ងៃមកដល់បែកគ្នា ដោយជាប់បំពេញការងារដែលអង្គការថ្នាក់លើប្រគល់ឲ្យធ្វើរៀងៗខ្លួន។



ទិដ្ឋភាព៖ ឪពុកម្តាយខ្ញុំទទួលលិខិតមរណៈពីនិរសារឲ្យគ្រួសារខ្ញុំទៅរស់នៅទួលស្វាំងពិឃាដ ។ (ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិឃាដ)

# ទម្ងន់ទុក្ខសោកឪពុក

## ខ្សែចំណងជើងខោអត្តឃាត, គ្រូបង្រៀនខ្សែចក្រពត្តិ

ថ្ងៃណាក៏ដូចថ្ងៃណា, យប់ណាក៏ដូចយប់ណាដែរ! ជីវិតរស់នៅក្នុងសង្គមមានមេដឹកនាំជាបិសាចខ្មៅ តែងតែរុកកួននិងរកចាប់កំហុសជានិច្ច។ ពេលថ្ងៃតាមឃ្លាំមើលពីគណៈរោងបាយ ពេលយប់មានកងឈ្លបមកយកការណ៍នៅក្រោមផ្ទះដើម្បីចាប់កំហុសដាក់បន្ទុកបន្ថែមក្នុងការកម្ទេចគ្រួសារជាគ្រូបង្រៀនខ្សែចក្រពត្តិអាមេរិក។ រឿងហេតុទាំងនេះហើយដែលធ្វើឲ្យឪពុកខ្ញុំសែនចង្អៀតចិត្តក្រៃរកគិតអ្វីពុំយល់ដែលជាអម្រែកទម្ងន់ទុក្ខកង្វល់ស្ទើរឆ្កួតវង្វេងស្មារតី។ សេចក្តីសង្ឃឹមមានតិចតួចណាស់សម្រាប់គ្រួសារដែលមានទោសស្មើនឹងប្រហារជីវិតពេលនេះបានធ្លាក់មកដល់ហើយ។ នឹកអាណិតកូនតូចៗដែលគ្នានៅក្មេងមិនទាន់ដឹងអ្វីទាំងអស់។

ថ្ងៃមួយពេលដែលគណៈមុខព្រួញរោងបាយឲ្យឪពុកខ្ញុំទៅឃ្វាលក្របីនៅដើមជនៀងតាកុកព្រៃរនាមមាត់ស្ទឹងគ្រៀង ឪពុកខ្ញុំតែងតែលួចនិយាយជាមួយ ពូសារុន ដែលគេចាត់តាំងឲ្យទៅចាំក្របីជាមួយគ្នា។ ដោយមានការទុកចិត្តណាមួយពូ សារុនជាកូនសិស្សលោកតាជីនអតីតគ្រូសូត្រឆ្វេងស្តាំវត្តជ្រៃនិងជាព្រះ វិន័យធរស្រុកពារាំង។ ពេលនោះឪពុកខ្ញុំបាននិយាយប្រាប់ពូសារុនថា ក្មួយ! ពូជាគ្រូបង្រៀន ដូចច្នេះគ្រួសារពូត្រូវអង្គការចោទថាជាខ្សែពួកខ្មាំងចក្រពត្តិអាមេរិក។ គេនឹងយកគ្រួសារពូទៅសម្លាប់ អ៊ីចឹងមធ្យោបាយមានតែមួយ។ ពេលនោះគាត់និយាយអួលដើមក បែរសម្លឹងមើលទៅភូមិដូចជានឹកកូនៗនៅឯផ្ទះរួចសម្លឹងមើលដើមចារតាសុខរួចងាកមកនិយាយជាមួយពូសារុនបន្តដោយយកដៃមកកាន់ស្មាពូសារុនពោលតិចៗថា ក្មួយ! ពូបានគិតរួចហើយពូនឹងចងកសម្លាប់ខ្លួនដើម្បីឲ្យរួចផុតពីការចោទប្រកាន់ថាពួកខ្មាំង។ ពេលពូស្លាប់ទៅគ្រួសារពូត្រូវរួចខ្លួន ដូច្នេះពូមិនស្តាយជីវិតទេ ដើម្បីឲ្យកូនៗ និងប្រពន្ធនៅរស់មើលថែទាំគ្រួសារបន្តទៅទៀត។ ពេលនោះពូសារុន បានតបទៅវិញថា មិនកើតទេលោកគ្រូបើលោកគ្រូធ្វើអត្តឃាតដោយខ្លួនឯងនោះជាអំពើបាបដ៏ធ្ងន់ធ្ងរណាស់ ព្រះសម្មាសម្ពុទ្ធមិនប្រោសឡើយ។ ពុកខ្ញុំបានតបថាពូដឹងអស់ហើយតែគ្មានជម្រើសទេ ព្រោះថ្ងៃណាក៏ដូចជាថ្ងៃណាដែរពួកកម្មាភិបាលតែងតែមកផ្តន្ទាគ្រួសារពូគ្មានពេលល្ហែឡើយ។ ពូសារុនបន្តថា លោកគ្រូកុំអាលគិតខ្លីតក់ក្រហល់ពេកពេលវេលានៅមានយើងអាចនៅគិតបានវែងឆ្ងាយទៀត។

ជជែកគ្នាបានបន្តិច ស្រាប់តែក្របីចេញមករកស៊ីស្រូវពង្រោះ ឪពុកខ្ញុំបានរត់ទៅដេញ។ ឆ្លៀតពេលនោះពូសារុនបានទៅលួចស្រាយថ្នក់ក្រមាពុកដែលគាត់ព្យួរនៅដើមជនៀងតាកុក។ ពូសារុន ភ្ញាក់ព្រឺត ហើយគិតក្នុងចិត្តថា លោកគ្រូពិតជាមានបំណងចងកសម្លាប់ខ្លួនមែន ដោយឃើញខ្សែចំណងជើងខោវែងវេញជាពីរធ្លុងរួចជាស្រេច និងត្រីរស់ដុតមួយដែលពូសារុនទើបនឹងដុតឲ្យគាត់។ មិនយូរប៉ុន្មានពុកខ្ញុំត្រឡប់មកវិញ ហើយបានទាញថ្នក់ក្រមាស្ពាយដើរចូលទៅក្នុងព្រៃ។ ពេលនោះ ពូសារុន ក៏លួចដើរតាមពីក្រោយមិនឲ្យដឹង។ ពូសារុនសង្កេតឃើញឪពុកខ្ញុំដើរតម្រង់ទៅដើមចារតាសុក ហើយយកត្រីចេញពីថ្នក់ក្រមា អង្គុយចោងហោងហូបបាយ។ ពូសារុន ចេះតែលួចមើលសកម្មភាពពុកខ្ញុំបន្តទៅទៀត។

ពុកខ្ញុំហូបបាយបណ្តើរមើលទៅលើដើមចារបណ្តើរ។ មិនយូរប៉ុន្មានគាត់ក៏លូកយកខ្សែចំណងចេញពីថ្នក់ក្រមា ហើយកាន់មែកចារបម្រុងស្ទុះឡើង។ រំពេចនោះ ពូសារុន បានស្រែកថា “ពូ! យើងដល់ពេលគៀងក្របីទៅភូមិវិញហើយ។ ពេលនោះពុកខ្ញុំគាត់ភ្ញាក់ដោយមិននឹកស្មានថាពូសារុន មកទាន់។ ពុកខ្ញុំក៏ប្រញាប់ប្រញាល់លាក់ខ្សែចំណងចូលក្នុងថ្នក់ក្រមាវិញ”។ តែអ៊ីៗ ពូសារុន ធ្វើជាធម្មតាហាក់ដូចជាមិនដឹងរឿង ហើយនាំគ្នាដឹកក្របីទៅភូមិវិញ។

ស្អែកឡើងមុនចេញទៅវាលចាំក្របីពុកខ្ញុំគាត់បានលួចទៅជួបលោក

តាជីនដែលជាអតីតសិស្សច្បងរបស់គាត់សុទ្ធសឹងជាអ្នកធម៌អាថ៌ហើយបានទំលាយអាថ៌កំបាំងក្នុងចិត្តប្រាប់តាជីនថានឹងបញ្ចប់ជីវិតខ្លួនឯងដើម្បីគ្រួសារគង់វង្ស។ លោកតាជីន បានចេញមកក្រៅផ្ទះទៀម មើលនាយអាយហើយក៏ចូលទៅវិញទាញទ្វារបិទរួចនិយាយខ្សឹបៗថា លោកគ្រូមិនត្រូវគិតខ្លីទេ អ៊ីៗបណ្តោយទៅតាមយថាកម្មចុះ បើជីវិតមិនអស់មិនស្លាប់ទេ។ ម្យ៉ាងទៀត បើ លោកគ្រូសម្លាប់ខ្លួនឯងវាជាអំពើបាបមួយធ្ងន់ធ្ងរណាស់ដែលព្រះមិនអាចប្រោសឲ្យរស់បានទេ វាជាអនន្តរិយកម្មធ្លាក់នរកគ្មានថ្ងៃងើបរួចឡើយ។ ពេលនោះឪពុកខ្ញុំក៏បានក្រាបថ្វាយបង្គំលាលោកតាជីន ចេញទៅចាំក្របី។

មួយសន្ទុះក្រោយមកពូសារុនបានចូលទៅជួបលោកតាជីនចង់និយាយរៀបរាប់រឿងរ៉ាវដែលឪពុកខ្ញុំចង់សម្លាប់ខ្លួន។ មិនទាន់ទាំងហាស្តីផង តាជីនបានប្រាប់ពូសារុន ថា "នែ! អន្ទិតជួយមើលលោកគ្រូ ឡុងផងពេលទៅចាំក្របី ខ្លាចក្រែងលោកគ្រូចងកសម្លាប់ខ្លួនព្រោះមើលទៅ ហាក់ដូចជាបង្កប់នូវអារម្មណ៍សោកសៅជាទីបំផុត" ។ បន្ទាប់មក ពូសារុនបានតបថា "មិនអីទេ ខ្ញុំនឹងតាមមើលនិងជួយលើកទឹកចិត្តគាត់ក្នុងរឿងនេះ"។ ក្រោយមកទៀត ពូសារុន លួចមើលក្នុងថ្នក់ក្រមាដើម្បីលួចយកខ្សែចំណងចេញតែមិនឃើញសោះប្រហែលជាលោកគ្រូបោះចោលបាត់ហើយ។

តែទោះបីជាខ្សែចំណងបោះចោល ហើយក៏ដោយ តែទឹកមុខពុកខ្ញុំនៅតែស្រពាប់ស្រពោនគ្មានពេលស្រស់ស្រាយសោះក្នុងការដោះស្រាយចំណងកម្មផលក្នុងគ្រួសារដែលត្រូវអង្គការសម្លាប់ក្នុងពេលប៉ុន្មានថ្ងៃខាងមុខនេះ។ អ៊ីៗត្រូវដោះស្រាយទៅតាមយថាកម្មនៃរបបអង្គការបដិវត្តន៍មហាលោតផ្លោះមហាអស្ចារ្យល្បីរន្ទឺសុះសាយដែលយកការប្រហារជីវិតប្រជារាស្ត្រជាការអភិវឌ្ឍក្នុងសង្គមខ្ទុះឈាមជាតិឯង ដោយគ្មានគិតក្រែងអាសូរដល់ទុក្ខកង្វល់ប្រជាជននូវចម្រៀងស្រែកឈាមរបស់បដិវត្តន៍ខ្មៅកខ្វក់ស្អីគេនោះ។

ទម្ងន់ទារុណកម្មទុក្ខសោករបស់ឪពុកខ្ញុំពិតជាមិនអាចសាបរលាបបានទេ ហើយក្លាយជាកេរមរតកស្អុយរលួយរបស់របបបដិវត្តន៍ខ្មៅបានដៅមកលើគ្រួសារដ៏កម្សត់នេះស្ទើរឆ្កួតវិញ្ញាណ។


រូបភាពតំណាងលះឪពុកខ្ញុំបម្រុងចងកធ្វើអត្តឃាតនៅដើមចារតាសុខ ។
( ឡុង វង្សសមិទ្ធ/ សៀវភៅ ទួលពិឃាដ )

# ខ្ញុំសូមប្រកាសរកបងប្រុសដែលបាត់ខ្លួន



នួន មករា ថតឆ្នាំ១៩៩៤។
(នួន មករា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

នាងខ្ញុំឈ្មោះ **នួន មករា** ហៅ មុំ ភេទស្រី មានអាយុ ៤៥ឆ្នាំ។ បច្ចុប្បន្នខ្ញុំរស់នៅភូមិពោធិ៍តាគួយ ឃុំលលកស ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់។ ខ្ញុំមិនចាំរូបរាងឪពុកម្តាយ និងបងប្រុសរបស់ខ្ញុំទេ ព្រោះកាលនោះ ខ្ញុំនៅជាកូនង៉ានៅឡើយ។

តាមរយៈឪពុកចិញ្ចឹមរបស់ខ្ញុំ ឈ្មោះ ពៅ វណ្ណ ហៅ ធី ដែលបានជួយសង្គ្រោះជីវិតខ្ញុំ និងបានយកខ្ញុំចេញពីសាកសពម្តាយរបស់ខ្ញុំបាននិយាយរៀបរាប់ប្រាប់ខ្ញុំថា នៅខែវិច្ឆិកា ឆ្នាំ១៩៧៨ គាត់គឺជាទាហានប៉ារ៉ានៅជរំតាមបណ្តោយព្រំដែនខ្មែរ-ថៃ និងតែងតែដើរល្បាតនៅក្នុងទឹកដីខ្មែរ។ ពេលដែលគាត់ធ្វើដំណើរដល់ឃុំត្គុលដូនទាវ ស្រុកឯកភ្នំ ខេត្តបាត់ដំបង ដែលជាទីកន្លែងសម្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហម គាត់និងទាហាន៥នាក់ទៀតនៅក្នុងអង្គភាពបានឮសំឡេងក្មេងយំ។ ដំបូងគាត់នឹកស្មានថាខ្មោចលង ប៉ុន្តែពេលគាត់ខិតខំផ្ទៀងស្តាប់ទើបដឹងថាសំឡេងក្មេងយំ។ នៅអំឡុងពេលនោះគាត់បានឃើញក្មេងប្រុសម្នាក់អាយុប្រមាណ៦ឆ្នាំ គឺជាបងប្រុសរបស់ខ្ញុំ កំពុងទាញខ្ញុំចេញពីសាកសពម្តាយដែលមានក្លិនស្អុយទៅហើយ ព្រោះពេលនោះខ្ញុំកំពុងបៅដោះម្តាយ។ បងប្រុសរបស់ខ្ញុំក្រឡេកក្រោយក៏ឃើញគាត់ (ឪពុកចិញ្ចឹមរបស់ខ្ញុំ)។ បងប្រុសរបស់ខ្ញុំស្មានថា គាត់គឺយោធាខ្មែរក្រហមក៏ទុកខ្ញុំចោល ហើយរត់គេចចេញទៅបាត់ ដោយមិនបានស្តាប់គាត់ស្រែកហៅឡើយ។ គាត់និងទាហាននៅក្នុងអង្គភាពបានឆែកសាកសពម្តាយរបស់ខ្ញុំរកឃើញឯកសារទាក់ទងនឹងឪពុកម្តាយបង្កើតរបស់ខ្ញុំ។ ឪពុកបង្កើតរបស់ខ្ញុំមានស្រុកកំណើតនៅទីក្រុងភ្នំពេញ ចំណែកម្តាយរបស់ខ្ញុំគឺជាអ្នកខេត្តបាត់ដំបង។ ឪពុកម្តាយរបស់ខ្ញុំជាប់សែស្រឡាយចិនមករស់នៅស្រុកខ្មែរ។ ឪពុករបស់ខ្ញុំមានរូបរាងខ្ពស់ សម្បុរស ចំណែកម្តាយរបស់ខ្ញុំទាប និងមានសម្បុរស្រអែម។

នៅអំឡុងឆ្នាំ១៩៨០ ពេលដែលខ្ញុំធ្វើដំណើរជាមួយឪពុកចិញ្ចឹមនៅតាមផ្លូវនៅស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ មានស្ត្រីម្នាក់បានស្នើសុំខ្ញុំពីឪពុកចិញ្ចឹម យកទៅនៅជាមួយ។ ឪពុកចិញ្ចឹមខ្ញុំបានយល់ព្រមប្រគល់ខ្ញុំឲ្យស្ត្រីនោះ ព្រោះគាត់គិតថា គាត់មិនទាន់មានប្រពន្ធមិនអាចចិញ្ចឹមខ្ញុំបានឡើយ។

នៅក្នុងឆ្នាំ១៩៩៤ មានឧបទ្ទវហេតុគ្រោះថ្នាក់ចរាចរកើតលើម្តាយចិញ្ចឹមរបស់ខ្ញុំ។ ពេលនោះខ្ញុំបានជួបបុរសម្នាក់ដែលជាអ្នកបង្កហេតុបុកម្តាយចិញ្ចឹមរបស់ខ្ញុំបណ្តាលឲ្យមានរបួសធ្ងន់។ ម្តាយចិញ្ចឹមរបស់ខ្ញុំត្រូវបានបញ្ជូនមកមន្ទីរពេទ្យកាល់ម៉ែត្រដើម្បីព្យាបាល។ ខ្ញុំមិនចាំត្រកូល



នូ មករា ថតឆ្នាំ២០២២។
(នូ មករា/មជ្ឈមណ្ឌលឯកសារកម្ពុជា)

របស់អ្នកបន្តហេតុច្បាស់លាស់ទេ គាត់ឈ្មោះ លី ប៊ុនធឿន ឬ ឡុង ប៊ុនធឿន។ គាត់បានសួរខ្ញុំថា «អ៊ំស្រីជាម្តាយបង្កើតរបស់ប្អូនឬ? ប៉ុន្តែមុខរបស់ប្អូនមិនដូចម្តាយរបស់ប្អូនទេ គឺមុខរបស់ប្អូនដូចបងទៅវិញ»។ ខ្ញុំមិនបានដឹងរឿងនេះទេ ព្រោះម្តាយចិញ្ចឹមរបស់ខ្ញុំមិនដែលប្រាប់ខ្ញុំ។ បង ប៊ុនធឿន មានមុខមាត់ស្រដៀងខ្ញុំហើយគាត់ក៏បាត់ប្អូនស្រីដែរ។ គាត់បានប្រាប់ខ្ញុំថាប្រសិនបើមានកិច្ចការអ្វីអាចទៅរកគាត់បាន គាត់រស់នៅជាមួយម្តាយមីងនៅម្តុំផ្សារស៊ីលីបដោយប្រកបរបរលក់ដូរ និងលក់ដូង។ ក្រោយមក នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ទើបខ្ញុំដឹងថា ម្តាយដែលខ្ញុំរស់នៅជាមួយគឺជាម្តាយចិញ្ចឹម។ នៅក្នុងឆ្នាំ២០១៥ ខ្ញុំបានទៅរកបង ប៊ុនធឿន នៅម្តុំផ្សារស៊ីលីបដើម្បីសួរនាំអំពីប្អូនស្រីរបស់គាត់ដែលបាត់ខ្លួនឲ្យច្បាស់ ព្រោះខ្ញុំក៏បាត់បងប្រុសដែរ ប៉ុន្តែប្រជាជនដែលរស់នៅម្តុំផ្សារស៊ីលីបប្រាប់ថា បងធឿន បានលក់ផ្ទះហើយ។ បងធឿន ធ្លាប់និយាយប្រាប់ខ្ញុំថា ប្រសិនបើគាត់រកប្អូនស្រីរបស់គាត់មិនឃើញទេ ពូរបស់គាត់នឹងនាំគាត់ទៅរស់នៅប្រទេសហុងកុង។

ខ្ញុំចង់ជួប បងធឿន ដើម្បីសាកសួរព័ត៌មាន ហើយប្រសិនបើបងប្អូនណាដែលមានដំណើរជីវិតប្រហាក់ប្រហែលនឹងការរៀបរាប់ខាងលើអាចទំនាក់ទំនងមកនាងខ្ញុំតាមរយៈលេខទូរស័ព្ទ៖ ០៨៦ ៨២ ៧៥ ០៧ ឬ ០៩២ ៧១០ ៦០៨ ឬតាមរយៈសារអេឡិចត្រូនិច៖ truthmeta.d@dccam.org។ សូមអរគុណ!



នូរ មករា ថតឆ្នាំ២០២២។
(នូរ មករា / មជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របមុខ៖

ស្ត្រីកំពុងបែនស្រូវ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)

រូបក្របក្រោយ៖

ស្ត្រីកំពុងកាប់ដំឡូងហាល នៅស្រុកអន្លង់វែង ខេត្តឧត្តរមានជ័យ។ (បណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជា)




**មជ្ឈមណ្ឌលឯកសារកម្ពុជា ៖ ការិយាល័យព័ត៌មានសាធារណះ**

ផ្ទះលេខ៦៦ មហាវិថីព្រះសីហនុ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរសព្ទ៖ (៨៥៥) ២៣ ២១១ ៨៧៥

DC-Cam/PIR: #66 ◆ Preah Sihanouk Blvd ◆ Phnom Penh ◆ Cambodia ◆ Tel: (855) 23 211 875 ◆ dccam@online.com.kh ◆ www.dccam.org

A magazine of the Documentation Center of Cambodia: Searching for the Truth ◆ Issue 267, March 2022 ◆ Funded by USAID

Licensed by the Ministry of Information of the Kingdom of Cambodia, Prakas No. 375 P.M. PRA. KA, 30 October 2018.